ជំពូកទី ៦

Draft

ជំពូកទី៦: ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ

៦.១ សេចក្តីផ្តើម

គោលបំណងនៃការសិក្សាការវាយតំលៃហេតុប៉ះពាល់បរិស្ថាន គឺដើម្បីរកអោយឃើញ និងកំណត់ពីហេតុប៉ះពាល់បរិស្ថានទៅលើធនធានធម្មជាតិ និងធនធានសង្គម ដែលអាចកើតឡើងក្នុងកំឡុងពេលរៀបចំប្លង់ សាងសង់ និងប្រតិបត្តិការគំរោង។ ក្រុមសិក្សាបរិស្ថានបានធ្វើការអង្កេតនៅទីតាំងជាក់ស្តែង និងត្រួតពិនិត្យមើលសក្តានុពលនៃហេតុប៉ះពាល់ទាំងវិជ្ជមាន និងអវិជ្ជមាន ហើយរៀបចំនូវវិធានការកាត់បន្ថយចំពោះហេតុប៉ះពាល់ជាអវិជ្ជមាននីមួយៗ។

ដើម្បីត្រួតពិនិត្យពីសក្តានុពលនៃហេតុប៉ះពាល់បរិស្ថាន ក្រុមសិក្សាបានប្រើប្រាស់បញ្ជីពិនិត្យវាយតំលៃបរិស្ថាន (checklist) តារាង ៦.១-១។ ផ្អែកតាមលទ្ធផលនៃការអង្កេតនៅទីតាំងជាក់ស្តែងទៅលើបរិស្ថាន និងសង្គមនៅក្នុងតំបន់គំរោងបង្ហាញថា សក្តានុពលនៃហេតុប៉ះពាល់បរិស្ថានដែលរំពឹងទុកថានឹងកើតឡើងដោយសកម្មភាពគំរោង មុនការសាងសង់ ពេលសាងសង់ និងដំណាក់កាលប្រតិបត្តិគំរោងត្រូវបានរៀបរាប់នៅក្នុងជំពូកនេះ។ វិធានការកាត់បន្ថយសំរាប់ហេតុប៉ះពាល់អវិជ្ជមាននីមួយៗត្រូវបានផ្តល់ជាអនុសាសន៍តាមចំនុចលំដាប់លំដោយ។

តារាង ៦.១-១: បញ្ជីពិនិត្យវាយតំលៃបរិស្ថាន

ល.រ	បញ្ជីបរិស្ថាន	បរិយាយ	ការវាយតំលៃ		ចំណាំ
			គ្មាន	មាន	
ក.	**បរិស្ថានសង្គម**				
១	ការតាំងលំនៅដ្ឋានសារជាថ្មី	ការតាំងលំនៅដ្ឋានសារជាថ្មី ដោយសារការកាន់កាប់ដី (ផ្ទេរសិទ្ធិជាម្ចាស់ផ្ទះ/ ដីធ្លី)	✓		គ្មានការតាំងលំនៅដ្ឋាននៅលើកោះពស់ ឆ្នេរហាវ៉ៃ និងការដ្ឋានស្ពានកោះពស់ទេ
២	សកម្មភាពសេដ្ឋកិច្ច	ពាត់បង់មូលដ្ឋានសេដ្ឋកិច្ច ដូចជាដី និងការផ្លាស់ប្តូរទំរង់សេដ្ឋកិច្ច	✓		គ្មានសកម្មភាពសេដ្ឋកិច្ចក្នុងទីតាំងគំរោង
៣	ចរាចរណ៍ និងសេវាកម្មសាធារណៈ	ហេតុប៉ះពាល់លើសាលារៀន មន្ទីរពេទ្យ និងស្ថានភាពចរាចរណ៍បច្ចុប្បន្ន ដូចជា ការកើនឡើងគ្រោះថ្នាក់ចរាចរណ៍ជាដើម		✓	ការកើនឡើងចរាចរណ៍លើដងផ្លូវនៅក្នុងតំបន់គំរោង ដោយការដឹកជញ្ជូនសំភារៈសាងសង់ អំឡុងពេលសាង សង់គំរោង
៤	ញ្ជែកសហគមន៍	ញ្ជែកសហគមន៍ដោយសារការផ្តាច់ចរាចរណ៍នៃតំបន់	✓		គំរោងមិនបានញ្ជែកសហគមន៍ទេ ថែមទាំងភ្ជាប់ដីគោក ទៅដីកោះទៀតផង

ល.រ	បញ្ជីបរិស្ថាន	បរិយាយ	ការវាយតម្លៃ		ចំណាំ
			គ្មាន	មាន	
៥	សម្បត្តិវប្បធម៌	ធ្វើឱ្យខូចខាត ឬបាត់បង់តម្លៃនៃ វត្តអារ៉ាម ព្រះវិហារគ្រិស ចេតិយ្យ កន្លែងបុរាណសាស្ត្រ និងវត្ថុវប្បធម៌	✓		គ្មានវត្ថុវប្បធម៌មាននៅក្នុងតំបន់គំរោងទេ
៦	សិទ្ធិប្រើប្រាស់ ទឹក និងសិទ្ធិ ទូទៅ	ឧបសគ្គចំពោះ សិទ្ធិនេសាទ សិទ្ធិប្រើប្រាស់ទឹក និងសិទ្ធិទូទៅ		✓	គំរោងនឹងប៉ះពាល់ដល់សកម្មភាពនេសាទនៃអ្នកនេសាទ មួយចំនួនក្បែរតំបន់គំរោង ជាពិសេសនៅជុំវិញ កោះពស់ ។ គំរោងនឹងមានការរំខានដល់នាវាចរណ៍ ក្នុងពេលសាងសង់ស្ពាន កាត់ឃ្លងធម្មជាតិ ។
៧	ស្ថានភាពសុខ ភាពសាធារណៈ	ការថមថយសុខភាព សាធារណៈ និងស្ថានភាពអនាម័យ ដោយសារ បង្កើតសំរាម និងសត្វល្អិតចង្រៃ		✓	ស្ថានភាពការងារខ្វះសុវត្ថិភាព និងគ្មានទឹកស្អាតប្រើប្រាស់ អាចប៉ះពាល់ដល់សុខភាពសាធារណៈ ។ បើសិនគ្រប់គ្រងកាក សំណល់ចេញពីមនុស្សមិនបានត្រឹមត្រូវ បង្កើតថ្នក់ទឹក ទឹកក្រខ្ជក់ និងសំណល់អាហារ ។
៨	ផ្លូវនាវាចរណ៍ និងកំពង់ផែ	ការរំខានដល់សកម្មភាព នាវាចរ និងកំពង់ផែកំពង់លោម		✓	គំរោងពីរកន្លែងប៉ះពាល់ដល់សកម្មភាពនាវាចរ របស់នាវាត្រាប់ប្រភេទអំឡុងពេលសាងសង់ និងបញ្ចប់ការឆ្លងកាត់ឃ្លងធម្មជាតិនៃនាវាខ្នាត់ចំ អំឡុងពេលប្រតិបត្តិការ
៩	គ្រោះថ្នាក់ (ហានិភ័យ)	បង្កើនគ្រោះថ្នាក់នៃការអ៊ីលបាក់ដី បង្កើតអាងទឹកក្រោមដី ។ល។		✓	ការអ៊ីលបាក់ដី និងបង្កើតអាងទឹកក្រោមដី មិនអាចកើតមានក្នុងតំបន់គំរោងទេ ដោយលក្ខខណ្ឌភូគព្ភសាស្ត្រតំបន់ និងប្រភេទគំរោង ។ ប៉ុន្តែស្ពានអាចជាកន្លែងធ្វើអត្តឃាតចំពោះអ្នកមោចាំង ឬខូចចិត្ត ។
ខ.	**បរិស្ថានធម្មជាតិ**				
១០	ឋានលេខា និងភូគព្ភសាស្ត្រ	ប្រែប្រួលតម្លៃនៃឋានលេខា និងភូគព្ភសាស្ត្រដោយការជីក ឬការចាក់បំពេញ		✓	នឹងប្រែប្រួលស្ថានភាពឋានលេខា ជាពិសេស នៅលើកោះពស់ ដោយសារការឈូសឆាយដីរៀបចំការដ្ឋានសាងសង់ ផ្លូវ សណ្ឋាគារ និងអគារផ្សេងៗ ។
១១	ការហូរច្រោះដី	ការហូរច្រោះដីស្រទាប់លើ ដោយសារភ្លៀងក្រោយការឈូសឆាយ និងកាប់សំអាតព្រៃ		✓	អាចកើតឡើងនៅការដ្ឋានសាងសង់អំឡុងពេលឈូសឆាយ និងកាប់សំអាតព្រៃលើកោះពស់
១២	ការស្រុតដី	ការប្តូររូបសណ្ឋានដី និងការស្រុតដី ដោយសារកំពស់ទឹកក្រោមដីថយចុះ	✓		រំពឹងថាមិនមានកើតឡើងទេ ដោយលក្ខខណ្ឌភូគព្ភសាស្ត្រតំបន់ និងសកម្មភាពគំរោង ។
១៣	ទឹកក្រោមដី	ការថយចុះកំពស់ទឹកក្រោមដី ដោយសារភាពរាំងស្ងួតអូសបន្ទាយ និង ករដីបង្ហដោយសកម្មភាពសាងសង់	✓		សកម្មភាពសាងសង់ និងប្រតិបត្តិការគំរោង ពុំមានផលប៉ះពាល់ដល់ទឹកក្រោមដី ។ គំរោងពុំប្រើប្រាស់ទឹកក្រោមដីទេ

Draft

ល.រ	បញ្ជីបរិស្ថាន	បរិយាយ	ការវាយតំលៃ		ចំណាំ
			គ្មាន	មាន	
១៤	ស្ថានភាពជលសាស្ត្រ	ប្រែប្រួលរំហូរទន្លេ និងទឹកស្រទាប់បាតទន្លេ ដោយសារការបំពេញដី និងការហូរចូលនៃប្រព័ន្ធរំដោះទឹក	✓		គំរោងនឹងគ្មានការចាក់បំពេញដីទេ ហើយប្រព័ន្ធរំដោះទឹកមានផ្តល់យ៉ាងគ្រប់គ្រាន់ដែរ
១៥	តំបន់ឆ្នេរ	ការហូរច្រោះតំបន់ឆ្នេរ និងប្រែប្រួលរុក្ខជាតិ ដោយសារការរានឆ្ការតំបន់ឆ្នេរ និងប្រែប្រួលឆ្នេរ		✓	ដើមឈើមួយចំនួនលើកោះនឹងត្រូវកាប់ចេញ ដើម្បីសំអាត ការដ្ឋានសាងសង់
១៦	សត្ត និងរុក្ខជាតិ	បង្អាក់ការបន្តពូជ និងធ្វើឱ្យផុតពូជ ដោយសារការប្រែប្រួលលក្ខខណ្ឌជំរក		✓	សកម្មភាពសាងសង់នៃគំរោងទាំងមូល អាចប៉ះពាល់លើ ព្រៃឈើ សត្វព្រៃ ជលផល នៅក្នុងតំបន់កោះពស់ ។ ពេលខ្លះ ការប្រតិបត្តិគំរោងប៉ះពាល់ដល់ជលផលផងដែរ ដោយសារការបញ្ចេញកាកសំណល់ចូលទៅក្នុងទឹក
១៧	ឧតុនិយម	ប្រែប្រួលសីតុណ្ហភាព កំណកបរិយាកាស ខ្យល់ ។ល។ ដោយសារការកាប់ឆ្ការព្រៃ ឈើយ៉ាងច្រើនសំរាប់ការសាងសង់ អាគារធំ១	✓		ពុំមានការកាប់ឆ្ការព្រៃ ឈើយ៉ាងច្រើនសំរាប់ការសាងសង់ អាគារធំ១នោះទេ
១៨	ទេសភាព	ប្រែប្រួលជ្រានលេខា និងការកាប់ឆ្ការព្រៃ ឈើ ការថយចុះសោភ័ណ្ឌភាពសមគ្នា ដោយសារសំណង់រូបសាស្ត្រ		✓	គំរោងនឹងប៉ះពាល់ទិចតូចអំឡុងពេលសាងសង់លើកោះពស់ ។ ស្ពានកោះពស់នឹងធ្វើឱ្យថយចុះសោភ័ណ្ឌភាពធម្មជាតិ រវាងដីគោក និងកោះពស់
គ.	**ការបំពុល**				
១៩	ការបំពុលខ្យល់	ខ្យល់ក្រខ្វក់បង្កឡើងការភាយឧស្ម័ន និងសាធាតុពុលចេញពីយានយន្ត និងរោងចក្រ		✓	ការបំពុលខ្យល់បន្ទិចបន្ទួច នឹងកើតចេញពីគ្រឿងចក្រសាងសង់ យានយន្ត និង ធូលី អំឡុងពេលសាងសង់ និង ដំណើរការគំរោង ។
២០	ការបំពុលទឹក	ការបំពុលបង្កឡើងដោយរំហូរកកកដី ខ្សាច់ និង ទឹកក្រខ្វក់ចេញពីរោងចក្រ ។លេ ។		✓	ទឹកក្រខ្វក់ចេញពីការដ្ឋានសាងសង់ អាចកើតចេញពីការឈូសឆាយដីក្នុងរដូវភ្លៀង ។ ការបង្ហូរទឹកតាមបណ្តាញផ្ទល់ និងទឹកក្រខ្វក់ចេញពីលំនៅដ្ឋាន ពុំមានការសំអាតចូលទៅក្នុងប្រភពទឹកនឹងកើតមាននៅពេលប្រតិបត្តិការគំរោង ។
២១	សំណល់	សំណល់កើតចេញពីការងារសាងសង់ អាចម៍ដី និង សំណល់ទូទៅ		✓	<u>ពេលសាងសង់:</u> សំណល់ពីការដ្ឋានសាងសង់ ដូចជា កំទេចកំទីនៃ សំភារៈសំណង់ (ក្រដាស ជ័រ ឈើ ដែក) និង អាចម៍ដី សំណល់ចេញពី បុគ្គលិក/កម្មករ ដូចជា សំណល់អាហារ លាមក និងទឹកនោម ។ <u>ពេលប្រតិបត្តិការ:</u> សំណល់រឹងតាមលំនៅដ្ឋាន

ល.រ	បញ្ជីបរិស្ថាន	បរិយាយ	ការវាយតំលៃ		ចំណាំ
			គ្មាន	មាន	
					អគារពាណិជ្ជកម្ម ភោជនីអាហារ សណ្ឋាគារ និងការបង្ហូរចេញនូវទឹកក្រខ្វក់ចូលក្នុងសមុទ្រ ។
២២	ការធ្វើឱ្យក្រខ្វក់ដី	ការធ្វើឱ្យក្រខ្វក់បង្កដោយបង្ហូរ ឬ សាយភាយនៃទឹកលូ ឬសាធាតុពុល	✓		ពុំកើតមានក្នុងការដ្ឋានគំរោងទេ ដោយសារទីតាំង និងការរចនាបួងគំរោង
២៣	សំលេង និងរំញ័រ	សំលេង និងរំញ័រកើតចេញពីយានយន្ត យន្តហោះ និងដំណើរការរោងចក្រ		✓	នឹងកើតមានពីគ្រឿងចក្រសាងសង់ អំឡុងពេលសាងសង់
២៤	ក្លិនមិនល្អ	កើតពីការបំភាយឧស្ម័ន និងអាក្រក់ចេញពីគ្រឿងសាងសង់ និងប្រតិបត្តិការ	✓		ពុំមានក្លិនអាក្រក់ភាយចេញទេ ដោយសារប្រភេទគំរោង ទីតាំង និងការរចនាបួង

៦.២ ហេតុប៉ះពាល់បរិស្ថានជាអវិជ្ជមាន និងវិធានការកាត់បន្ថយ

៦.២.១ ដំណាក់កាលមុនសាងសង់

នៅក្នុងដំណាក់កាលរៀបចំបួងគំរោង មិនមានសកម្មភាពជាគ្រោះថ្នាក់ចំបងណាមួយទៅលើធនធានធម្មជាតិ និងធនធានសង្គមនៅក្នុងតំបន់គំរោងនេះទេ ។ គំរោងពុំមានហេតុប៉ះពាល់លើដីសហគមន៍ ឬទ្រព្យសម្បត្តិសហគមន៍នៅក្នុងតំបន់ទេ ហើយគ្រប់ទីតាំងសាងសង់ស្ថិតនៅលើដីជួលរយៈពេល៩៩ឆ្នាំរបស់ក្រុមហ៊ុនកោះពស់ទាំងស្រុង ។ ពុំមានការផ្លាស់ប្តូរលំនៅដ្ឋានសូម្បីតែមួយគ្រួសារក៏គ្មានដែរ ។

មានតែសកម្មភាពទាក់ទងជាមួយនឹងការជ្រើសរើសទីកន្លែងគំរោង ការស្រាវជ្រាវ និងការចុះអង្កេត សំរាប់ការរៀបចំបួងគំរោងប៉ុណ្ណោះ ។

- **ទីតាំងគំរោង និង ការរចនាបួង**

គំរោង**មរកត**មានទីតាំងនៅក្រៅឧទ្យានជាតិរាម និងនៅក្រៅតំបន់អភិរក្សជំរៅទឹកក្បាលឆាយ ។ ដូចនេះទីតាំងគំរោងមិនប៉ះពាល់ដល់កន្លែងអភិរក្ស ឬកន្លែងការពារនានានៅក្នុងតំបន់នេះទេ ។

ប៉ុន្តែការរៀបចំខ្សែបន្ទាត់ស្ពានកាត់តាមឃ្លងធម្មជាតិនៅក្នុងតំបន់កោះពស់ ដែលជាកន្លែងផ្លូវនាវាចរណ៍សំរាប់កប៉ាល់ចេញចូលទៅផែកំពង់សោម ។ ដូចនេះស្ពានន៏ងជាឧបសគ្គដល់ការធ្វើនាវាចរណ៍ខ្លាតធំ យោងតាមបួងកំពស់ស្ពានមានត្រឹមតែ ៣២.៥ម ពីផ្ទៃទឹកខ្ពស់បំផុតក្នុងតំបន់នេះ ។ ផ្អែកតាមទំហំនាវាដែលបានឆ្លងកាត់ឃ្លងនេះ ក្រសួងសាធារណការ និងដឹកជញ្ជូន បានស្នើទៅក្រុមហ៊ុនកោះពស់ ដើម្បីរកលទ្ធភាពសាងសង់ស្ពានកោះពស់នេះដែលមានកំពស់ ៣៧.៥ម ពីផ្ទៃទឹកខ្ពស់បំផុតក្នុងតំបន់នេះ ។

សមាសធាតុជំនួយផ្សេងៗទៀតរបស់គំរោងដូចជាម៉ាស៊ីនលាយស៊ីម៉ង់ត៍ កន្លែងស្តុកទុកស៊ីម៉ង់ត៍ និងជំរុំកម្មករជាដើម ដែលរៀបចំដាក់នៅលើទីលានដីគោកនៅតាមមាត់សមុទ្រជិតសំណង់ស្ពាន និងឆ្នេរហាវ៉ៃ នឹងធ្វើឱ្យមានការមិនសប្បាយចិត្តដល់អ្នកជិតខាង និងអ្នកទេសចរណ៍នៅឆ្នេរលំហែកាយ និងឆ្នេរហាវ៉ៃ ទោះបីជាសំណង់នោះស្ថិតនៅក្នុងដីជួលរបស់គំរោងក៏ដោយ ។

➢ *<u>វិធានការកាត់បន្ថយ</u>*

ការជ្រើសរើសទីតាំងគំរោង និងកំពស់ស្ពានកោះពស់ត្រូវបានដោះស្រាយដោយអន្តរក្រសួងដែលដឹកនាំដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) ដោយមានការឯកភាពពី ***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*** *នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា (RGC) សូមមើលឧបសម្ព័ន្ធទី២គ ។ នៅក្នុងលិខិតលេខ ៧៧៨/០៨ របស់ CDC នៃ RGC បានបញ្ជាក់ថា ស្ពានអាចសាងសង់នៅកំពស់ពី ២៨ម ទៅ ៣២ម ពីផ្ទៃទឹកខ្ពស់បំផុត ។ ជាងនេះទៀត ក្នុងប្រការពាក់ព័ន្ធ "កិច្ចសន្យាបន្ថែមស្តីពី ការកែសំរួលខ្លឹមសារក្នុងកិច្ចសន្យាជួលកោះពស់ និងដីឆ្នេរកោះពស់ (ឆ្នេរហាវ៉ៃ) ក្រុងព្រះសីហនុ ពាក់ព័ន្ធនឹងការប្តូរទីតាំងសាងសង់គល់ស្ពាន (ផ្នែកដីគោក) ឥឡូវពីផ្នែកដីគោក ទៅកោះពស់"(ឧបសម្ព័ន្ធទី២ឃ) បានចែងថា ភាគី "ខ" (កោះពស់ (ខេមបូឌា) អ៊ីនវេសមេនត្រូប អេលធីឌី) ត្រូវអនុវត្តតាមគោលការណ៍បច្ចេកទេស ដូចខាងក្រោម:-*

- ***កំពស់ស្ពាន:*** *ត្រង់ចំនុចតន្លង់នាវាចរ ត្រូវមានកំពស់យ៉ាងទាប ៣២ម៉ែត្រ គិតចាប់ពីផ្ទៃទឹកពេលទឹកសមុទ្រជោរខ្ពស់បំផុត ។*
- ***គំលាតសរសរស្ពាន:*** *នៅត្រង់តំបន់តន្លង់នាវាចរ ការសាងសង់សរសរស្ពាន ត្រូវមានគំលាតពីគ្នាយ៉ាងតិច ១៥០ ម៉ែត្រ ដើម្បីសំរួលដល់ចរាចរនាវា ។*
- ***សំភារៈតាំងភ្ជាប់ និងស្លាកសញ្ញាចរាចរ:*** *ត្រូវមានគំនូសចរាចរ-បំពាក់ភ្លើងអគ្គិសនីតាមបណ្តោយស្ពានរួមទាំងខាងលើ និងខាងក្រោមស្ពានផងដែរ-បំពាក់បង្ហាន់ដៃស្ពាន-បំពាក់ស្លាកសញ្ញាចរាចរផ្សេងៗទៀតតាមលក្ខណៈបច្ចេកទេសកំណត់ ។*
- ***លក្ខណៈបច្ចេកទេសសាងសង់ស្ពាន:*** *ត្រូវគោរពតាមការណែនាំរបស់ភាគី "ក" និងក្រសួង-ស្ថាប័នមានសម្ថកិច្ចពាក់ព័ន្ធ ក្នុងនោះរួមទាំងសុវត្ថិភាពការងារក្នុងពេលសាងសង់ផងដែរ ។*

គណៈកម្មការត្រួតពិនិត្យបទដ្ឋានបច្ចេកទេសសាងសង់ស្ពានកោះពស់ បានបង្កើតតាំងពី ខែមករា ឆ្នាំ ២០០៨ ដោយក្រសួងសាធារណការ និងដឹកជញ្ជូន សូមមើលឧបសម្ព័ន្ធទី៣ ហើយមានភារកិច្ចដើម្បី (១) អធិការកិច្ច និងកែតំរូវ ទៅតាមបទដ្ឋានបច្ចេទេស និងសំណង់វិស្វកម្មស្ពាន (២) រៀបចំកិច្ចប្រជុំចាំបាច់ និងពិភាក្សាជាមួយក្រុមហ៊ុនវិនិយោគ និងភាគីពាក់ព័ន្ធផ្សេងទៀត ។

ក្រុមហ៊ុនអនុវត្តន៍គំរោងនឹងគោរពតាមបណ្ដាវិស្វកម្មទាំងអស់ដែលបានយល់ព្រមដោយអន្តរក្រសួង ព្រមទាំងសហការល្អជាមួយគណៈកម្មការត្រួតពិនិត្យបទដ្ឋានបច្ចេកទេសសាងសង់ស្ពានកោះពស់ ។

ពិភាក្សាជាមួយអ្នកជិតខាងនៃទីកន្លែងគំរោងដោយសន្តិវិធី និងសហប្រតិបត្តិការល្អជាមួយអាជ្ញាធរមូលដ្ឋាន អ្នកដឹកនាំសហគមន៍ ឬមេភូមិនៅពេលរៀបចំគ្រប្លង់ និងការរៀបចំដាក់សមាសធាតុទាំងអស់របស់គំរោង ទោះបីដាក់នៅក្នុងបរិវេណដីគំរោងក៏ដោយ ជាពិសេសសមាសភាពគំរោងនៅការដ្ឋានឆ្នេរហាវ៉ៃ និងស្ពានកោះពស់ ។

- **ការសំអាតការដ្ឋានសាងសង់**

ការឆ្ការព្រៃប្រមាណជា ៤៦ហត ឬ ៤៧% នៃផ្ទៃព្រៃឈើលើកោះ និងការឈូសឆាយដីសំរាប់ការដ្ឋានសាងសង់ជំរុំកម្មករ និងសមាសធាតុបន្ទាប់បន្សំផ្សេងទៀត នឹងមានផលប៉ះពាល់ដល់ធនធានបរិស្ថាន និងថយចុះប្រព័ន្ធអេកូឡូស៊ីនៅក្នុងតំបន់ ។ ការបាត់បង់ដើមឈើ និងកំរាលរុក្ខជាតិនៅការដ្ឋានសាងសង់ ដោយសារការឈូសឆាយដី នឹងបង្កឱ្យមានសំណឹកដី និងប៉ះពាល់ដល់គុណភាពទឹក ។ ការបំពុលខ្យល់ ធូលី សំលេង និងរំញ័រ នឹងបង្កហេតុប៉ះពាល់ដល់សហគមន៍ជិតខាង ។ ផលប៉ះពាល់នេះ អាចចាត់ទុកថាមានកំរិតមធ្យមដល់ធនធានព្រៃ និងអេកូឡូស៊ីរបស់កោះពស់ ។

➢ *<u>វិធានការកាត់បន្ថយ</u>*

- *ការសំអាតទីតាំងនេះនឹងត្រូវធ្វើឡើងក្នុងផែនកំណត់សំរាប់តែធ្លាចាំបាច់ដែលបំរើឱ្យការសាងសង់ប៉ុណ្ណោះ ។ ការឈូសឆាយដីនៅរដូវប្រាំងត្រូវបានរៀបចំក្នុងផែនការ ។*
- *វិធានការសំខាន់ៗសំរាប់ការពារចំរោះដីនឹងត្រូវបានអនុវត្ត ដូចជា រៀបចំជាថ្នាក់ៗដូចកាំជណ្តើរ ការដាក់ក្រណាត់សំពត់ចាប់យកកករដីនៅការដ្ឋានក្នុងទឹក និងមាត់ទឹក ។*
- *កំរិតកំណត់សំលេង និងរំញ័រចេញពីម៉ាស៊ីន គ្រឿងចក្រនៅពេលឈូសឆាយដី និងពេលកាប់ដើមឈើ ដោយប្រើប្រាស់គ្រឿងចក្រ និងយានយន្តដែលមានគុណភាពល្អ ។ គំរោងមានផែនការអនុវត្តការងារឈូសឆាយដី និងសំអាតទីតាំងនេះនៅតែពេលថ្ងៃប៉ុណ្ណោះ ។*

- **ការអង្កេតពីភូតពន្ធសាស្ត្រ**

ការខួងដី និងផ្ទដើម្បីអង្កេតពីភូតពន្ធសាស្ត្រនៅលើកោះពស់ ទីតាំងស្ពាន និងតំបន់អភិវឌ្ឍន៍ឆ្នេរហាវ៉ៃ អាចបង្កហេតុប៉ះពាល់ដល់គុណភាពទឹកតាមឆ្នេរនៅក្នុងតំបន់គំរោង ។ ម្យ៉ាងវិញទៀត ការបញ្ចេញភក់ពីរណ្តៅខួងក្នុងទឹកសមុទ្រ អាចបង្កហេតុប៉ះពាល់ដល់គុណភាពទឹកតាមឆ្នេរផងដែរ ។ ការខួងនៅលើដីគោកក្នុងតំបន់អភិវឌ្ឍឆ្នេរហាវ៉ៃ អាចបង្កហេតុប៉ះពាល់ដល់សហគមន៍ដែលនៅជាប់ និងអ្នកទេសចរណ៍ ដោយសារការបំពុលខ្យល់ សំលេង និង រំញ័រពីសកម្មភាពខួង ។ ប៉ុន្តែផលប៉ះពាល់នេះ មិនមានលក្ខណៈធំដុំទេ ហើយវាមានរយៈពេលខ្លីទៀតផង ។

➢ *<u>វិធានការកាត់បន្ថយ</u>*

- *ការការពារជាមូលដ្ឋានមួយចំនួនចំពោះ ភក់ ឬល្បប់/ផេះ ចេញពីរណ្តៅខួងត្រូវបានផ្តល់ ដោយការដាក់ក្រណាត់សំពត់ ឬសំណាញ់ហ្ជូស្ទីកពណ៌ខ្យៀវ ចាប់យកកករដីនៅការដ្ឋានខួងក្នុងទឹក និង*

មាត់ទឹក។ អាចម៉ីដី ឬផេះចេញពីរណ្តៅខូង និងទុកដាក់ក្នុងកន្លែងមានសុវត្ថិភាព ឬប្រើសំរាប់បំពេញដីទីលានវាយកូនគោល។

- *ការកំណត់សំលេង និង រំញ័រចេញពីម៉ាស៊ីនខូង ដី/ថ្មពិនិត្យមើលភូតគ្ភសាស្ត្រ នឹងត្រូវអនុវត្តន៍ស្រប តាមបទដ្ឋានកំណត់សំរាប់សំលេង និងរំញ័ររបស់ក្រសួងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា។*

៦.២.២ ដំណាក់កាលសាងសង់

ក) ហេតុប៉ះពាល់ទៅលើបរិស្ថានសង្គម

- **ចរាចរណ៍**

ភាពកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍អាចកើតឡើងនៅលើផ្លូវក្នុងតំបន់ដែលពាក់ព័ន្ធ ការដ្ឋានសាងសង់គំរោង ដែលបណ្តាលមកពីការដឹកជញ្ជូនសំភារៈសំណង់ចេញ និងចូលការដ្ឋាន ក្នុងអំឡុងពេលសាងសង់គំរោង។ ចរាចរណ៍យ៉ាងមមាញ្ជឹកពីរថយន្តធំរបស់គំរោងក៏អាច បង្កការខូចខាតដល់ផ្លូវថ្នល់ផងដែរ ជាពិសេស កំណាត់ផ្លូវ២ធ្នូ នៅខាងមុខឆ្នេរហាវ៉ៃ។

➢ *<u>វិធានការកាត់បន្ថយ</u>*

- *ស្លាកសញ្ញាចរាចរណ៍ និងអ្នកសំរួលចរាចរណ៍ (ដូចជាប៉ូលីស) នឹងត្រូវផ្តល់ឱ្យបានគ្រប់គ្រាន់នៅតាមបណ្តោយផ្លូវក្នុងតំបន់គំរោង និងនៅក្នុងផ្លូវចេញចូលរបស់គំរោង។*
- *អប់រំដល់អ្នកបើកបររបស់គំរោង គោរពតាមច្បាប់ចរាចរណ៍ផ្លូវគោករបស់ប្រទេសកម្ពុជា ដូចជាការកំណត់ល្បឿន គោរពភ្លើងសញ្ញា/ស្លាកសញ្ញាចរាចរណ៍ និងបទបញ្ជាផ្សេងៗ។*
- *កែលំអ និងជួសជុលផ្លូវដែលប្រើប្រាស់សំរាប់ជាផ្លូវចេញចូលរបស់គំរោង ជាពិសេសកំណាត់ផ្លូវ២ធ្នូ នៅខាងមុខឆ្នេរហាវ៉ៃ ឱ្យមានលក្ខណៈដូចដើម ឬល្អជាងមុន ដោយក្រុមហ៊ុនវិនិយោគនៅក្នុងដំណាក់កាលសាងសង់នេះ។*

- **សិទ្ធិប្រើប្រាស់ទឹក និងសិទ្ធិទូទៅ**

គំរោង**មរកត**នឹងប្រើប្រាស់ទឹកពីរដ្ឋាការទឹកក្រុងព្រះសីហនុ សំរាប់បំពេញការងារសាងសង់ទាំងអស់ ព្រមទាំងការប្រើប្រាស់ប្រចាំថ្ងៃរបស់បុគ្គលិក/កម្មករទៀតផង។ ដូចនេះ បរិមាណទឹកដែលត្រូវការសំរាប់គំរោងអាចនឹងមានហេតុប៉ះពាល់ដល់ការផ្គត់ផ្គង់ទឹកស្អាតរបស់ក្រុងដែលសមត្ថភាពផ្គត់ផ្គង់សព្វថ្ងៃនៅមានកំរិត និងប៉ះពាល់ដល់ការប្រើប្រាស់របស់ប្រជាពលរដ្ឋដោយដោយសំពាធទឹកខ្សោយ ឬខ្វះខាតទឹកតែម្តង។

ដោយឡែក គំរោងក៏នឹងបង្កហេតុប៉ះពាល់ដល់សកម្មភាពនេសាទរបស់អ្នកនេសាទមួយចំនួនដែលតែងតែធ្វើនេសាទនៅក្បែរតំបន់គំរោង ជាពិសេស ការដ្ឋានសាងសង់ស្ពាន និងជុំវិញកោះពស់ ដោយសារអំឡុងពេលសាងសង់

នឹងត្រូវហាមឃាត់សកម្មភាពនេសាទនៅក្បែរការដ្ឋាន។ ប៉ុន្តែ ហេតុប៉ះពាល់លើសកម្មភាពនេសាទនេះមានកំរិតតិចតួច និងមានរយៈពេលខ្លីទៀតផង ពីព្រោះទីនេះមិនមែនជាតំបន់នេសាទសំខាន់របស់ខេត្តព្រះសីហនុទេ ហើយរយៈពេលដែលអាចធ្វើការនេសាទទីនេះតែ២ខែប៉ុណ្ណោះ (ក្នុងរដូវប្រាំង)។

➢ *<u>វិធានការកាត់បន្ថយ</u>*

- *ក្រុមហ៊ុននឹងប្រើប្រាស់ទឹកពីប្រព័ន្ធទឹកស្អាតរបស់ក្រុង ដោយធ្វើកិច្ចសហការជាមុនជាមួយរដ្ឋាការទឹកក្រុងព្រះសីហនុ ដើម្បីឱ្យអង្គភាពនេះអាចពង្រីកសមត្ថភាពផ្គត់ផ្គង់បានសមស្របតាមតំរូវការប្រើប្រាស់ទូទាំងក្រុង។*
- *ក្រុមហ៊ុនធានាថា ការប្រើប្រាស់ទឹកពីរដ្ឋាការទឹកព្រះសីហនុមិនធ្វើឱ្យប៉ះពាល់ដល់ការប្រើប្រាស់ទឹករបស់អ្នកក្រុងទេ ដោយក្រុមហ៊ុនបានទទួលលិខិតឆ្លើយតបលេខ១៧២ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ (ឧបសម្ព័ន្ធ៥) បានបញ្ជាក់ថាអង្គភាពរដ្ឋាការទឹកក្រុងព្រះសីហនុ មានលទ្ធភាពផ្គត់ផ្គង់ទឹកស្អាតគ្រប់គ្រាន់សំរាប់គំរោងអភិវឌ្ឍន៍នៅលើកោះពស់ និងផ្នែកនៃតំបន់ឆ្នេរហារ៉ៃរបស់ក្រុមហ៊ុនតាមសំណើ និងជែនការតំរូវការទឹក។*
- *ក្រុមហ៊ុននឹងអនុញ្ញាតឱ្យអ្នកនេសាទធ្វើសកម្មភាពនេសាទជុំវិញកោះពស់ក្នុងចំងាយ ១០០ម៉ែត្រពីមាត់ទឹក លើកលែងតែកន្លែងសាងសង់ស្ពាន និងការដ្ឋានសាងសង់ស្ថានីយ៍ចតទូកទេសចរណ៍ ដើម្បីជៀសវាងគ្រោះថ្នាក់បង្កដោយសកម្មភាពសាងសង់។*

- **សុខភាពសាធារណៈ**

គំរោងអាចមានហេតុប៉ះពាល់ទៅលើសុខភាពកម្មករ និងសហគមន៍ ដោយសារសកម្មភាពសាងសង់គំរោង ដូចជាការបញ្ចេញ ខ្សល់ក្ខក់ សំលេងរំខាន និង រំញ័ររចេញពីគ្រឿងចក្រសាងសង់ ម៉ាស៊ីនលាយស៊ីម៉ង់ត៍ ឡាន/រថយន្តធំ ដែលដឹកសំភារៈសាងសង់។ ការគ្រប់គ្រងមិនត្រឹមត្រូវនូវសំណល់ដែលកើតពីសកម្មភាពសាងសង់ និងមនុស្ស (កម្មករ/បុគ្គលិកគំរោង) អាចធ្វើអោយខូចដី បំពុលខ្សល់ បង្កើតភ្នាក់ងារចំលងជំងឺ និងធ្វើអោយប៉ះពាល់ដល់សុខភាពកម្មករ/បុគ្គលិក ប្រជាពលរដ្ឋក្នុងសហគមន៍ ក៏ដូចជាសុខភាពអ្នកទេសចរណ៍ផងដែរ។

ការលេចឬកំពប់ឥន្ធនៈ និងប្រេងរំអិលចេញពីគ្រឿងចក្រសាងសង់ និងការបញ្ចេញទឹកក្រខ្ចក់យ៉ាងច្រើនពីសកម្មភាពសាងសង់ និងជំរុំកម្មករ ចូលទៅក្នុងសមុទ្រ ឬនៅលើឆ្នេរនឹងបង្កឱ្យមានផលប៉ះពាល់ដល់សុខភាពប្រជាជន និងភ្ញៀវទេសចរណ៍ដែលមកកំសាន្ត ឬហែលទឹកលេងនៅទីនេះ។

ម្យ៉ាងវិញទៀតក្រុមហ៊ុននឹងជ្រើសរើសបុគ្គលិកពីខាងក្រៅអោយធ្វើការសំរាប់គំរោង ដូចនេះ អាចធ្វើឱ្យប៉ះពាល់ដល់សុខភាពប្រជាជនមូលដ្ឋាន តាមរយៈការចំលងជំងឺមួយចំនួន ដូចជា អេដស៍ ផ្តាសសាយបក្សី ជំងឺឆ្លងកាចសាហាវដទៃទៀត ការសេពថ្នាំញៀន និងគ្រឿងស្រវឹងផងដែរ ប្រសិនបើបុគ្គលិក/កម្មករគំរោងមានការប្រាស្រ័យទាក់ទងចូលទៅក្នុងសហគមន៍ក្នុងគោលបំណង ផ្សេងៗ រាប់ទាំងស្នេហា និងជួញដូរគ្រឿងញៀន។

➢ *វិធានការកាត់បន្ថយ*

- *ក្រុមហ៊ុននឹងត្រូវអនុវត្តតាមបទដ្ឋានសុវត្ថិភាពការងារ។ ឧបករណ៍ និងបរិក្ខារនឹងត្រូវផ្តល់អោយ (ស្បែកជើងកវែង ស្រោមដៃ មួកការពារ វ៉ែនតាការពារភ្នែក។ល។) ដើម្បីការពារប្រឆាំងនឹងគ្រោះថ្នាក់ផ្សេងៗដល់បុគ្គលិកគំរោងក្នុងអំឡុងពេលការងារ។*
- *អប់រំបុគ្គលិក/កម្មករគំរោង អំពីសុវត្ថិភាពការងារ និងការថែទាំសុខភាពអនាម័យឱ្យបានគ្រប់គ្រាន់ ដើម្បីជៀសវាងប៉ះពាល់ដល់សុខភាពពួកគេ ព្រមទាំងសហគមន៍ជិតខាង។*
- *គំរោងនឹងផ្តល់ទឹកស្អាត និង សាងសង់ជំរុំកម្មករដែលមានបំពាក់បង្គន់អនាម័យសំរាប់បុគ្គលិកកម្មករ ប្រើប្រាស់ និងស្នាក់នៅបានសមរម្យ។ ការផ្តល់ទឹកស្អាត និងបង្គន់អនាម័យនឹងមានទាំងការដ្ឋានសាងសង់ និងជំរុំស្នាក់នៅ។*
- *គ្រប់គ្រងសំណល់រឹងឱ្យបានត្រឹមត្រូវ ទាំងនៅក្នុងការដ្ឋានសាងសង់ និងជំរុំកម្មករ។ ការជីកកប់ក្នុងរណ្តៅ និងការដឹកជញ្ជូនដោយអ្នកម៉ៅការប្រមូលសំរាម និងមានផ្តល់ប្រព័ន្ធអនាម័យ។*
- *ការការពារ និងព្យាបាលនឹងត្រូវបានផ្តល់ឱ្យដោយម្ចាស់គំរោង ឧទា. សេវាថែទាំសុខភាព ថ្នាំពេទ្យ និងគ្រូពេទ្យ/វេជ្ជបណ្ឌិត ដើម្បីពិនិត្យ និងព្យាបាលបុគ្គលិក/កម្មករគំរោង ដើម្បីជៀសវាងការឆ្លងរាលដាលនៃជំងឺនានាទៅដល់ប្រជាជនក្នុងសហគមន៍មូលដ្ឋាន។*
- *សហប្រតិបត្តិការល្អជាមួយស្ថាប័នសុខភាពនៅក្រុងព្រះសីហនុ និងថ្នាក់ជាតិ ដើម្បីការពារជំងឺឆ្លងណាមួយនៅក្នុង និងនៅជុំវិញតំបន់គំរោង។*
- *ក្រុមហ៊ុននឹងធ្វើសហប្រតិបត្តិការជាមួយប៉ូលីស និងអាជ្ញាធរមូលដ្ឋាន ដើម្បីទប់ស្កាត់ការប្រើប្រាស់ថ្នាំញៀន និងចរាចរណ៍ថ្នាំញៀននៅក្នុងតំបន់គំរោង។*

- **ផ្លូវនាវាចរណ៍ និង កំពង់ផែកំពង់សោម**

គំរោងនឹងរំខានទាំងស្រុងដល់ផ្លូវនាវាចរណ៍កាត់តាមឃ្លងធម្មជាតិនៅតំបន់កោះពស់ ចំពោះនាវាគ្រប់ប្រភេទចេញចូលផែកំពង់សោមអំឡុងពេលសាងសង់។ នៅក្នុងពេលសាងសង់ស្ពាន នាវាទាំងអស់រាប់បញ្ចូលទាំងទូកនេសាទផង នឹងមិនអនុញ្ញាតិអោយឆ្លងកាត់ឃ្លងធម្មជាតិនៅពីក្រោមទីតាំងស្ពានទេ។ មានបញ្ហាខ្លះៗចំពោះប្រតិបត្តិការកំពង់ផែ ដោយសារនៅពេលនេះមិនទាន់មានការសាងសង់ផ្លូវឃ្លងវាងថ្មីនៅឡើយ។ ដូចនេះនាំឱ្យថយចុះកិច្ចដំណើរការរបស់កំពង់ផែ ឬប៉ះពាល់ដល់សកម្មភាពដឹកជញ្ជូនតាមកប៉ាល់របស់ផែកំពង់សោម។

➢ *វិធានការកាត់បន្ថយ*

- *ក្រុមហ៊ុននឹងធ្វើសហប្រតិបត្តិការល្អជាមួយអាជ្ញាធរកំពង់ផែកំពង់សោម និងព្យាយាមរកវិធីល្អបំផុតសំរាប់ការស្វែងរកផ្លូវបណ្តោះអាសន្នសំរាប់សកម្មភាពនាវាចរណ៍ ក្នុងដំណាក់កាលសាងសង់។*

- *ជូនដំណឹងឱ្យបានគ្រប់គ្រាន់ដល់អ្នកនេសាទ ភ្នាក់ងារទេសចរណ៍ និងប្រជាជនមូលដ្ឋានឱ្យប្រើប្រាស់ផ្លូវនាវាចរណ៍ផ្សេងទៀតសំរាប់បើកបរទូកបរបស់គេ នៅឆ្ងាយពីការដ្ឋានសាងសង់ស្ពានដើម្បីជៀសវាងគ្រោះថ្នាក់ដែលអាចកើតមានឡើងជាយថាហេតុ ។*
- *មានផ្តល់ស្លាកសញ្ញាសុវត្ថិភាពនៅជុំវិញការដ្ឋានស្ពាន និងមានបណ្តែតពោងបង្ហាញទិសដៅសំរាប់ការធ្វើនាវាចរណ៍វាងការដ្ឋានសាងសង់ទៀតផង ។*
- *សហប្រតិបត្តិការល្អជាមួយអជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធនៅក្នុងក្រុងព្រះសីហនុ ដើម្បីរៀបចំគ្រប់គ្រង និងដោះស្រាយចំពោះបញ្ហាក្នុងការដ្ឋានសាងសង់ ។*

ខ) ហេតុប៉ះពាល់ទៅលើបរិស្ថានធម្មជាតិ

- **ឋានលេខា**

គំរោងនឹងផ្លាស់ប្តូរកំពស់ផ្ទៃដីធម្មជាតិនៅកន្លែងមួយចំនួន ជាពិសេសនៅលើកោះពស់ ដោយសារការឈូសឆាយដី ការជីកកាយដីដើម្បីសាងសង់ផ្លូវ និងអាគារនានានៃសមាសភាពនៃការអភិវឌ្ឍនៅលើកោះពស់ ។

មានការសាងសង់ផ្លូវមេ និងផ្លូវក្រវាត់ព័ទ្ធជុំវិញកោះ ដែលមានទទឹងទំហំ ២៤ម រាប់ទាំងចិញ្ចើមផ្លូវសំរាប់អ្នកថ្មើរជើងផង ។ ក្នុងការរៀបចំសាងសង់បណ្តាញផ្លូវនៅលើកោះពស់នេះ តំរូវឱ្យមានការចាក់បំពេញដី និងការជីកដីឬផ្ទេរចេញ ដើម្បីឱ្យសមស្របតាមបទដ្ឋានបច្ចេកទេសនៃសំណង់ផ្លូវថ្នល់ ។ ដូចនេះ សកម្មភាពសាងសង់ផ្លូវអាចបង្ក ហេតុបះពាល់ដល់ឋានលេខារបស់កោះពស់ ក៏ប៉ុន្តែ ហេតុប៉ះពាល់នេះមិនជាបញ្ហាធំដុំទេ ។

ការបំបែកយកផ្ទាំងថ្មនៅកន្លែងមួយចំនួនដើម្បីរៀបចំគ្រឹះអាគារ និងសំណង់រូបវន្តដទៃទៀតនៅលើកោះពស់ នឹងធ្វើឱ្យផ្លាស់ប្តូរផ្ទៃដីធម្មជាតិផងដែរ ។

➢ *<u>វិធានការកាត់បន្ថយ</u>*

- *ការការពារបរិស្ថានលើការផ្លាស់ប្តូរឋានលេខានៅក្នុងតំបន់គំរោងជាមួយនឹងទិដ្ឋភាពបច្ចេកទេស និងសេដ្ឋកិច្ច សំរាប់ការសាងសង់ផ្លូវនឹងត្រូវអនុវត្ត ។*
- *គំរោងមានផែនការជៀសវាងការបំបែកយកផ្ទាំងថ្មច្រើនពេក ឬការជីកយកដីជ្រៅហួសហេតុ ហើយមានការរៀបចំជាថ្នាក់ៗចំពោះការដ្ឋានសាងសង់មួយចំនួន ដើម្បីកាត់បន្ថយការផ្លាស់ប្តូរឋានលេខានៃដីកោះនេះ ។*

- **សំណឹកដី**

សំណឹកដីអាចកើតឡើងនៅការដ្ឋានផ្នែកចុងទាំងសងខាងនៃស្ពាន ដោយសារការឈូសឆាយដី/ការលើកដី និងការបោសសំអាតរុក្ខជាតិនៅកន្លែងសាងសង់ ។ ម្យ៉ាងវិញទៀត ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានានៅលើកោះពស់ក៏បង្កឱ្យមានសំណឹកដីផងដែរ ជាពិសេសការសាងសង់ បណ្តាញផ្លូវថ្នល់ អាគារធំៗ និងបឹងកាឡូ ពីព្រោះ

សណ្ឋានដីនៅលើកោះពស់មានលក្ខណៈចោទបន្ទិច ហើយលក្ខណៈដីនៅតំបន់គំរោងដែលភាគច្រើនជាដីល្បាយខ្សាច់ ហើយជាងនេះទៀតនោះតំបន់ឆ្នេរមានកំណកបរិយាកាសខ្ពស់ ។ ដោយឡែកការសាងសង់នៅលើឆ្នេរហាវ៉ៃពុំមានបញ្ហាសំណឹកដីនោះទេ ដោយទីតាំងនេះជាវាលរាបស្មើរាបស្មើជាប់ឆ្នេរ ដូចនោះហេតុប៉ះពាល់នឹងអាចកើតមានចំពោះសំណឹកដីនៅកន្លែងធ្លាចំហនឹងកើតមានឡើងនៅដំណាក់កាលសាងសង់លើកោះពស់ និងជើងស្ពានកោះពស់ ហើយហេតុប៉ះពាល់លើសំណឹកដីចំពោះគំរោងមរកតទាំងមូលអាចមានកំរិតមធ្យម បើសិនមានការឈូសឆាយបើកចំហព្រមគ្នាច្រើនការដ្ឋាន ។

➢ *<u>វិធានការកាត់បន្ថយ</u>*

- *ការសំអាតរុក្ខជាតិក្នុងការដ្ឋានសាងសង់នានារបស់គំរោងមរកត នឹងត្រូវកំណត់ទំហំជាអប្បរមាសំរាប់តែទីធ្លាសាងសង់ហេដ្ឋារចនាសម្ព័ន្ធនិមួយៗ ហើយធ្វើឡើងជាដំណាក់ៗតាមបូកនិមួយៗ ។ ជាក់ស្តែងគំរោងបានអនុវត្តផែនការសាងសង់ជាតំណាក់ៗ ដូចជា ការសាងសង់ជើងស្ពានចប់ទើបសាងសង់ផ្លូវលើកោះ បន្ទាប់មកការសាងសង់អាគារមួយបូកម្តងៗ ទាំងនៅលើកោះពស់ និងលើឆ្នេរហាវ៉ៃ ។*
- *ការឈូសឆាយដីនៅក្នុងការដ្ឋានសាងសង់នឹងត្រូវធ្វើតែនៅរដូវប្រាំង ឬគ្មានភ្លៀងធ្លាក់ ដើម្បីកាត់បន្ថយសំណឹកដីពីកន្លែង/ការដ្ឋានសាងសង់ ។*
- *វិធានការ/ការទប់ស្កាត់សំណឹកដីសមស្រប នឹងត្រូវអនុវត្ត ដូចជាការដាំដុះរុក្ខជាតិឡើងវិញភ្លាមៗ ទីបើកចំហបន្ទាប់ពីបញ្ចប់សាងសង់ ការជីកធ្វើជាថ្នាក់ៗដូចកាំជណ្តើដើម្បីបន្ថយចំណោតដី ការរៀបចំជាជញ្ជាំងឥដ្ឋ ឬតម្រៀបថ្មនៅកន្លែងដែល មានដីងាយទទួលរងសំណឹក ។*

- **ហេតុប៉ះពាល់លើធនធានឆ្នេរ**

ដោយសារតំបន់គំរោងស្ថិតនៅក្នុងតំបន់ឆ្នេរនៃឆកក្នុងក្រុងព្រះសីហនុ ដែលគ្របដណ្តប់ដោយឆ្នេរហាវ៉ៃ ឆ្នេរឯកភាជ្យ និងកោះពស់ ដែលមានសក្តានុពលយ៉ាងខ្លាំងសំរាប់ការអភិវឌ្ឍកន្លែងទេសចរណ៍ ។ ដូចនេះសកម្មភាពសាងសង់នៅក្នុងតំបន់ទាំងនេះនឹងអាចបន្ថយនូវតំលៃធនធានមួយចំនួនអាស្រ័យការធ្វើឱ្យក្រខ្វក់ដោយសារគំរោង ហើយនឹងបង្កផលប៉ះពាល់ដល់សកម្មភាពទេសចរណ៍ក្នុងតំបន់ ។

ភាពមិនសប្បាយចិត្តនៃការមើលឃើញហ្វូងមនុស្ស និងសំលេងអូអរកើតចេញពីកម្មករ និងគ្រឿងចក្រសាងសង់នៃការដ្ឋានសំណង់ ជាពិសេសការងារសាងសង់លើឆ្នេរហាវ៉ៃ និងស្ពានកោះពស់អាចនឹងរំខានដល់ភ្ញៀវទេសចរណ៍ដែលមកទស្សនានៅតំបន់ឆ្នេរនេះ ។

ការគ្រប់គ្រងសំណល់រឹងមិនបានត្រឹមត្រូវនៅកន្លែងសាងសង់ ការកំពប់ពាកសំណល់ ជាពិសេសប្រេង និងប្រេងរំអិល និងសារធាតុពុលចូលទៅក្នុងទឹក ឬនៅលើឆ្នេរអាចបង្កគ្រោះថ្នាក់ដល់ធនធានតាមឆ្នេរ ដូចជាធ្វើអោយក្រខ្វក់ឆ្នេរតាមមាត់ច្រាំង និងកន្លែងទឹកភាក់ ។

ទឹកដែលមានកកករ និងកំទេចកំណកខ្ពស់ដែលកើតពីសកម្មភាពសាងសង់ គ្មានការទប់ស្កាត់ ឬត្រួតពិនិត្យដោយគំរោងនឹងធ្វើឱ្យក្រខ្វក់ និងបំផ្លាញដល់ច្រាំងសមុទ្រ និងបាតសមុទ្រដែលមានទឹករាក់នៅក្នុងតំបន់ឆ្នេរនៅក្បែរការដ្ឋានសាងសង់ទាំងនោះ ។

➢ *<u>វិធានការកាត់បន្ថយ</u>*

- *នឹងត្រូវដាក់របងស័ង្កសីកំពស់២ម៉ែត្រយ៉ាងតិច នៅជុំវិញការដ្ឋានសំណង់ ជាពិសេសនៅការដ្ឋានស្ពាន និងការដ្ឋាននៅលើឆ្នេរហាវ៉ៃ ។ គ្រឿងលំអភ្នែក (ផ្ទាំងរូបភាពស្អាតៗ ដូចជារូបទេសភាពរមណីយដ្ឋាន ឬផលិតផលល្អៗ) នឹងត្រូវបំពាក់លើរបងការដ្ឋានផងដែរ បើចាំបាច់ ។*
- *ការទប់ស្កាត់កកករទឹក និងកំទេចកំណអោយបានល្អ ជាតំរូវការចាំបាច់នៅគ្រប់កន្លែងនៃការដ្ឋានសាងសង់នៅក្នុងទឹក និងនៅឆ្នេរសមុទ្រ/មាត់ទឹក ។ ជាឧទាហរណ៍ គេអាចដាក់ក្រណាត់ស្ទាក់ កករដីនៅជុំវិញកន្លែងសាងសង់នៅក្នុងទឹក ហើយសាងសង់ស្រះរងកករនៅកន្លែងសាងសង់នៅក្បែរឆ្នេរសមុទ្រ ឬតាមមាត់ទឹក ។*
- *គ្រប់គ្រងសំណល់ប្រេងម៉ាស៊ីន ឬប្រេងរំអិលដែលចេញពីសកម្មភាពសាងសង់ឱ្យបានត្រឹមត្រូវ ដោយប្រមូលទុកដាក់ក្នុងធុង និងប្រើប្រាស់ឡើងវិញ ឬលក់ឱ្យអ្នកយកទៅប្រើក្នុងបំណងផ្សេងៗ ។ ធ្វើការថែទាំ និងជូសជុលគ្រឿងចក្រដែលបំរើការឱ្យគំរោង មិនឱ្យលេចកំពប់ប្រេង និងខ្លាញ់ទៅលើដី ឬក្នុងទឹក ។*
- *អប់រំដល់កម្មករមិនឱ្យចោលកាកសំណល់ចូលទៅក្នុងប្រភពទឹក ហើយផ្តល់មធ្យោបាយគ្រប់គ្រាន់ដើម្បីគ្រប់គ្រងកាកសំណល់ រួមបញ្ចូលទាំងការសាងសង់បង្គន់អនាម័យនៅក្នុងទីកន្លែងសាងសង់ និង ជំរុំស្នាក់នៅរបស់បុគ្គលិក/កម្មករគំរោង ។*
- *ធ្វើកិច្ចព្រមព្រាងជាមួយក្រុមហ៊ុនផ្តល់សេវាប្រមូលយកសំរាមនៅក្រុងព្រះសីហនុ និងធានាថារាល់កាកសំណល់ទាំងអស់ដែលបានបង្កើតពីមនុស្ស និងពីសកម្មភាពសាងសង់ ត្រូវបានប្រមូល និងយកទៅបោះចោលត្រឹមត្រូវស្របទៅតាមអនុក្រឹត្យនៃការគ្រប់គ្រងសំណល់រឹងរបស់ ក្រសួងបរិស្ថាននៃរាជរដ្ឋាភិបាលកម្ពុជា ។*

- **ហេតុប៉ះពាល់ទៅលើព្រៃឈើ និង សត្វព្រៃ**

ព្រៃឈើនៅលើកោះពស់ ជាទូទៅឃើញមានជាព្រៃបៃតងតំបន់ឆ្នេរដែលភាគច្រើនជាឈើគ្មានចំណាត់ថ្នាក់ ។ ប៉ុន្តែព្រៃឈើនៅទីនេះអាចជាជំរកដ៏ល្អចំពោះសត្វព្រៃនៅលើកោះ និងជួយជាលំនឹងអេកូឡូស៊ីនៃតំបន់កោះពស់ទាំងមូល ។ ការកាប់ព្រៃឈើប្រមាណជា ៤៦ហ.ត ឬ៤៧% នៃទំហំព្រៃឈើសរុបនៅលើកោះដើម្បីសាងសង់ផ្លូវ អាគារ និងហេដ្ឋារចនាសម្ព័ន្ធដទៃទៀតនឹងបង្កផលប៉ះពាល់ដល់ធនធានព្រៃនៅលើកោះ ។ ការបាន់ស្មានព្រៃឈើ ដែលនឹងត្រូវ

បាត់បង់ គឺតំលៃ ១៨៥.៨០០ ដុល្លាអាមេរិក សំរាប់ឈើមូល និង ១.៨០០ ដុល្លាអាមេរិក សំរាប់កំនើនមាឌឈើ ប្រចាំឆ្នាំ ។

ព្រៃឈើនៅលើកោះពស់ គេឃើញវត្តមានពួជបក្សីព្រៃ និងល្ងនមួយចំនួន ។ សត្វពស់ តែងតែជួបជារឿយៗ អំឡុងពេលចុះសិក្សាព្រៃឈើ និងសត្វព្រៃក្នុងតំបន់គំរោង ហើយសត្វស្លាបជាទូទៅបានមកស្នាក់នៅលើកោះពស់នាពេលថ្ងៃ គឺដើម្បីមករកចំណីប៉ុណ្ណោះ ។ ការទន្ទ្រានចូលក្នុងព្រៃឈើលើកោះពីសំណាក់កម្មករសំណង់ដើម្បីចាប់សត្វព្រៃអាចកើតមានឡើង ដូចនេះគំរោងអាចប៉ះពាល់ដល់សត្វព្រៃនៅលើកោះពស់ ប៉ុន្តែហេតុប៉ះពាល់នេះមានតិចតួច ដោយសារលើកោះនេះមានសត្វព្រៃធម្មតាតិចតួចណាស់ ហើយពុំមានប្រភេទកំពុងរងគ្រោះនោះទេ ។

ហេតុប៉ះពាល់ទៅលើព្រៃឈើ និងសត្វព្រៃនៅក្នុងតំបន់គំរោងគឺជាបន្សំនូវការខូចខាតប្រព័ន្ធអេកូឡូស៊ីនៅតំបន់កោះពស់ ប៉ុន្តែហេតុប៉ះពាល់លើព្រៃឈើ និងសត្វព្រៃនៅក្នុងតំបន់នេះក្នុងកំរិតមធ្យមដែលតំរូវឱ្យមានរៀបចំវិធានការឱ្យបានសមស្រប ។

➢ *<u>វិធានការកាត់បន្ថយ</u>*

- *ការកាប់ព្រៃឈើនឹងត្រូវធ្វើឡើងក្នុងដែនកំណត់នៃតំរូវការទីកន្លែងសំរាប់សកម្មភាពសាងសង់របស់គំរោងប៉ុណ្ណោះ ។*
- *ដាំដើមឈើ ឬរុក្ខជាតិដទៃទៀតឡើងវិញនៅបន្ទាប់ពីបញ្ចប់សកម្មភាពសាងសង់ជាក់ស្តែងនៅតាមការដ្ឋាននីមួយៗ ដើម្បីរក្សាលំនឹងអេកូឡូស៊ីនៅលើកោះនិងតំបន់ក្បែរខាង ។*
- *ហាមឃាត់កម្មករសំណង់ដាច់ខាត ពីការទន្ទ្រានចូលព្រៃដើម្បីបរបាញ់សត្វ និងកាប់ព្រៃឈើ ។*
- *ក្រុមហ៊ុនកោះពស់នឹងធ្វើកិច្ចសហការល្អជាមួយខ័ណ្ឌរដ្ឋបាលព្រៃឈើខេត្តព្រះសីហនុ រដ្ឋបាលព្រៃឈើ និងក្រសួងកសិកម្មដើម្បីសុំការអនុញ្ញាតកាប់ដើមឈើលើកោះមួយចំនួនសំរាប់ការដ្ឋានសាងសង់របស់គំរោង ។*
- *ក្រុមហ៊ុនកោះពស់នឹងអនុវត្តតាមកិច្ចសន្យាជួលកោះពស់ក្នុងក្រុងព្រះសីហនុរវាងក្រុមហ៊ុនកោះពស់ជាមួយរាជរដ្ឋាភិបាលកម្ពុជាចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៦ ដែលមានចែងក្នុងកថាខ័ណ្ឌទីបីត្រង់ចំនុន ៣.៣ ថា "ក្នុងការអនុវត្តន៍គំរោង ភាគី(ខ) មានសិទ្ធិកាប់ឆ្ការព្រៃ ដើម្បីអភិវឌ្ឍន៍លើទីតាំងវិនិយោគតាមបម្លង់មេ ។ ដើមឈើទាំងអស់នៅលើទីតាំងវិនិយោគ ដែលត្រូវកាប់សំរាប់គោលបំណងនៃសិទ្ធិប្រើប្រាស់ទីតាំងវិនិយោគ ដែលបានអនុញ្ញាត ហើយប្រសិនបើដើមឈើទាំងនោះមានតំលៃសេដ្ឋកិច្ចនោះ ភាគី(ខ) ត្រូវបង់ចំណូលជូនរដ្ឋស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានទើបមានសិទ្ធិប្រើប្រាស់ ឬលក់ឈើទាំងនោះដោយស្របច្បាប់ ។ ពុំនោះទេ ឈើដែលកាប់រួចហើយត្រូវប្រគល់ជូនរដ្ឋវិញ ។"*

- **ហេតុប៉ះពាល់លើភាវរសក្នុងទឹក/មច្ឆា**

នៅដំណាក់កាលសាងសង់ គំរោងអាចប៉ះពាល់ដល់ជីវិតសត្វក្នុងទឹកដូចជា ទឹក បង្គា ត្រី ត្រីតុកែ និងផ្កាថ្ម ដែលរស់នៅក្នុងតំបន់កោះពស់ ។ ហេតុប៉ះពាល់ដល់ធនធានទាំងនោះបណ្តាលពីការប្រែប្រួលគុណភាពទឹក (ទឹកមានកកម/ភាពល្អក់ខ្ពស់ កាកសំណល់កំពប់ចូលទៅក្នុងទឹក សំលេង និង រំញ័រចេញពីសកម្មភាពសាងសង់) ។

ភាពល្អក់ខ្ពស់នៅក្នុងទឹកនឹងបង្ខាំងដល់ពន្លឺដែលចាំងចូលក្នុងជំរៅទឹក បន្ទាប់មកបង្អាក់ខានដល់ការធ្វើរស្មីសំយោគរបស់មីក្រូសរីរាង្គ (ពពួកបន្លង់តុង អាល់ហ្គាពិណបៃតង។ល។) និងរុក្ខជាតិតូចៗ ដែលធ្វើឱ្យថយចុះនូវផលិតកម្មអុកស៊ីសែន បំផ្លាញកំរិតរលាយអុកស៊ីសែននៅក្នុងទឹក ប្រភេទសត្វក្នុងទឹកមួយចំនួននឹងរត់គេចទៅតំបន់ផ្សេងទៀត ហើយមួយចំនួនទៀតស្លាប់ ឬអសកម្មក្នុងការបង្កកំណើតថ្មី ។

កកកល្អក់ទឹក នឹងបណ្តាលអោយមានកំទេចកំណខ្ពស់នៅក្នុងបាតសមុទ្រ ដែលជាជំរកបស់ស្មៅសមុទ្រ ផ្កាថ្ម និងពពួកត្រីតុកែ ។ ការកំពប់កាកសំណល់ចូលក្នុងទឹក ជាពិសេស ប្រេងឥន្ធនៈ និងប្រេងរំអិល និងកាកសំណល់ គ្រោះថ្នាក់ចេញពីសំភារៈសំណង់ នឹងបង្កហេតុប៉ះពាល់ខ្លាំងចំពោះជីវិតសត្វក្នុងទឹក និងត្រី ។

ជួនកាលការនេសាទខុសច្បាប់ (ការបំផ្ទុះ ឬការប្រើថ្នាំបំពុល) ពីសំណាក់កម្មករសំណង់ក៏បណ្តាលអោយមានហេតុប៉ះពាល់ ឬបំផ្លាញភាវរសក្នុងទឹក និងធនធានមច្ឆានៅក្នុងតំរោងផងដែរ ។ ដោយផ្អែកលើលទ្ធផលសិក្សាជលផល និងផ្កាថ្មក្នុងតំបន់កោះពស់រកឃើញថា មានត្រី ៦៥ប្រភេទ រាប់បញ្ចូលទាំងបង្គាយក្ស និងមីក ហើយមានផ្កាថ្មរីង និងស្តុង ។ ដូចនេះហេតុប៉ះពាល់លើសត្វក្នុងទឹក និងត្រីមានកំរិតមធ្យម ។

➢ *<u>វិធានការកាត់បន្ថយ</u>*

- *ការទប់ស្កាត់កកដី និងកំទេចកំណឱ្យបានល្អគឺជាតំរូវការចាំបាច់នៅគ្រប់កន្លែងនៃការដ្ឋានសាងសង់នៅក្នុងទឹក និងនៅឆ្នេរសមុទ្រ/មាត់ទឹក ។ ជាឧទាហរណ៍ គេអាចដាក់ក្រណាត់ស្ទាក់កកដីនៅជុំវិញកន្លែងសាងសង់នៅក្នុងទឹក ហើយសាងសង់ស្រះរងកកដីនៅកន្លែងសាងសង់នៅឆ្នេរសមុទ្រ ឬតាមមាត់ទឹក ។*
- *គ្រប់គ្រងសំណល់ប្រេងម៉ាស៊ីន ឬប្រេងរំអិលនានាឱ្យបានត្រឹមត្រូវ ដោយប្រមូលទុកដាក់ក្នុងធុង និងប្រើប្រាស់ឡើងវិញ ឬលក់ឱ្យអ្នកយកទៅប្រើក្នុងបំណងផ្សេងៗ ។ ថែទាំ និងជួសជុលគ្រឿង ចក្រ និងយានយន្តរបស់គំរោងមិនឱ្យលេចកំពប់ប្រេង/ខ្លាញ់លើដី ឬក្នុងទឹក ។*
- *អប់រំដល់កម្មករមិនឱ្យចោលកាកសំណល់ចូលទៅក្នុងប្រភពទឹក លើយផ្តល់មធ្យោបាយគ្រប់គ្រាន់ដើម្បីគ្រប់គ្រងកាកសំណល់ រួមបញ្ចូលទាំងសាងសង់បង្គន់អនាម័យនៅក្នុងទឹកន្លែងសាងសង់ និងជុំវិញ្ចាក់នៅ ។ ក្រុមហ៊ុនធានាថា រាល់កាកសំណល់ទាំងអស់ដែលបានបង្កើតពីមនុស្ស និងពីសកម្មភាពសាងសង់នឹងត្រូវបានប្រមូល និងយកទៅចោះចោលត្រឹមត្រូវស្របទៅតាមអនុក្រឹត្យនៃការគ្រប់គ្រងសំណល់រឹង របស់ក្រសួងបរិស្ថាននៃរាជរដ្ឋាភិបាលកម្ពុជា ។*

- *ហាមឃាត់ដាច់ខាតចំពោះកម្មករសំណង់ មិនឱ្យធ្វើនេសាទខុសច្បាប់ ហើយក្រុមហ៊ុនធ្វើកិច្ចសហការជាមួយខ័ណ្ឌរដ្ឋបាលជលផលខេត្តព្រះសីហនុ ដើម្បីធ្វើអធិការកិច្ច និងទប់ស្កាត់សកម្មភាពនេសាទខុសច្បាប់នៅក្នុងតំបន់គំរោង ។*

- **ទេសភាព**

ក្នុងអំឡុងពេលសាងសង់លើកោះពស់ និងឆ្នេរបាវ៉ៃនឹងមានហេតុប៉ះពាល់ដល់ទេសភាពនៅក្នុងតំបន់ដោយសារភាពផ្លាស់ប្តូរហ៊ានលេខាដោយការឈូសឆាយដី កាយបើកចំហផ្ទៃដី កាប់សំអាតរុក្ខជាតិ និងការដាក់ឧបករណ៍ សំភារៈ គ្រឿងចក្រស្អេកស្ពុះ ។

ការបុកសរសរគ្រឹះ និងសកម្មភាពសាងសង់ដទៃទៀតនៅការដ្ឋានសាងសង់ស្ពាន នឹងបង្កឱ្យមានភាពមិនស្រស់ស្រាយនៅតំបន់កោះពស់ ។ ប៉ុន្តែ ហេតុប៉ះពាល់លើទេសភាពដោយសារសកម្មភាពសាងសង់នេះមានកំរិតតិចតួចដោយសារការសាងសង់ផ្ទៃកដែលបែរមកដីគោកមានរយៈពេលមិនយូរទេ ក្រៅពីនេះទីតាំងដទៃទៀតមានការចាំងដោយព្រៃឈើ និងសណ្ឋានដីកោះ ។

➢ *<u>វិធានការកាត់បន្ថយ</u>*

- *ក្រុមហ៊ុននឹងរៀបចំផែនការឱ្យបានល្អសំរាប់ការកាប់សំអាតរុក្ខជាតិសំរាប់ការដ្ឋានសាងសង់ចាំបាច់ ឧទាហរណ៍ការដ្ឋានសាងសង់នៅលើកោះពស់នឹងត្រូវធ្វើជាបួកៗ គឺមិនបើកចំហការដ្ឋានសាងសង់នៅពេលតែមួយរួមគ្នានោះទេ ។*
- *ការដាំដុះរុក្ខជាតិឡើងវិញ នៅកន្លែងដែលបានបញ្ចប់ការងារសំណង់ស៊ីវិល ដើម្បីរក្សាតំបន់ទាំងមូលឱ្យមានភាពបែតងដូចស្ថានភាពដើម ។*
- *គ្រឿងតែងលំអ (ផ្ទាំងរូបភាពស្អាតៗ ដូចជារូបទេសភាព រមណីយដ្ឋាន ឬផលិតផលល្អៗ) នៅបរិវេណការដ្ឋានសាងសង់ឆ្នេរបាវ៉ៃ និងការដ្ឋានដទៃទៀតនឹងត្រូវបានផ្តល់ឱ្យក្នុងអំឡុងពេលសាងសង់ ដោយក្រុមហ៊ុនវិនិយោគគំរោង ។*

គ) ហេតុប៉ះពាល់អាយុសារជាតិពុល

- **ការបំពុលខ្យល់**

ផ្សែងបំភាយចេញពីគ្រឿងចក្រសាងសង់ ម៉ាស៊ីនភ្លើងរបស់គំរោង រោងចក្រលាយបេតុង ឡានធំៗ និងការដឹកជញ្ជូនសំភារៈសំណង់សំរាប់គំរោង នឹងបំពុលដល់ខ្យល់បរិយាកាសនៅក្នុងតំបន់គំរោង ។ ការភាយចេញពីម៉ាស៊ីនសាងសង់រួមទាំងធូលី/ភាគល្អិតអណ្តែត ខ្យល់ក្រ$_2$ក់ (NO_2, SO_2, CO) និងផ្សែងចេញពីការបំផ្ទុះថ្មនៅការដ្ឋានសាងសង់ ស្ពាន ឆ្នេរបាវ៉ៃ និងលើកោះពស់ក៏ធ្វើឱ្យប៉ះពាល់ដល់គុណភាពខ្យល់ផងដែរ ។

ខ្យល់កខ្វក់អាចប៉ះពាល់ផងដែរដល់សុខភាពភ្ញៀវទេសចរណ៍នៅក្នុងតំបន់ ជាពិសេសភ្ញៀវទេសចរណ៍ដែលមកកំសាន្ត និងសំរាកលំហែនៅឆ្នេរលំហែកាយ ឆ្នេរឯករាជ្យ និងឆ្នេរហាវ៉ៃ ។

➢ *<u>វិធានការកាត់បន្ថយ</u>*

- *ក្រុមហ៊ុននឹងប្រើប្រាស់ថាមពលអគ្គិសនីពីបណ្តាញអគ្គិសនីកម្ពុជាសាខាក្រុងព្រះសីហនុ សូមមើលឧបសម្ព័ន្ធទី៥ លិខិតលេខ ០៨៩៨ របស់អគ្គិសនីកម្ពុជា ចុះថ្ងៃទី ២៤ ខែកម្ភៈ ឆ្នាំ២០០៩ ស្តីពីការតភ្ជាប់ថាមពលអគ្គិសនីពីបណ្តាញអគ្គិសនីកម្ពុជាសាខាក្រុងព្រះសីហនុទៅកោះពស់ ។ ម៉ាស៊ីនភ្លើងរបស់គំរោងប្រើសំរាប់តែពេលភ្លើងរដ្ឋដាច់ប៉ុណ្ណោះ ។*
- *ម៉ាស៊ីនសាងសង់ដែលមានគុណភាពល្អ និងឡានដឹក ឬរថយន្តធំៗរបស់គំរោង ដែលមានផ្ទៃរង និងសំលេងតិចបំផុត នឹងត្រូវបានប្រើប្រាស់ ដើម្បីការពារគុណភាពខ្យល់នៅក្នុងតំបន់គំរោងនៅអំឡុងដំណាក់កាលសាងសង់ ។*
- *ការគ្របសំភារៈសាងសង់ (ស៊ីម៉ង់ត៍ ត្រួស ខ្សាច់ ។ល។) នៅពេលដឹកជញ្ជូនចូលទៅការដ្ឋានសាងសង់ ។ ស្រោចទឹក លើគំនរត្រួស ឬខ្សាច់ នៅរដូវប្រាំង ។ ត្រូវដាក់ក្រណាត់លើម សំរាប់ចាប់ធូលីនៅកន្លែងបញ្ចេញធូលី ពីម៉ាស៊ីនលាយស៊ីម៉ង់ត៍ ។*
- *ក្រុមហ៊ុននឹងប្រើប្រាស់ត្រឿងផ្ទុះ និងបច្ចេកទេសត្រឹមត្រូវ ដូចនេះមិនមានការបំពុលខ្ពស់ចូលទៅក្នុងខ្យល់បរិយាកាសឡើយ ។*

- **គុណភាពទឹក**

គុណភាពទឹកនៅក្នុងតំបន់គំរោង ជាពិសេស នៅការដ្ឋានស្ពានកោះពស់ ឆ្នេរហាវ៉ៃ និងនៅជុំវិញកោះពស់ នឹងត្រូវថមថយគុណភាព ដោយសារសកម្មភាពសាងសង់ ដូចជាការឈូសឆាយដី ការខួង ការបុកសសរគ្រឹះ ការសង់គ្រឹះស្ពាន ការចោលកាកសំណល់ ការកំពប់ឥន្ធនៈ និងប្រេងរំអិលពីម៉ាស៊ីនគ្រឿងចក្រសាងសង់ចូលទៅលើឆ្នេរសមុទ្រ/ក្នុងទឹកសមុទ្រ ឬនៅតាមកន្លែងទំនេរនានាក្បែរនោះ ។ ជួនកាលការបង្ហូរទឹកក្រខ្វក់ដ៏ច្រើនពីសកម្មភាពសាងសង់ និងជំរុំកម្មករចូលទៅក្នុងប្រភពទឹក និងដីទំនេរអាចកើតមានឡើងផងដែរ ។

នៅលើកោះ មិនមានសហគមន៍នៅក្បែរទីនោះទេ ប៉ុន្តែនៅខាងការដ្ឋានដីគោកដែលនៅជាប់ឆ្នេរហាវ៉ៃ និងឆ្នេរឯករាជ្យ ដែលជាកន្លែងទេសចរណ៍ ការសាងសង់គំរោងនឹងបង្កផលប៉ះពាល់ដល់កន្លែងទេសចរណ៍ខាងលើ ដោយសារកករលួកនៅក្នុងទឹក ។ ផលប៉ះពាល់សុខភាពដល់អ្នកហែលទឹក/អ្នកលេងទឹក និងប៉ះពាល់ដល់សោភណ្ឌភាពដែលបណ្តាលពីគុណភាពទឹកមិនស្អាតនៅតំបន់ឆ្នេរ ។

គុណភាពមិនល្អ (មានភាពល្អក់ខ្ពស់ និងកករច្រើន មានសំរាម និងប្រេងអណ្តែត) នឹងប៉ះពាល់យ៉ាងខ្លាំងដល់ជីវិតសត្វ និងរុក្ខជាតិរស់នៅក្នុងទឹកនៅតំបន់ឆ្នេរនេះ និងអ្នកទេសចរណ៍ជាតិនិងអន្តរជាតិដែលមកកំសាន្តនៅ

តំបន់ឆ្នេរនេះ។ ស្មៅសមុទ្រ និងផ្កាថ្មកាន់តែងាយទទួលរងផលប៉ះពាល់ដោយសារភាពល្អក់។ ភាពល្អក់ខ្ពស់ និងកាកសំណល់ដែលអណ្តែត ដូចជាភក់ដែលបានពីការខួង និងភាពល្អិតដែលអណ្តែត/ល្បប់ បណ្តាលឱ្យអុកស៊ីសែនរលាយក្នុងទឹកមានកំរិតទាប។ ប៉ុន្តែ ការសាងសង់មានរយៈពេលខ្លី ដូចនេះហេតុប៉ះពាល់នឹងអាចកើតមានកំរិតមធ្យម ហើយការធ្វើឱ្យប្រសើរឡើងវិញតាមបែបធម្មជាតិនៃសមុទ្រ ពិតជាអាចជួយសំអាតបាន។

➢ *<u>វិធានការកាត់បន្ថយ</u>*

- *ការលូសរនាយដីនៅលើដីពោកគួរធ្វើឡើងនៅរដូវប្រាំងដើម្បីកាត់បន្ថយសំណឹកដី និងកាកសំណល់ហូរចូលក្នុងសមុទ្រ។ វិធានការ/ការទប់ស្កាត់ករណីក និងសំណឹកដីត្រឹមត្រូវនឹងត្រូវផ្តល់ (ដាក់ក្រណាត់ព័ទ្ធជុំវិញ កន្លែងសាងសង់នៅក្នុងទឹក) នៅកន្លែងការដ្ឋានជាក់ស្តែង ដើម្បីជៀសវាងការហូរសាយចេញកករដីពីកន្លែងសាងសង់នៅអំឡុងពេលសាងសង់ ។*
- *ក្រុមហ៊ុនអនុវត្តគំរោង នឹងអប់រំបុគ្គលិក/កម្មករមិនឱ្យចោះចោលសំរាម/កាកសំណល់ចូលទៅក្នុងប្រភពទឹក លើយផ្តល់សំភារៈគ្រប់គ្រងកាកសំណល់រាប់ទាំងសាងសង់បម្ពង់អនាម័យឱ្យបានគ្រប់គ្រាន់នៅការដ្ឋានសំណង់ និងនៅជុំវិញ្ជាក់នៅរបស់បុគ្គលិក/កម្មករ ។*
- *គ្រប់គ្រងសំណល់ប្រេងម៉ាស៊ីន និងប្រេងរំអិលឱ្យបានត្រឹមត្រូវដោយប្រមូលទុកដាក់ក្នុងធុង និងប្រើប្រាស់ឡើងវិញ ឬលក់ឱ្យអ្នកយកទៅប្រើក្នុងបំណងផ្សេងៗ។ ថែទាំ និងជួសជុលគ្រឿងចក្រគំរោងមិនឱ្យលេចកំពប់ប្រេង និងខ្លាញ់លើដី ឬក្នុងទឹក ។*
- *ការត្រួតពិនិត្យគុណភាពទឹកនៅជុំវិញការដ្ឋានគំរោង នឹងត្រូវអនុវត្តឱ្យបានទៀងទាត់ ដើម្បីធានាថាគុណភាពរបស់ទឹកនៅពេលសាងសង់មិនមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ជីវិតសត្ត និងរុក្ខជាតិក្នុងទឹក (ត្រី ផ្កាថ្ម ។ល។) និងមនុស្សម្នា ដែលបែល/ លេងនៅតំបន់ជុំវិញ្ជកោះពស់ កន្លែងសាងសង់ស្ពាន និង នៅតំបន់ឆ្នេរបាវ៉ៃ។ ប៉ារ៉ាម៉ែត្រសំខាន់ៗសំរាប់ត្រួតពិនិត្យគុណភាពទឹកគឺ TSS, DO, BOD_5, Total N, Total P, Cd, Hg, and Pb ។*

- **កាកសំណល់**

សំណល់រឹងដូចជា កាកសំណល់នៃសំភារៈសាងសង់ សំណល់ផ្ទះបាយ និងសំណល់ចេញពីមនុស្សអាចកើតមានឡើងនៅការដ្ឋានសាងសង់ និងជុំវិញ្ជាក់នៅរបស់បុគ្គលិក/កម្មករគំរោង ។

កាកសំណល់ពីការដ្ឋានសាងសង់ ដូចជា កំទេចកំទីនៃ សំភារៈសំណង់ (ក្រដាស ជ័រ ឈើ ដែក អាចម៍ដី ។ល។) និងសំណល់ប្រេងឥន្ធនៈ ប្រេងរំអិលឬខ្លាញ់ពីគ្រឿងចក្រសាងសង់ ជាតិពុលនានាពីសំភារៈសាងសង់ ។ សំណល់ចេញពីបុគ្គលិកកម្មករ និងផ្ទះបាយគំរោង ដូចជា សំណល់បន្លែ ឆ្អឹងត្រី ឆ្អឹងសត្ត ថង់ប្លាស្ទិក/ស្បោង សំណល់អាហារ រីឯសំណល់ចេញពីបុគ្គលិក.កម្មករគំរោងមានដូចជា លាមក និងទឹកនោម ។

ការគ្រប់គ្រងកាកសំណល់ក្នុងការដ្ឋានសាងសង់ និងក្នុងជំរុំស្នាក់នៅរបស់បុគ្គលិក/កម្មករមិនបានល្អ នឹងបង្ក ឱ្យមានបញ្ហាជាច្រើនដល់ធនធានបរិស្ថាន និងសង្គមក្នុងតំបន់គំរោង។ បញ្ហាទីមួយគឺ ធ្វើឱ្យខូចសោភ័ណ្ឌភាព បញ្ហាទីពីរ គឺបំពុលដល់គុណភាពដី គុណភាពខ្យល់ និងគុណភាពទឹក បញ្ហាទីបីគឺបង្កើតជំរក និងសត្វចង្រៃចំលងរោគ ដូចជា ម្ជុស រ៉ុយ ហើយបញ្ហាចុងក្រោយគឺ ប៉ះពាល់ដល់សុខភាពសត្វក្នុងទឹក សត្វពាហនៈនានា និងសុខភាពមនុស្ស នៅក្នុងតំបន់គំរោង និងតំបន់ជិតខាង។

➢ *<u>វិធានការបន្ធូរបន្ថយ</u>*

- *ក្រុមហ៊ុននឹងអប់រំកម្មករមិនឱ្យចោះចោលកាកសំណល់ទៅក្នុងខ្សែទឹក និងផ្តល់ឱ្យនូវសេវាកម្មគ្រប់គ្រងសំរាមរួមទាំងបង្គន់អនាម័យក្នុងទីតាំងការដ្ឋានសាងសង់ និងក្នុងជំរុំបុគ្គលិក/កម្មករ។ ក្រុមហ៊ុនកោះពស់នឹងធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុនប្រមូលសំរាមនៅក្នុងក្រុងព្រះសីហនុ ដើម្បីប្រមូល និងដឹកយកកាកសំណល់ទាំងអស់ដែលចេញពីមនុស្ស និងពីសកម្មភាពសាងសង់ទៅចោះចោល ដោយផ្អែកទៅតាមបទបញ្ជា ឬក៏គោលការណ៍ណែនាំអំពីការគ្រប់គ្រងកាកសំណល់រឹងរបស់ប្រទេសកម្ពុជា។ ជាក់ស្តែងក្រុមហ៊ុនកោះពស់មានកិច្ចសន្យាជាមួយក្រុមហ៊ុន CINTRI សាខាក្រុងព្រះសីហនុ ដើម្បីប្រមូលសំរាមការិយាល័យ និងសំរាមផ្ទះបាយយកទៅចោះចោល សូមមើល ឧបសម្ព័ន្ធទី៥។*
- *ក្រុមហ៊ុននឹងសាងសង់ស្រះរងកកក ដែលមានតួនាទីសំអាតបឋមនៃទឹកដែលប្រើប្រាស់ចេញពីការដ្ឋានសាងសង់ និងជំរុំស្នាក់នៅរបស់បុគ្គលិក/កម្មករ។ សំភារៈសំលាប់មេរោគ ដូចជា មេរ៉ាកំពេរ១ និងក្លរីនឹងត្រូវបានប្រើដើម្បីសំអាតទឹកក្នុងស្រះរងកកក ក្នុងករណីបើចាំបាច់។*
- *គ្រប់គ្រងសំណល់សំភារៈសំណង់ឱ្យបានត្រឹមត្រូវ ដូចជា ឈើ ដែក ក្រដាស និងស្បោងប្លាស្ទិក ព្រមទាំងសំណល់ប្រេង និងប្រេងរំអិលចេញពីគ្រឿងចក្រសាងសង់ ដោយប្រមូលទុកក្នុងធុងដើម្បីប្រើប្រាស់ឡើងវិញ ឬលក់ឱ្យអ្នកប្រើប្រាស់ផ្សេងទៀត។*

- **ការរំខានដោយសំលេង និងរំញ័រ**

សំលេង និងរំញ័រដែលកើតចេញពីគ្រឿងចក្រសាងសង់ ជាពិសេស ការបុកសសរគ្រឹះ រថយន្តធំ១/យានយន្ត ប្រើសំរាប់ដឹកជញ្ជូនសំភារៈសំណង់នឹងកើតមានឡើងនៅក្នុង និងនៅជុំវិញការដ្ឋានសាងសង់។ សំលេង និងរំញ័រនៅការដ្ឋានសាងសង់ស្ពានកោះពស់ និងឆ្នេរហាវ៉ៃ គឺចាត់ជាប្រភពបំពុលសហគមន៍នៅទីនេះ។ ប៉ុន្តែ ដោយសារទីតាំងគំរោងពុំមានលំនៅដ្ឋានអ្នកស្រុក ហើយការសាងសង់គ្រឹះមានរយៈពេលខ្លី នោះហេតុប៉ះពាល់ដោយសារសំលេង និងរំញ័រមិនជាបញ្ហាធំដុំនោះទេ។

តាមពិតទៅសកម្មភាពសាងសង់នៅលើកោះពស់នឹងមានបង្កើតចេញនូវសំលេង និងរំញ័រមួយចំនួន ក៏ប៉ុន្តែ កោះនេះស្ថិតនៅឆ្ងាយពីដីកោគ ហើយក៏គ្មានលំនៅដ្ឋាននៅលើកោះទេ ដូចនេះមានតែសត្វព្រៃនៅលើកោះពស់

ប៉ុណ្ណោះដែលនឹងរងហេតុប៉ះពាល់ដោយសារសំលេង និងរំញ័រ។ ទន្ទឹមនឹងនេះព្រៃឈើនៅលើកោះអាចកាត់បន្ថយសំលេងរំខានភាគច្រើនផងដែរ ដូច្នេះហេតុប៉ះពាល់ដោយសារសំលេង និងរំញ័រនៅលើកោះមិនជាបញ្ហាធំដុំនោះទេ។

➢ *<u>វិធានការកាត់បន្ថយ</u>*

- *ទោះបីគំរោងនឹងបង្ករហេតុប៉ះពាល់តិចតួចដោយសារសំលេង និងរំញ័រក៏ដោយ ក៏ក្រុមហ៊ុនកោះពស់នឹងប្រើប្រាស់គ្រឿងចក្រ និងរថយន្តធំ១/យានយន្តគំរោងទាំងអស់ ដែលមានគុណភាពល្អ បញ្ចេញសំលេង និងរំញ័រតិច។*
- *ក្រុមហ៊ុននឹងផ្តល់ឧបករណ៍ និងសំភារៈ ដូចជា កាស់ពាក់នៅត្រចៀកការពារសំលេង ជូនដល់បុគ្គលិកកម្មករគំរោងនៅការដ្ឋានធ្វើការដែលមានសំលេងខ្លាំង។*
- *រាល់សកម្មភាពសាងសង់ទាំងអស់របស់គំរោងមរកត នឹងត្រូវអនុវត្តនៅក្នុងរយៈពេលម៉ោងធ្វើការពេលថ្ងៃ (៧:៣០-១១:៣០ និង ១៣:៣០-១៧:៣០) និងគោរពតាមកំរិតកំណត់សំលេងក្នុងតំបន់សាធារណៈ ដូចមានចែងក្នុងឧបសម្ព័ន្ធទី៦នៃអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង។*

៦.២.៣ ដំណាក់កាលប្រតិបត្តិ

ក) ហេតុប៉ះពាល់លើបរិស្ថានសង្គម

- **ចរាចរណ៍**

ការកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍អាចកើតឡើងនៅលើផ្លូវដែលពាក់ព័ន្ធទៅនឹងកិច្ចដំណើរការគំរោងមរកត ជាពិសេស ផ្លូវពីរធ្ន និងស្ពានកោះពស់ ដោយការកើនឡើងនូវរថយន្ត ឡានធំ ម៉ូតូ និងទោចក្រយានដែលចរាចរណ៍លើផ្លូវក្នុងតំបន់គំរោង។ ជួនកាលគ្រោះថ្នាក់ចរាចរណ៍អាចកើតឡើងនៅលើស្ពានផងដែរ ដោយសារការធ្វេសប្រហែសរបស់អ្នកបើកបរ ឬអ្នកប្រើប្រាស់ផ្លូវ/ស្ពាន។

➢ *<u>វិធានការកាត់បន្ថយ</u>*

- *ក្រុមហ៊ុននឹងបំពាក់ភ្លើងចរាចរណ៍ ស្លាកសញ្ញាចរាចរណ៍ និង ភ្លើងបំភ្លឺនៅតាមបណ្តោយស្ពានទាំងសងខាង ខាងក្រោមស្ពាន ដូចមានចែងក្នុងកិច្ចសន្យាបន្ថែមរវាងក្រុមហ៊ុនកោះពស់ ជាមួយរាជរដ្ឋាភិបាលកម្ពុជា។*
- *ក្រុមហ៊ុនកោះពស់នឹងធ្វើសហប្រតិបត្តិការជាមួយមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះសីហនុ ដើម្បីបំពាក់ភ្លើងបំភ្លឺ និងស្លាកសញ្ញាចរាចរណ៍លើផ្លូវពីរធ្ន។*

- *ក្រុមហ៊ុនកោះពស់នឹងធ្វើសហប្រតិបត្តិការជាមួយភ្នាក់ងារប៉ូលីសក្នុងក្រុងព្រះសីហនុ ដើម្បីផ្តល់ប៉ូលីសចរាចរណ៍ ដើម្បីប្រចាំការលើច្រកចូលស្ពាន និងកន្លែងប្រសព្វគ្នានៃផ្លូវសំខាន់ៗនៅក្នុងតំបន់គំរោង ។*

- **សិទ្ធិប្រើប្រាស់ទឹក និងសិទ្ធិទូទៅ**

ទ្វីតាតំបន់កោះពស់មិនមែនជាតំបន់នេសាទសំខាន់នៃក្រុងព្រះសីហនុ ប៉ុន្តែមានគ្រួសារអ្នកនេសាទប្រហែល ៥០គ្រួសារ ដែលតែងតែធ្វើនេសាទនៅទីនេះជារៀងរាល់ឆ្នាំ ជាពិសេសនៅរដូវប្រាំង (រយៈពេល២ខែក្នុងមួយឆ្នាំ) ហើយមានពីរបីគ្រួសារធ្វើនេសាទទីនេះពេញមួយឆ្នាំ។ ក្រៅពីការបង្ហាញខាងលើ មានសកម្មភាពនេសាទបែបទេសចរណ៍នៅខាងមុខឆ្នេរហាវ៉ៃ និងនៅក្បែរច្រាំងជុំវិញកោះពស់ផងដែរ ។

គំរោងនឹងមានហេតុប៉ះពាល់ដល់សកម្មភាពនេសាទរបស់អ្នកនេសាទមួយចំនួនដែលធ្វើនេសាទនៅក្បែរតំបន់កោះពស់ និងនៅខាងមុខឆ្នេរហាវ៉ៃ បើសិនគំរោងនឹងហាមឃាត់សកម្មភាពនេសាទបែបគ្រួសារនៅទីនេះ។ ព្រោះថានៅពេលគំរោងដាក់ឱ្យដំណើរការនោះ សកម្មភាពនេសាទបែបគ្រួសារប្រមាណជា៥0% (២៥ គ្រួសារ) ដែលធ្លាប់កមធ្វើនេសាទនៅក្បែរកោះពស់នេះនឹងត្រូវកាត់បង់ដោយសារ ការកំណត់ដែននេសាទនៅតំបន់កោះពស់ ហើយនឹងប៉ះពាល់ដល់ចំណូលអ្នកនេសាទ ឬគ្រួសារនេសាទប្រមាណជា ៥៣.000 ដុល្លាសហរដ្ឋអាមេរិកក្នុងមួយឆ្នាំ ។

ផ្អែកតាមការសិក្សាលើជលផលក្នុងតំបន់គំរោងក្នុងខែមិថុនា ឆ្នាំ២00៩ ដល់ ខែកម្ភៈ ឆ្នាំ២0១0 បង្ហាញឱ្យឃើញថា:-

- ចំណូលប្រចាំថ្ងៃរបស់គ្រួសារដែលមានទូកនេសាទគឺ ១៥0.000 រៀល ឬ ៣៥ ដុល្លាសហរដ្ឋអាមេរិក (អត្រាប្តូរប្រាក់គឺ ៤២00រៀល/១ដុល្លា)
- គ្រួសារអ្នកនេសាទដែលតែងតែធ្វើនេសាទនៅតំបន់កោះពស់មានចំនួនសរុប ៥0គ្រួសារ
- រយៈពេលដែលធ្វើការនេសាទនៅតំបន់កោះពស់គឺ ២ខែ ឬ ៦0ថ្ងៃប៉ុណ្ណោះ ក្នុងមួយឆ្នាំ ។

ដូចនេះ ហេតុប៉ះពាល់លើសកម្មភាពនេសាទនេះមានកំរិតតិចតួច និងមានរយៈពេលខ្លីទៀតផង ពីព្រោះទីនេះមិនមែនជាតំបន់នេសាទសំខាន់របស់ខេត្តព្រះសីហនុទេ ហើយរយៈពេលដែលអាចធ្វើការនេសាទទីនេះតែ ២ខែប៉ុណ្ណោះ (ក្នុងរដូវប្រាំង) ។ ម្យ៉ាងវិញទៀតពួកគេអាចទៅរកកន្លែងនេសាទផ្សេងទៀតក្នុងសមុទ្រខ្មែរ ដូចជានៅកោះរុង កោះតាង និងតាក្យៀវជាដើម ។

អ្វីដែលប៉ះពាល់លើសិទ្ធិទូទៅដោយសារគំរោងនេះគឺ ការបាត់បង់ឆ្នេរកំសាន្តជាសាធារណៈ និងការខ្វះខាតទឹកស្អាតប្រើប្រាស់របស់អ្នកក្រុងព្រះសីហនុ។ ព្រោះថា តំរូវការទឹក យ៉ាងច្រើនសំរាប់កិច្ចប្រតិបត្តិ ការហេដ្ឋារចនាសម្ព័ន្ធ នៅលើកោះ និងលើឆ្នេរហាវ៉ៃ នេះអាចប៉ះពាល់ដល់បរិមាណទឹក ប្រើរបស់អ្នកក្រុងព្រះសីហនុយ៉ាងខ្លាំង ។ ម្យ៉ាងវិញទៀត គំរោងនឹងប៉ះពាល់ដោយការបាត់បង់ឆ្នេរសាធារណៈរបស់ប្រជាពលរដ្ឋទូទៅ ដែលពួកគាត់តែងតែទៅលេងកំសាន្តនៅឆ្នេរហាវ៉ៃ និងឆ្នេរកោះពស់ បើគំរោងហាមឃាត់មិនឱ្យចូលក្រៅពីភ្ញៀវរបស់ខ្លួន ដូចជាករណីឆ្នេរសុខានោះ ។

➢ *<u>វិធានការកាត់បន្ថយ</u>*

- *ក្រុមហ៊ុនកោះពស់នឹងអនុញ្ញាតឱ្យអ្នកនេសាទធ្វើសកម្មភាពនេសាទនៅតំបន់កោះពស់ក្នុងចំងាយ កំណត់ច្បាស់លាស់ពីមាត់ឆ្នេរនៃកោះ ដោយមានដាក់បណ្តែតពោងសញ្ញាដែនកំណត់ជុំវិញកោះ ។*
- *ក្រុមហ៊ុននឹងអនុញ្ញាតឱ្យអ្នកនេសាទធ្វើសកម្មភាពនេសាទជុំវិញកោះពស់ក្នុងចំងាយ ១00ម៉ែត្រ ពីមាត់ទឹក ដើម្បីថែរក្សាភាពស្រស់ស្អាត និងសុវត្ថិភាពដល់ប្រជាជាន និងភ្ញៀវដែលរស់នៅលើកោះ ។*
- *ក្រុមហ៊ុននឹងផ្តល់អាទិភាពជ្រើសរើសក្រុសារអ្នកនេសាទដែលនឹងរងផលប៉ះពាល់ឱ្យចូលធ្វើការជាបុគ្គលិក/កម្មករបស់គំរោងទេ អំឡុងពេលប្រតិបត្តិគំរោង ។*
- *ក្រុមហ៊ុននឹងអនុញ្ញាតឱ្យប្រជាពលរដ្ឋចូលលេងកំសាន្តលើឆ្នេរហាវ៉ៃតាមធម្មតា និងអនុញ្ញាតឱ្យចូលទៅលេងលើកោះពស់និងឆ្នេរកោះពស់ក្នុងកំរិតកំណត់ដោយដឹកជញ្ជូនតាមឡានប្រើអគ្គិសនីពីតល់ស្ពានខាងដីពោកដើម្បីធានាបានទាំងសុវត្ថិភាព និងភាពស្អាតដល់ឆ្នេរនិងបរិស្ថានលើកោះទាំងមូល ។*

- **ហេតុប៉ះពាល់លើសុខភាពសាធារណៈ**

ក្នុងដំណាក់កាលប្រតិបត្តិគំរោងបញ្ហាដែលប៉ះពាល់ដល់សុខភាពសាធារណៈសំខាន់គឺដោយសារសំណល់រឹង និងទឹកក្រខ្វក់ដែលកើតចេញពីសកម្មភាពគំរោង ។ ការគ្រប់គ្រងសំណល់រឹងមិនបានត្រឹមត្រូវនៅលើកោះពស់ និងនៅឆ្នេរហាវ៉ៃ នឹងបង្កឱ្យមានក្លិនស្អុយ ក្រខ្វក់ដី និងក្រខ្វក់ទឹក ព្រមទាំងបង្កើតជំរកប៉ាក់តើរ និងភ្ជាក់ងារចំលងជំងឺដែលនាំឱ្យប៉ះពាល់ដល់សុខភាពមនុស្ស ។ ការគ្រប់គ្រងទឹកក្រខ្វក់មិនបានល្អ ឬភាពមិនដំណើរការល្អនៃអាងធ្វើប្រព្រឹត្តកម្មសំអាតទឹកស្អុយ នៅលើកោះពស់ ក៏ដូចជានៅឆ្នេរហាវ៉ៃ នឹងបំពុលគុណភាពទឹកនៅជុំវិញកន្លែងដែលបង្ហូរចេញ ។

➢ *<u>វិធានការកាត់បន្ថយ</u>*

- *ក្រុមហ៊ុននឹងផ្តល់ឱ្យគ្រប់គ្រាន់នូវគ្រឿងសំភារៈគ្រប់គ្រងសំណល់រឹងដូចជា ធុងដាក់សំរាម និងកន្លែងដាក់សំរាមតាមការចនាប្លង់ទាន់សម័យទំនើបសំរាប់តំបន់រមណីយដ្ឋាន (ធុងសំរាមមានបីប្រភេទ ដូចជា (១) ធុងសំរាមក្រដាស់/ប្លាស្ទិក/កំទេចដែក/កែវ (២) ធុងសំរាមសំណល់អាហារនិងបន្លែ និង (៣) ធុងសំរាមគ្រោះថ្នាក់(ថ្មពិល អាគុយ សំណល់ថ្នាំពេទ្យ និងសាធាតុពុលនានា ។ល ។)*
- *ក្រុមហ៊ុនកោះពស់នឹងធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុនផ្តល់សេវាកម្មប្រមូលសំរាម (ដូចជា CINTRI) ដើម្បីប្រមូល ដឹកជញ្ជូន និងយកទៅចោះចោលរាល់សំណល់រឹងទាំងអស់ដែលកើតចេញពីកិច្ចដំណើរការគំរោងមរកតទាំងមូល ។*
- *ក្រុមហ៊ុនធ្វើការត្រួតពិនិត្យជាប្រចាំ ដើម្បីធានាថាកិច្ចដំណើរការនៃអាងធ្វើប្រព្រឹត្តិកម្មទាំងអស់របស់គំរោងមានដំណើរការល្អ ដែលធានាបាននូវតំលៃនៃកំរិតប៉ារ៉ាម៉ែត្របង្ហូរចេញស្របតាមបទដ្ឋានបង្ហូរចេញទៅតំបន់ទឹកសាធារណៈ ដែលកំណត់ដោយក្រសួងបរិស្ថាននៃប្រទេសកម្ពុជា ។*

- *ក្រុមហ៊ុនមរកតមានសាងសង់មន្ទីរពហុព្យាបាល ឬមណ្ឌលសុខភាពនៅលើកោះពស់ និងមានផ្តល់សេវាកម្មថែទាំសុខភាពចំពោះភ្ញៀវទេសចរណ៍ក៏ដូចជាប្រជាពលរដ្ឋក្នុងខេត្តព្រះសីហនុផងដែរ ។*
- *ក្រុមហ៊ុនកោះពស់នឹងធ្វើសហប្រតិបត្តិការល្អជាមួយភ្នាក់ងារថែទាំសុខភាពថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់ ឬថ្នាក់អន្តរជាតិ ដើម្បីដោះស្រាយរាល់បញ្ហាសុខភាពនៅក្នុងតំបន់គំរោង ។*

- **ហានិភ័យ**

ក្នុងពេលស្ពានដំណើរការ ស្ពាននេះអាចជាកន្លែងគោលដៅសំរាប់មនុស្សមួយចំនួនធ្វើអត្តឃាត (អ្នកមោហាំង ឬអ្នកខូចចិត្ត ទៅលោតទឹកសម្លាប់ខ្លួន) ដូចធ្លាប់កើត មានឡើងជាធម្មតានៅស្ពានធំៗក្នុងប្រទេសកម្ពុជា។ ជួនកាលការរុញច្រានគ្នាដោយចេតនា ឬដោយអចេតនា និងការប្រច្រៀតគ្នាហួសហេតុនៅលើស្ពាន ក៏អាចបង្កជាគ្រោះថ្នាក់ដល់ជីវិតបានដែរ ។

➢ *<u>វិធានការកាត់បន្ថយ</u>*

<u>មុនពេលមានហានិភ័យ</u>

- *ក្រុមហ៊ុននឹងមានដាក់ឆ្នាំស្ពាន និងប៉ូលីសឱ្យបានគ្រប់គ្រាន់នៅលើស្ពាន ព្រមទាំងរៀបចំឱ្យមានឆ្នាំស្ពានបីវេន ដើម្បីធានាសុវត្ថិភាព ២៤ ម៉ោង លើ២៤ ម៉ោង ។*
- *តំរោងនេះមានបំពាក់ភ្លើងបំភ្លឺទាំងផ្នែកខាងលើស្ពាន និងខាងក្រោមស្ពានបានគ្រប់គ្រាន់ ។*
- *អនុញ្ញាតឱ្យប្រជាពលរដ្ឋចូលលេងកំសាន្តលើផ្ទៃរហាវ៉ៃតាមធម្មតា និងអនុញ្ញាតឱ្យប្រជាពលរដ្ឋចូលទៅលេងលើកោះពស់ក្នុងកំរិតកំណត់ ដោយដឹកជញ្ជូនតាមឡានប្រើអគ្គិសនីពីគល់ស្ពានខាងដីគោក ដើម្បីធានាបានទាំងសុវត្ថិភាព និងភាពស្អាតដល់ផ្ទៃ និងបរិស្ថានលើកោះទាំងមូល*
- *ក្រុមហ៊ុននឹងរៀបចំផែនការ សុវត្ថិភាព និងសន្តិសុខទូទៅ ដើម្បីបញ្ជៀសភាពកកស្ទះនៅគល់ស្ពាន និងលើស្ពាន នៅពេលមានប្រារព្ធពិធីពិសេសៗជា សាធារណៈនៅលើកោះពស់ ។*

<u>នៅពេលមានហានិភ័យ</u>

នៅពេលមានហានិភ័យកើតឡើង ក្រុមហ៊ុនកោះពស់នឹង:

- *ប្រើប្រាស់កំលាំងសមត្ថកិច្ច និងធនធានឧបករណ៍សំភារៈរបស់ក្រុមហ៊ុនឱ្យអស់លទ្ធភាព និងធ្វើកិច្ចសហការជាមួយប៉ូលីស សមត្ថកិច្ចគ្រប់ជាន់ថ្នាក់ក្នុងក្រុងព្រះសីហនុ និងភ្នាក់ងារសង្គ្រោះដទៃទៀតឱ្យបានទាន់ពេលវេលា ដើម្បី ដោះស្រាយចំពោះបញ្ហាហានិភ័យដែលអាចកើតឡើងលើកោះពស់ និងស្ពានកោះពស់ ។*
- *ធានាការដោះស្រាយជាបន្ទាន់ ចំពោះការបាត់បង់ទ្រព្យសម្បត្តិ និងអាយុជីវិតទៅតាមច្បាប់វិនិយោគ ការធានារ៉ាប់រងរបស់ក្រុមហ៊ុន និងកាតព្វកិច្ចច្បាប់នានារបស់កម្ពុជា ។*

ខ) ហេតុប៉ះពាល់ទៅលើបរិស្ថានធម្មជាតិ

- **ហេតុប៉ះពាល់ទៅលើព្រៃឈើ និងសត្វព្រៃ**

គំរោងនឹងប៉ះពាល់ដល់សត្វព្រៃ ជាពិសេស ពពួកបក្សីនៅតំបន់កោះពស់ ដោយសារនៅពេលដំណើរការគំរោង និងមានចំនួនមនុស្សច្រើនកុះករនៅលើកោះ។ ជាងនេះទៀតនោះព្រៃឈើចំនួន ៤៦ហ.ត នៅលើកោះត្រូវបានបាត់បង់ក្នុងពេលសាងសង់គំរោង ដូចនេះសត្វព្រៃបានបាត់បង់ជំរករបស់វា និងធ្វើឱ្យថយចុះនូវលំនឹងប្រព័ន្ធអេកូឡូស៊ីលើកោះពស់ និងតំបន់ក្បែរខាង។ គំរោងបានធ្វើឱ្យថយសមត្ថភាពស្រូបជាតិឧស្ម័នកាបូនឌីអុកស៊ីតប្រមាណជា ២៤.១១៩តោន/ឆ្នាំ គិតជាទឹកប្រាក់ត្រូវជា ១២០.៦០០ដុល្លារអាមេរិក ហើយបាត់បង់កំនើនមាឌឈើ ៤០ តោន/ឆ្នាំ ឬ គិតជាទឹកប្រាក់ត្រូវជា ១.៨៥០ដុល្លារអាមេរិក/ឆ្នាំ ដោយផ្អែកតាម លទ្ធផលសិក្សាលើព្រៃឈើ។

ប៉ុន្តែហេតុប៉ះពាល់លើសត្វព្រៃ ពុំមានលក្ខណៈធំដុំទេ ដោយសារកោះពស់មិនមែនជាជំរកដ៏សំខាន់របស់សត្វព្រៃនោះទេ ហើយមានសត្វស្លាប សត្វស្វា និងសត្វពស់តិចតួចណាស់ដែលមានវត្តមាននាពេលបច្ចុប្បន្ននេះ។

➢ *<u>វិធានការកាត់បន្ថយ</u>*

- *ការដាំឈើឡើងវិញនៅកន្លែងដីវាល់ចាំបាច់មួយចំនួនលើកោះពស់ ដែលអាចក្យាបានជាជំរកបក្សីព្រៃ និងជំរកសត្វព្រៃដទៃទៀត។ ធ្វើបានដូច្នេះអាចអភិរក្សនូវប្រព័ន្ធអេកូឡូស៊ីនៅក្នុងតំបន់នេះបានមួយចំនួន។*
- *ក្រុមហ៊ុននឹងចូលរួមវិភាគទានក្នុងកម្មវិធីអភិរក្ស និងការដាំព្រៃឈើឡើងវិញនៅក្នុងខេត្តព្រះសីហនុ ឧទាហរណ៍ក្រុមហ៊ុននឹងចូលរួមវិភាគទានក្នុងទិវាដាំដើមឈើជាដើម។ល។*

- **ហេតុប៉ះពាល់ទៅលើ ភាវរសក្នុងទឹក/មច្ឆា**

ហេតុប៉ះពាល់លើវារីសត្ត/ត្រី អាចនឹងកើតមានឡើង ដោយសារការបង្ហូរទឹកក្រខ្វក់ដែលគ្មានការសំអាតចូលក្នុងប្រភពទឹក ការពង្រាយសំរាម/សំណល់រឹងនៅលើឆ្នេរ ឬតាមមាត់ទឹក។ គំរោងនឹងមានហេតុប៉ះពាល់តិចតួចទៅមធ្យមលើវារីសត្ត/វារីរុក្ខជាតិ ជាមួយនឹងការបណ្តុំជាតិពុលជាបន្តបន្ទាប់ហូរចូលទៅក្នុងទឹក។

សកម្មភាពនេសាទច្រើន និងការប្រមូលយកវារីសត្តនៅតាមមាត់ច្រាំងនៃតំបន់កោះពស់អាចនឹងកើតមានឡើង។ ដោយសារភាពងាយស្រួលក្នុងការចេញចូលបណ្តាលមកពីកិច្ចដំណើរការស្ពានអាចទាក់ទាញដល់អ្នកនេសាទ ឬ ភ្ញៀវទេសចរណ៍ចូលមក និងធ្វើនេសាទនៅតាមក្បែរច្រាំងកោះពស់។

➢ *<u>វិធានការកាត់បន្ថយ</u>*

- *គំរោងមរកតមានផែនការទប់ស្កាត់ និងធ្វើឱ្យប្រសើរឡើងនូវធនធានធម្មជាតិសំរាប់ការអភិវឌ្ឍន៍ផ្នែកទេសចរណ៍ ដូចនេះសកម្មភាពនេសាទ និងការប្រមូលវារីសត្តនឹងត្រូវមានកំណត់។*

- *ក្រុមហ៊ុននឹងធ្វើសហប្រតិបត្តិការល្អជាមួយខ័ណ្ឌរដ្ឋបាលជលផលខេត្តព្រះសីហនុ និងអនុញ្ញាតឱ្យអ្នកនេសាទធ្វើសកម្មភាពនេសាទនៅតំបន់កោះពស់ក្នុងចំងាយដែនកំណត់ពីមាត់ច្រាំង (យ៉ាងតិច ១០០ ម៉ែត្រ ពីច្រាំងកោះពស់)*
- *គ្រប់គ្រងឱ្យបានល្អចំពោះកាកសំណល់ដែលកើតចេញពីការប្រតិបត្តិគំរោង។ ត្រួតពិនិត្យយ៉ាងខ្ជាប់ខ្ជួននូវអាងធ្វើប្រព្រឹត្តិកម្មទឹកស្អុយឱ្យមានដំណើរការល្អ លើយតំលៃនៃប៉ារ៉ាម៉ែត្របង្ហូរចេញគោរពតាមបទដ្ឋាននៃការបង្ហូរចូលតំបន់ទឹកធម្មជាតិដែលកំណត់ដោយក្រសួងបរិស្ថាន។*
- *ក្រុមហ៊ុននឹងធ្វើសហប្រតិបត្តិការល្អជាមួយខ័ណ្ឌរដ្ឋបាលជលផលខេត្តព្រះសីហនុ ដើម្បីត្រួតពិនិត្យតាមដានវារីសត្ត/ត្រី និងវារីរុក្ខជាតិក្នុងតំបន់កោះពស់ទាំងមូលអំឡុងពេលដំណើរការគំរោង។ នឹងមានផែនការធ្វើអង្កេតលើត្រី និងផ្ទាម្នៅជុំវិញកោះពស់ (១០០ម ពីមាត់ច្រាំង) ជារៀងរាលពីរឆ្នាំម្តងពេញរយៈពេលប្រតិបត្តិការគំរោង ដើម្បីពិនិត្យមើលធនធានធម្មជាតិនេះ និងរកដំណោះស្រាយធ្វើយ៉ាងណារក្សានិរន្តភាពវាឱ្យបាន។*

- **ហេតុប៉ះពាល់ទៅលើដីប្រើប្រាស់**

អំឡុងពេលនៃកិច្ចប្រតិបត្តិការគំរោងមរកតដីប្រើប្រាស់នៅក្នុងតំបន់នឹងត្រូវបានផ្លាស់ប្តូរនៅលើដីកោះ និងនៅដីគោក។ ការផ្លាស់ប្តូរនៃដីប្រើប្រាស់លើកោះពស់ គឺការថយចុះនូវព្រៃឈើក្នុងតំបន់ឆ្នេរដោយសារការអភិវឌ្ឍដី និងសកម្មភាពអភិវឌ្ឍន៍ផ្សេងទៀតនៅលើកោះ ហើយមានការប្រែប្រួលប្រព័ន្ធអេកូឡូស៊ីនៅលើកោះ និងអាចបង្កផលអាក្រក់ដល់ផែព្រះសីហនុដោយសារខ្យល់ហោកបក់ខ្លាំង និងរកលធំៗ។

➢ *<u>វិធានការកាត់បន្ថយ</u>*

- *ក្រុមហ៊ុននឹងរៀបចំផែនការអភិវឌ្ឍឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំ និងបទដ្ឋានក្នុងន័យការអភិវឌ្ឍដែលមានលក្ខណៈសេដ្ឋកិច្ចផង និងការពារបានន្ទូវបរិស្ថានផង។*
- *បញ្ជៀសរាល់ការបំផ្លិច បំផ្លាញដល់ធនធានបរិស្ថានធ្ងន់ធ្ងរ ជាពិសេសប្រព័ន្ធអេកូឡូស៊ីតំបន់កោះពស់ និង បញ្ជៀសរាល់ ទំនាស់សង្គមធ្ងន់ធ្ងរក្នុងតំបន់គំរោង។*
- *ក្រុមហ៊ុននឹងធ្វើសហប្រតិបត្តិការជាមួយស្ថាប័នជំនាញនានាក្នុងខេត្តព្រះសីហនុ ក៏ដូចក្រសួងពាក់ព័ន្ធ ដើម្បីដោះស្រាយរាល់ទំនាស់នានាដែលទាក់ទងនឹងការអភិវឌ្ឍគំរោងនេះ។*

គ) ហេតុប៉ះពាល់ដោយសារជាតិពុល

- **ការបំពុលខ្យល់**

ការកើនឡើងនូវរថយន្តធុនធ្ងន់ និង រថយន្តដឹកផ្សេងៗ នៅតំបន់កោះពស់ ក៏ដូចជានៅក្នុងក្រុងព្រះសីហនុ នឹងបញ្ចេញផ្សែងក្រខ្វក់មួយចំនួនចូលទៅក្នុងបរិយាកាសនៅក្នុងតំបន់។ ការបំភាយពីរថយន្តតូចធំ និងទោចក្រយាន

យន្តទាំងនោះ រួមមាន NO_2, SO_2, CO, និង TSP ។ សំលេង និងរំញ័រចេញពីការធ្វើចរាចរណ៍នៃយានយន្តទាំងនោះអាចគិតថាមិនសំខាន់ ។

ខ្យល់កខ្វក់អាចប៉ះពាល់ដល់សុខភាពមនុស្ស/ភ្ញៀវទេសចរណ៍នៅក្នុងតំបន់ ជាពិសេស ប្រជាជនដែលរស់នៅក្នុងតំបន់គំរោង និងតំបន់ក្បែរខាងសង្កាត់លេខ៣ និងខ័ណ្ឌមិត្តភាព។ ប៉ុន្តែហេតុប៉ះពាល់ពីការបំពុលខ្យល់ អំឡុងពេលដំណើរការគំរោងមិនមានកំរិតធំដុំនោះទេ ដោយសារមានខ្យល់បរិយាកាសល្អណាស់នៅតំបន់ឆ្នេរ ហើយមានចរាចរណ៍តិចតួចផងដែរក្នុងតំបន់នេះ ។

➢ *<u>វិធានការកាត់បន្ថយ</u>*

- *ការការពារព្រៃឈើឱ្យបានល្អ (ដើមឈើ និងរុក្ខជាតិនានា) នៅលើកោះ និងនៅដីគោកនៅក្នុងតំបន់កោះពស់ទាំងមូល ហើយការដាំដើមឈើនៅកន្លែងទំនេរ ឬនៅតាមបណ្តោយផ្លូវក៏អាចជួយរក្សាឱ្យមានខ្យល់អាកាសបរិសុទ្ធផងដែរ ។*

- **ការបំពុលទឹក**

ការបោះចោលសំរាមចូលក្នុងទឹកសមុទ្រ ឬនៅទីវាលលើកោះពស់ និងឆ្នេរហាវ៉ៃនឹងបំពុលគុណភាពទឹកនៃតំបន់ឆ្នេរសមុទ្រនេះ ។ ជួនកាល ការបង្ហូរទឹកក្រខ្វក់មិនបានសំអាតចេញពីសហគមន៍ ឬសកម្មភាពដំណើរការគំរោងចូលក្នុងប្រភពទឹក ឬទីធ្លាចំហអាចកើតមានឡើង ។ ការមិនដំណើរការល្អនៃអាងធ្វើប្រព្រឹត្តិកម្មសំអាតទឹកក្រខ្វក់នៅលើកោះពស់ និងនៅឆ្នេរហាវ៉ៃអំឡុងពេលប្រតិបត្តិគំរោងនឹងបំពុលគុណភាពទឹកសមុទ្រក្នុងតំបន់នេះ ។

➢ *<u>វិធានការកាត់បន្ថយ</u>*

- *គ្រប់គ្រងឱ្យបានល្អចំពោះកាកសំណល់គំរោង ដែលកើតចេញពី លំនៅដ្ឋាន សណ្ឋាគារ អាគារការិយាល័យ តំបន់ពាណិជ្ជកម្ម និងតំបន់សាធារណៈនៅលើកោះពស់ និងនៅឆ្នេរហាវ៉ៃ ។ ជាឧទាហរណ៍សំណល់រឹង គឺមានការគ្រប់គ្រងយ៉ាងល្អដោយមានប្រព័ន្ធប្រមូលយកតាមការទាមទារនៃបរិស្ថានស្អាតសមជាទីស្ថានទេសចរណ៍ ហើយទឹកក្រខ្វក់គឺមានតភ្ជាប់យ៉ាងល្អត្រឹមត្រូវ និងធ្វើការសំអាតដោយអាងធ្វើប្រព្រឹត្តកម្មមុននឹងបង្ហូរចេញចូលទៅក្នុងសមុទ្រ ។*
- *ក្រុមហ៊ុន នឹងវ៉ែទាំ និងត្រួតពិនិត្យយ៉ាងខ្ជាប់ខ្ជួននូវអាងធ្វើប្រព្រឹត្តិកម្មទឹកស្អុយឱ្យមានដំណើរការល្អ ហើយតំលៃនៃប៉ារ៉ាម៉ែត្របង្ហូរចេញគោ:ពតាមបទដ្ឋាននៃការបង្ហូរចូលតំបន់ទឹកធម្មជាតិដែលបានកំណត់ដោយក្រសួងបរិស្ថាន ។*
- *ត្រួតពិនិត្យគុណភាពទឹកនៅជុំវិញទីតាំងគំរោង នឹងត្រូវអនុវត្តឱ្យបានទៀងទាត់ ដើម្បីធានាថាគុណភាពរបស់ទឹកនៅពេលប្រតិបត្តិគំរោងមិនមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ជីវិតសត្ត និងរុក្ខជាតិក្នុងទឹក និងមនុស្ស ។ ប៉ារ៉ាម៉ែត្រសំខាន់ៗសំរាប់ត្រួតពិនិត្យគុណភាពទឹកគឺ TSS, DO, BOD_5, Total N, Total P, Cd, Hg, and Pb ។*

- **កាកសំណល់**

ការចោលសំណល់រឹង/សំរាមលើផ្ទៃដី លើឆ្នេរមាត់ទឹក និងក្នុងផ្ទៃទឹកពីសំណាក់ភ្ញៀវទេសចរណ៍ ឬសហគមន៍រស់នៅលើកោះពស់អំឡុងពេលប្រតិបត្តិគំរោងអាចនឹងកើតមានឡើង បើសិនប្រព័ន្ធគ្រប់គ្រងសំណល់រឹងមិនផ្តល់ឱ្យបានគ្រប់គ្រាន់ និងមិនដំណើរការល្អ ។

➢ *<u>វិធានការកាត់បន្ថយ</u>*

- *កាកសំណល់រឹងដែលកើតចេញពី លំនៅដ្ឋាន សណ្ឋាគារ អាគារ ការិយាល័យ តំបន់ពាណិជ្ជកម្ម និងតំបន់សាធារណៈនៅលើកោះពស់ និងនៅឆ្នេរហាវ៉ៃ នឹងត្រូវបានប្រមូល ទុកដាក់ និងយកទៅបោះចោលតាមការទាមទារនៃបរិស្ថានស្អាតសំរាប់តំបន់រមណីយដ្ឋាន ។ ក្រុមហ៊ុននឹងផ្តល់ធុងដាក់សំរាមដោយឡែកៗពីគ្នា តាមប្រភេទសំរាម ដូចជា (១) ធុងសំរាមក្រដាស់/ប្លាស្ទិក/កំទេចដែក/កែវ (២) ធុងសំរាមផ្ទះបាយ និង (៣) ធុងសំរាមគ្រោះថ្នាក់(ថ្មពិល អាគុយ សំណល់ថ្នាំពេទ្យ និងសារធាតុពុលនានា ។ល ។)*
- *ប្រព័ន្ធប្រមូលសំរាមផ្ទះបាយមួយដង ទៅពីរដងក្នុងមួយថ្ងៃនឹងត្រូវអនុវត្តចំពោះគំរោងមរកត ។ ប្រើប្រាស់ឡានដឹកសំរាមដែលមានគុណភាពល្អ ដើម្បីធានាមិនឱ្យមានការលេច ឬកំពុបសំរាមតាមដងផ្លូវឡើយ ។*
- *ក្រុមហ៊ុនកោះពស់នឹងធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុនប្រមូលសំរាមនៅក្នុងក្រុងព្រះសីហនុ (ដូចជាក្រុមហ៊ុន CINTRI) ដើម្បីប្រមូល ដឹកជញ្ជូន និងយកទៅបោះចោលនូវសំណល់រឹងទាំងអស់ដែលចេញពីគំរោងមរកត ពេញរយៈពេលប្រតិបត្តគំរោង ។ បច្ចុប្បន្ន ក្រុមហ៊ុនកោះពស់មានកិច្ចសន្យាជាមួយក្រុមហ៊ុន CINTRI សាខាក្រុងព្រះសីហនុ ដើម្បីប្រមូលសំរាមការិយាល័យ និងសំរាមផ្ទះបាយយកទៅបោះចោល សូមមើល ឧបសម្ព័ន្ធទី៥ ។*

៦.២.៤ សង្ខេបហេតុប៉ះពាល់អវិជ្ជមាន និងវិធានការកាត់បន្ថយ

ហេតុប៉ះពាល់បរិស្ថាននៃគំរោងមរកត គឺជាលទ្ធផលកើតចេញពីសកម្មភាពសាងសង់ និងប្រតិបត្តិការស្ពានកោះពស់ ហេដ្ឋារចនាសម្ព័ន្ធលើកោះពស់ និងឆ្នេរហាវ៉ៃនឹងមានសំពាធទៅលើអេកូឡូស៊ីក្នុងតំបន់ និងលើជីវភាពប្រជាពលរដ្ឋ ជាពិសេសអ្នកដែលរស់នៅពីងផ្អែកលើធនធានធម្មជាតិលើកោះពស់នេះ ។ ក្នុងតារាង ៦.២.៤-១ បង្ហាញសង្ខេបនៃហេតុប៉ះពាល់ និងវិធានការកាត់បន្ថយរឿងរ៉ាវបរិស្ថាននីមួយៗ ។

តារាង៦.២.៤-១: សង្ខេបហេតុប៉ះពាល់អវិជ្ជមាន និងវិធានការកាត់បន្ថយ

រឿងរ៉ាវបរិស្ថាន	សកម្មភាព	កំរិតនៃហេតុប៉ះពាល់			វិធានការកាត់បន្ថយ
		តិច	មធ្យម	ខ្លាំង	
ដំណាក់កាលមុនពេលសាងសង់					
ទីតាំងគំរោង និងការរចនាប្លង់	ស្ពានស្នើសុំនឹងកាត់តាមឃ្លងធម្មជាតិនៅក្នុងតំបន់កោះពស់ ដែលជាកន្លែងផ្លូវនាវាចរណ៍សំរាប់កប៉ាល់ចេញចូលទៅផែកំពង់សោម ។ សមាសធាតុជំនួយផ្សេងៗទៀតរបស់គំរោង និងជំរុំកម្មករ ដែលរៀបចំដាក់នៅជិតសំណង់ស្ពាន និងឆ្នេរហាវ៉ៃ នឹងធ្វើឱ្យមានការមិនសប្បាយចិត្តដល់អ្នកជិតខាង និងអ្នកទេសចរណ៍នៅឆ្នេរលំហែកាយ និងឆ្នេរហាវ៉ៃ ។		✓		*ក្រុមហ៊ុនកោះពស់ (ខេមបូឌា) អ៊ិនវេសមេនត្រូប អេលធីឌី នឹងអនុវត្តតាមគោលការណ៍បច្ចេកទេសដែលបានអនុម័តដោយអន្តរក្រសួង និងរាជរដ្ឋាភិបាលកម្ពុជា:-* - ***កំពស់ស្ពាន:*** *៣២.៥ ម៉ែត្រ គិតចាប់ពីផ្ទៃទឹកពេល ទឹកសមុទ្រជារខ្ពស់បំផុត ។* - ***គំលាតសសរស្ពាន:*** *២០០ ម៉ែត្រ នៅត្រង់ចន្លោះកណ្តាលស្ពាន ដើម្បីសំរួលដល់នាវាចរណ៍ ។* - ***សំភារៈតាំងភ្ជាប់ និងស្លាកសញ្ញាចរាចរ:*** *មានគំនូសចរាចរ-បំពាក់ភ្លើងអគ្គិសនីតាមបណ្តោយស្ពានរួមទាំងខាងលើ និងខាងក្រោមស្ពានផងដែរ-បំពាក់បង្គាន់ដៃស្ពាន-បំពាក់ស្លាកសញ្ញាចរាចរណ៍ផ្សេងៗទៀតតាមលក្ខណៈបច្ចេកទេសកំណត់ ។* - ***លក្ខណៈបច្ចេកទេសសាងសង់ស្ពាន:*** *គោរពតាមការណែនាំរបស់ក្រសួង-ស្ថាប័នជំនាញនៃរាជរដ្ឋាភិបាលកម្ពុជា និងអនុវត្តសុវត្ថិភាពការងារក្នុងពេលសាងសង់ ។* *ក្រុមហ៊ុននឹងសហការល្អជាមួយគណៈកម្មការត្រួតពិនិត្យបទដ្ឋានបច្ចេកទេសសាងសង់ស្ពានកោះពស់ អន្តរក្រសួង អាជ្ញាធរមូលដ្ឋាន អ្នកដឹកនាំសហគមន៍ នៅពេលជ្រើសរើសទីតាំង ការរៀបចំដាក់សមាសធាតុទាំងអស់របស់គំរោង រួមទាំងជំរុំបុគ្គលិក-កម្មករនៅក្នុងបរិវេណគំរោង ។*

Draft

ការសំអាតការដ្ឋានសាងសង់	ការឆ្ការព្រៃ ៤៧% នៃផ្ទៃព្រៃឈើលើកោះ និងការឈូសឆាយដីសំរាប់ការដ្ឋានសាងសង់ជំរុំកម្មករ និងសមាសធាតុ បន្ទាប់បន្សំផ្សេងទៀតនឹងធ្វើឱ្យបាត់បង់ដើមឈើ និងកំរាលរុក្ខជាតិ ដែលបង្កឱ្យមានសំណឹកដី និងប៉ះពាល់ដល់គុណភាពទឹក ។ ការបំពុលខ្យល់ ធូលី សំលេង និងរំញ័រ នឹងបង្កហេតុប៉ះពាល់ដល់ សហគមន៍ជិតខាង ។		✓		- *ការសំអាតទីតាំងនេះនឹងត្រូវធ្វើឡើងក្នុងដែនកំណត់សំរាប់តែធ្លាចាំបាច់ដែលបំរើឱ្យការសាងសង់ ។* - *រៀបចំផែនការធ្វើការឈូសឆាយដីនៅរដូវប្រាំង ហើយវិធានការសំរាប់ការពារចំរោះដីនឹងត្រូវបានអនុវត្ត ដូចជា រៀបចំជាថ្នាក់ៗដូចកាំជណ្តើរ ការដាក់ក្រណាត់សំពត់ចាប់យកកករដីនៅការដ្ឋានក្នុងទឹក និងមាត់ទឹក ។* - *ការិតកំណត់សំលេង និងរំញ័រចេញពីម៉ាស៊ីន គ្រឿងចក្រនៅពេលឈូសឆាយដី និងពេលកាប់ដើមឈើ នឹងត្រូវអនុវត្ត ។* - *ប្រើប្រាស់គ្រឿងចក្រ និងយានយន្តដែលមានគុណភាពល្អ ។ គំរោងមានផែនការ អនុវត្តការងារនៅតែពេលថ្ងៃប៉ុណ្ណោះ ។*
ការអង្កេតភូគព្ភសាស្ត្រ	ការខួងដី និងថ្មដើម្បីអង្កេតពីភូគព្ភសាស្ត្រនៅលើកោះពស់ ទីតាំងស្ពាន និងតំបន់អភិវឌ្ឍន៍ឆ្នេរហាវ៉ៃ អាចបង្កហេតុប៉ះពាល់ដល់គុណភាពទឹកតាមឆ្នេរនៅក្នុងតំបន់គំរោង ។	✓			- *ការការពារជាមូលដ្ឋានមួយចំនួនចំពោះ ភក់ ឬល្បប់/ផេះ ចេញពីរណ្តៅខួងត្រូវបានផ្តល់ ដោយដាក់ក្រណាត់សំពត់ ឬសំណាញ់ជ្ជាស្ទីកពណ៌ខ្មៅ ចាប់យកកករដីនៅការដ្ឋានខួងក្នុងទឹក និងមាត់ទឹក ។* - *អាចម៍ដី ឬផេះថ្មចេញពីរណ្តៅខួង និងទុកដាក់ក្នុងកន្លែងមានសុវត្ថិភាពប្រើសំរាប់បំពេញដី ទីលានវាយកូនគោល ។* - *ការកំណត់សំលេង និងរំញ័រចេញពីម៉ាស៊ីនខួងដី/ថ្ម នឹងត្រូវអនុវត្តន៍ស្របតាមបទដ្ឋានកំណត់សំរាប់សំលេង និងរំញ័ររបស់ក្រសួងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា ។*
ដំណាក់កាលសាងសង់					
ចរាចរណ៍	ភាពកកស្ទះចរាចរណ៍ នឹងអាចកើតឡើងនៅលើផ្លូវក្នុងមូលដ្ឋាន ដែលបណ្តាលមកពីការដឹកជញ្ជូនសំភារៈសំណង់ចេញ និងចូលការដ្ឋានគំរោង ។ ចរាចរណ៍យ៉ាងមមាញ៉ឹកពីរថយន្តធំរបស់	✓			- *ស្លាកសញ្ញាចរាចរណ៍ និងអ្នកសំរួលចរាចរណ៍ (ដូចជាប៉ូលីស) នឹងត្រូវផ្តល់ឱ្យបានគ្រប់គ្រាន់នៅតាមបណ្តោយផ្លូវក្នុងតំបន់គំរោង និងនៅក្នុងផ្លូវចេញចូលរបស់គំរោង ។* - *អប់រំដល់អ្នកបើកបររបស់គំរោង គោរពតាមច្បាប់ចរាចរណ៍ផ្លូវគោករបស់ប្រទេសកម្ពុជា ។*

Draft

	គំរោងក៏អាចបង្កការខូចខាតដល់ផ្លូវថ្នល់ផងដែរ ជាពិសេសកំណាត់ផ្លូវ២ធ្នូនៅខាងមុខឆ្នេរហាវ៉ៃ ។				- *ក្រុមហ៊ុននឹងធ្វើការកែលំអ និងជួសជុលកំណាត់ផ្លូវ២ធ្នូ ដែលប្រើប្រាស់សំរាប់ជាផ្លូវចេញចូលរបស់គំរោង ។*
សិទ្ធិប្រើប្រាស់ទឹក និងសិទ្ធិទូទៅ	គំរោងមរកតនឹងប្រើប្រាស់ទឹកពីរដ្ឋាការទឹកក្រុងព្រះសីហនុ សំរាប់បំរើឱ្យការងារសាងសង់ ព្រមទាំងការប្រើប្រាស់ប្រចាំថ្ងៃរបស់បុគ្គលិក/កម្មករទៀតផង ។ តំរូវការទឹកយ៉ាងច្រើននេះអាចប៉ះពាល់ដល់បរិមាណទឹកប្រើប្រាស់របស់អ្នកក្រុងព្រះសីហនុ ។ គំរោងនឹងប៉ះពាល់ដល់សកម្មភាពនេសាទរបស់អ្នកនេសាទមួយចំនួនដែលតែងតែធ្វើនេសាទនៅក្បែរតំបន់គំរោង ។ គំរោងនឹងប៉ះពាល់ដល់ការប្រើប្រាស់ឆ្នេររបស់ប្រជាពលរដ្ឋទូទៅ ដែលចង់ទៅលេងកំសាន្តនៅឆ្នេរហាវ៉ៃ និងឆ្នេរកោះពស់		✓		- *គំរោងនឹងប្រើប្រាស់ទឹកពីប្រព័ន្ធទឹកស្អាតរបស់ក្រុង ដោយធ្វើកិច្ចសហការជាមុនជាមួយរដ្ឋាការទឹកក្រុងព្រះសីហនុ ដើម្បីឱ្យអង្គភាពនេះអាចពង្រីកសមត្ថភាពផ្គត់ផ្គង់បានសមស្របតាមតំរូវការប្រើប្រាស់ទូទាំងក្រុង ។* - *ក្រុមហ៊ុនធានាថា ការប្រើប្រាស់ទឹកពីរដ្ឋាការទឹកព្រះសីហនុមិនធ្វើឱ្យប៉ះពាល់ដល់ការប្រើប្រាស់ទឹករបស់អ្នកក្រុងទេ ដោយក្រុមហ៊ុនបានទទួលលិខិតផ្លើយតបលេខ៦៧២ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលបានបញ្ជាក់ថា អង្គភាពរដ្ឋាការទឹកក្រុងព្រះសីហនុមានលទ្ធភាពផ្គត់ផ្គង់ទឹកស្អាតគ្រប់គ្រាន់សំរាប់គំរោងមរកត ។* - *ក្រុមហ៊ុននឹងអនុញ្ញាតឱ្យអ្នកនេសាទធ្វើនេសាទជុំវិញកោះពស់ក្នុងចំងាយ ១០០ម៉ែត្រពីមាត់ទឹកលើកលែងតែកន្លែងសាងសង់ស្ពាន និងការដ្ឋានសាងសង់ស្ថានីយ៍ចតទូកទេសចរណ៍ ។*
សុខភាពសាធារណៈ	គំរោងអាចមានហេតុប៉ះពាល់ទៅលើសុខភាពកម្មករ និងសហគមន៍ ដោយការបញ្ចោញខ្សល់កខ្វក់ សំលេងរំខាន និង រំញ័រចេញពីគ្រឿងចក្រសាងសង់ ឡាន/ រថយន្តធំរបស់គំរោង ។ ការគ្រប់គ្រងមិនត្រឹមត្រូវនូវសំណល់ដែលកើតពីសកម្មភាពសាងសង់ និងមនុស្ស	✓			- *ក្រុមហ៊ុននឹងត្រូវអនុវត្តតាមបទដ្ឋានសុវត្ថិភាពការងារ ដោយផ្តល់ឧបករណ៍ និងបរិក្ខារគ្រប់គ្រាន់ (ស្បែកជើងកវែង ស្រោមដៃ មួកការពារ វ៉ែនតាការពារភ្នែក ។ល។ ដើម្បីការពារគ្រោះថ្នាក់ផ្សេងៗដល់បុគ្គលិក-កម្មករ គំរោង ។* - *អប់រំបុគ្គលិកគំរោងអំពីសុវត្ថិភាពការងារ និងការថែទាំសុខភាព ការធ្វើអនាម័យឱ្យបានត្រឹមត្រូវ ។* - *គំរោងនឹងផ្តល់ទឹកស្អាត និងសាងសង់ជ្រុំកម្មករដែលមានបំពាក់បង្គន់អនាម័យសំរាប់បុគ្គលិកកម្មករប្រើប្រាស់ និងស្នាក់នៅបានសមរម្យ ។* - *គ្រប់គ្រងសំណល់រឹងទាំងនៅក្នុងការដ្ឋានសាងសង់ និងជ្រុំកម្មករឱ្យបានត្រឹមត្រូវ ។*

Draft

	នៅការដ្ឋាន និងនៅជំរុំកម្មករ/បុគ្គលិកគំរោង ។ គំរោងអាចបង្កហេតុប៉ះ ពាល់ដល់សុខភាពប្រជាជនមូលដ្ឋាន តាមរយៈការចំលងជំងឺមួយចំនួន ដូចជា អេដស៍ ផ្តាសសាយបក្សី ជំងឺឆ្លងកាច សាហាវដទៃទៀត ការសេពថ្នាំញៀន និងជួញដូរគ្រឿងញៀន ។				- *ការការពារ និងព្យាបាលនឹងត្រូវបានផ្តល់ឱ្យដោយម្ចាស់គំរោង ឧទា. សេវាវ៉ៃទាំសុខភាព ថ្នាំពេទ្យ និងគ្រូពេទ្យ/វេជ្ជបណ្ឌិត ដើម្បីពិនិត្យ និងព្យាបាលបុគ្គលិក/កម្មករគំរោង ។* - *សហប្រតិបត្តិការល្អជាមួយស្ថាប័នសុខភាពនៅក្រុងព្រះសីហនុ និងថ្នាក់ជាតិ ដើម្បីការពារជំងឺឆ្លងណាមួយនៅក្នុង និងនៅជុំវិញតំបន់គំរោង ។* - *ក្រុមហ៊ុននឹងធ្វើសហប្រតិបត្តិការជាមួយប៉ូលីស និងអាជ្ញាធរមូលដ្ឋាន ដើម្បីទប់ស្កាត់ការប្រើប្រាស់ថ្នាំញៀន និងចរាចរណ៍ថ្នាំញៀននៅក្នុងតំបន់គំរោង ។*
ផ្លូវនាវាចរណ៍	គំរោងនឹងរំខានដល់ផ្លូវនាវាចរណ៍កាត់តាមឃ្លងធម្មជាតិនៅតំបន់កោះពស់ អំឡុងពេលសាងសង់ស្ពានកោះពស់ ។		✓		- *ក្រុមហ៊ុននឹងធ្វើសហប្រតិបត្តិការល្អជាមួយអាជ្ញាធរកំពង់ផែកំពង់សោម និងប្រើប្រាស់ផ្លូវវាងផ្សេងជាបណ្តោះអាសន្នសម្រាប់សកម្មភាពនាវាចរណ៍ក្នុងដំណាក់កាលសាងសង់ស្ពាន ។* - *ជូនដំណឹងឱ្យបានគ្រប់គ្រាន់ដល់អ្នកនេសាទ ភ្នាក់ងារទេសចរណ៍ និងប្រជាជនមូលដ្ឋានឱ្យប្រើប្រាស់ផ្លូវនាវាចរណ៍ផ្សេងទៀតសម្រាប់បើកបរទូករបស់គេ នៅឆ្ងាយពីការដ្ឋានសាងសង់ស្ពានដើម្បីជៀសវាងគ្រោះថ្នាក់ដែលអាចកើតមានឡើងជាយថាហេតុ ។* - *មានផ្តល់ស្លាកសញ្ញាសុវត្ថិភាពនៅជុំវិញការដ្ឋានស្ពាន និងមានបណ្តែតពោងបង្ហាញទិសដៅសម្រាប់ការធ្វើនាវាចរណ៍រាងការដ្ឋានសាងសង់ទៀតផង ។*
ហានលេខា	គំរោងនឹងផ្ទាស់ប្តូរកំពស់ផ្ទៃដីធម្មជាតិនៅកន្លែងមួយចំនួន ជាពិសេសនៅលើកោះពស់ ដោយសារការឈូសឆាយដី ការជីកកាយដី ដើម្បីសាងសង់ផ្លូវ និងអាគារនៅលើកោះពស់ ។	✓			- *ការការពារបរិស្ថានលើការផ្ទាស់ប្តូរហានលេខានៅក្នុងតំបន់គំរោងជាមួយនឹងទិដ្ឋភាពបច្ចេកទេស និងសេដ្ឋកិច្ចសម្រាប់ការសាងសង់ផ្លូវនឹងត្រូវអនុវត្ត ។* - *គំរោងមានផ្នែកការជៀសវាងការបំបែកយកផ្ទាំងថ្មច្រើនពេក ឬការជីកយកដីជ្រៅហួសហេតុ ហើយមានការរៀបចំជាថ្នាក់ៗចំពោះការដ្ឋានសាងសង់មួយចំនួន ដើម្បីកាត់បន្ថយការផ្ទាស់ប្តូរហានលេខានៃដីកោះនេះ ។*
សំណឹកដី	សំណឹកដីអាចកើតឡើងនៅការដ្ឋានផ្នែកចុងទាំងសងខាងនៃស្ពាន ការរដ្ឋានសាងសង់ផ្លូវ		✓		- *ការសំអាតរុក្ខជាតិក្នុងការដ្ឋានសាងសង់ទានារបស់គំរោងមរកត នឹងត្រូវកំណត់ទំហំជាអប្បរមាសម្រាប់តែការសាងសង់ ។*

	និងអាគារលើកោះ ដោយសារសណ្ឋានដី និងប្រភេទដីនៃតំបន់កោះពស់នេះ ។				- *ការលូសធាយដីនៅក្នុងការដ្ឋានសាងសង់នឹងត្រូវធ្វើតែនៅរដូវប្រាំង ឬគ្មានភ្លៀងធ្លាក់ ។* - *វិធានការ/ការទប់ស្កាត់សំណឹកដីសមស្រប នឹងត្រូវអនុវត្ត ដូចជាការដាំដុះរុក្ខជាតិឡើងវិញភ្លាម១ បន្ទាប់ពីបកស្រទាប់ដីលើ ជីកធ្វើជាថ្នាក់១ដូចកាំជណ្តើដើម្បីបន្ថយចំណោតដី ការរៀបចំជញ្ជាំងកន្ត ឬតម្រៀបថ្មនៅកន្លែងដែល មានដីងាយទទួលរងសំណឹក ។*
ធនធានឆ្នេរ	សកម្មភាពសាងសង់នៅតំបន់កោះពស់ នឹងបន្ថយនូវតំលៃធនធានមួយចំនួនអាស្រ័យការធ្វើឱ្យក្រខ្វក់ដោយសារគំរោង ដូចជាភាពមិនសប្បាយចិត្ត នៃការមើលឃើញហ្វូងមនុស្ស និង សំលេងអ៊ូអរ កើតចេញពីកម្មករ និងគ្រឿងចក្រសាងសង់នៃការដ្ឋានសំណង់ ។ ការគ្រប់គ្រងសំណល់រឹងមិនបានត្រឹមត្រូវ នៅកន្លែងសាងសង់ ការចោលកាកសំណល់លើដី ទៅក្នុងទឹក ឬនៅលើឆ្នេរ ធ្វើឱ្យខូចធនធានតាមឆ្នេរ ដូចជាធ្វើឱ្យក្រខ្វក់ឆ្នេរតាមមាត់ច្រាំង និងកន្លែងទឹកភាក់ ។ ទឹកដែលមានកករ និងកំទេចកំណខ្ពស់ ដែលកើតពីសកម្មភាពសាងសង់ នឹងធ្វើឱ្យក្រខ្វក់ និងបំផ្លាញដល់ច្រាំងសមុទ្រ និងគុណភាពទឹក ។	✓			- *នឹងដាក់របងស័ង្កសីកំពស់២ម៉ែត្រយ៉ាងតិច នៅជុំវិញការដ្ឋានសំណង់ ជាពិសេសនៅការដ្ឋានស្ពាន និងការដ្ឋាននៅលើឆ្នេរបាវ៉ៃ ។* - *គ្រឿងលំអក្តែត (ផ្ទាំងរូបភាពស្អាត១) នឹងត្រូវបំពាក់លើរបងការដ្ឋានផងដែរ បើចាំបាច់ ។* - *ការទប់ស្កាត់កករទឹក និងកំទេចកំណអោយបានល្អ ជាតំរូវការចាំបាច់នៅគ្រប់កន្លែងនៃការដ្ឋានសាងសង់នៅក្នុងទឹក និងនៅឆ្នេរសមុទ្រ/មាត់ទឹក ។ ជាឧទាហរណ៍ គេអាចដាក់ក្រណាត់ស្ទាក់កករដីនៅជុំវិញកន្លែងសាងសង់នៅក្នុងទឹក ហើយសាងសង់ស្រះរងកករនៅកន្លែងសាងសង់នៅក្បែរឆ្នេរសមុទ្រ ឬតាមមាត់ទឹក ។* - *គ្រប់គ្រងសំណល់ប្រេងម៉ាស៊ីន ឬប្រេងរំអិលដែលចេញពីសកម្មភាពសាងសង់ឱ្យបានត្រឹមត្រូវ ដោយប្រមូលទុកដាក់ក្នុងធុង និងប្រើប្រាស់ឡើងវិញ ឬលក់ឱ្យអ្នកយកទៅប្រើក្នុងបំណងផ្សេង១ ។* - *ធ្វើការថែទាំ និងជួសជុលគ្រឿងចក្រដែលបំរើការឱ្យគំរោងមិនឱ្យលេចកំពប់ប្រេង និងខ្លាញ់ ទៅលើដី ឬក្នុងទឹក ។* - *អប់រំដល់កម្មករមិនឱ្យចោលកាកសំណល់ចូលទៅក្នុងប្រភពទឹក ហើយផ្តល់មធ្យោបាយគ្រប់គ្រាន់ ដើម្បីគ្រប់គ្រងកាកសំណល់ រួមបញ្ចូលទាំងការសាងសង់បង្គន់អនាម័យនៅក្នុងទឹកកន្លែងសាងសង់ និងជុំវិញស្នាក់នៅរបស់បុគ្គលិក/កម្មករគំរោង ។*
ព្រៃឈើ និងសត្វព្រៃ	ការកាប់ព្រៃឈើប្រមាណជា ៤៦ហ.ត ឬ៤៧% នៃទំហំព្រៃឈើសរុបនៅលើកោះ ដើម្បីសាងសង់ផ្ទះ អាគារ និងហេដ្ឋារចនាសម្ព័ន្ធ		✓		- *ការកាប់ព្រៃឈើនឹងត្រូវធ្វើឡើងក្នុងដែនកំណត់នៃតំរូវការទីកន្លែងសំរាប់សកម្មភាពសាងសង់គំរោងប៉ុណ្ណោះ ។* - *ដាំដើមឈើ ឬរុក្ខជាតិដទៃទៀតឡើងវិញនៅបន្ទាប់ពីបញ្ចប់សកម្មភាពសាងសង់ជាក់ស្តែងនៅតាមការ*

	ដទៃទៀត ធ្វើឱ្យបាត់បង់ព្រៃឈើ និងថយចុះប្រព័ន្ធអេកូឡូស៊ីលើកោះ ។ ការកាប់ព្រៃឈើការទន្ទ្រានចូលក្នុងព្រៃលើកោះពីសំណាក់កម្មករសំណង់ដើម្បីចាប់សត្វព្រៃ អាចប៉ះពាល់ដល់សត្វព្រៃនៅលើកោះពស់ ។				*ដ្ឋានមួយៗ ។* - *ហាមឃាត់កម្មករសំណង់ដាច់ខាត ពីការទន្ទ្រានចូលព្រៃដើម្បីបរបាញ់សត្ត និងកាប់ព្រៃឈើ ។* - *ក្រុមហ៊ុនកោះពស់នឹងធ្វើកិច្ចសហការល្អជាមួយខ័ណ្ឌរដ្ឋបាលព្រៃឈើខេត្តព្រះសីហនុ រដ្ឋបាលព្រៃឈើ និងក្រសួងកសិកម្មដើម្បីសុំការអនុញ្ញាតកាប់ដើមឈើលើកោះមួយចំនួនសំរាប់ការដ្ឋានសាងសង់ ។* - *ក្រុមហ៊ុនកោះពស់នឹងអនុវត្តតាមកិច្ចសន្យាជួលកោះពស់ក្នុងក្រុងព្រះសីហនុរវាងក្រុមហ៊ុនកោះពស់ជាមួយរាជរដ្ឋាភិបាលកម្ពុជាចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៦ ដែលមានចែងក្នុងកថាខ័ណ្ឌទីបី ត្រង់ចំនុន ៣.៣ ថា "ក្នុងការអនុវត្តន៍គំរោង ភាគី (ខ) មានសិទ្ធិកាប់ឆ្ការព្រៃ ដើម្បីអភិវឌ្ឍន៍លើទីតាំងវិនិយោគតាមបម្លង់មេ ។ ដើមឈើទាំងអស់នៅលើទីតាំងវិនិយោគដែលត្រូវកាប់សំរាប់គោលបំណងនៃសិទ្ធិប្រើប្រាស់ទីតាំងវិនិយោគដែលបានអនុញ្ញាត ហើយប្រសិនបើដើមឈើទាំងនោះមានតំលៃសេដ្ឋកិច្ច នោះភាគី(ខ) ត្រូវបង់ចំណូលជូនរដ្ឋស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ទើបមានសិទ្ធិប្រើប្រាស់ ឬលក់ឈើទាំងនោះដោយស្របច្បាប់ ។ ពុំនោះទេ ឈើដែលកាប់រួចហើយត្រូវប្រគល់ជូនរដ្ឋវិញ ។"*
ការរស់ក្នុងទឹក/ មច្ឆា	នៅដំណាក់កាលសាងសង់ គំរោងអាចប៉ះពាល់ដល់ជីវិតសត្វក្នុងទឹកដូចជា មឹក បង្គា ត្រីត្រីតុកែ និងផ្កាថ្មដែលរស់នៅក្នុងតំបន់កោះពស់ ។ ហេតុប៉ះពាល់ដល់ធនធានទាំងនោះបណ្តាលពីការប្រែប្រួលគុណភាពទឹក (ទឹកមាន កករ/ ភាពល្អក់ខ្ពស់ កាកសំណល់កំពប់ចូល ទៅក្នុងទឹក សំលេង និង រំញ័រចេញពីសកម្មភាព សាងសង់) ។ ជួនកាលការនេសាទខុសច្បាប់ (ការបំផ្ទុះ ឬការប្រើថ្នាំបំពុល) ពីសំណាក់កម្មករសំណង់ ក៏បណ្តាលឱ្យមានហេតុប៉ះពាល់ ឬបំផ្លាញភាវ		✓		- *ការទប់ស្កាត់ឥតរដី និងកំទេចកំណឱ្យបានល្អគឺជាតំរូវការចាំបាច់នៅគ្រប់កន្លែងនៃការដ្ឋានសាងសង់នៅក្នុងទឹក និងនៅឆ្នេរសមុទ្រ/មាត់ទឹក ដោយដាក់ក្រណាត់ស្រាក់ឥតរដីនៅជុំវិញ កន្លែងសាងសង់នៅក្នុងទឹក ហើយសាងសង់ស្រះរងកករនៅកន្លែងសាងសង់នៅឆ្នេរសមុទ្រ ឬតាមមាត់ទឹក ។* - *គ្រប់គ្រងសំណល់ប្រេងម៉ាស៊ីន ឬប្រេងរំអិលនានាឱ្យបានត្រឹមត្រូវ ដោយប្រមូលទុកដាក់ក្នុងធុង និងប្រើប្រាស់ឡើងវិញ ឬលក់ឱ្យអ្នកយកទៅប្រើក្នុងបំណងផ្សេងៗ ។* - *ថែទាំ និងជួសជុលគ្រឿងចក្រ និងយានយន្តគំរោងមិនឱ្យលេចកំពប់ប្រេង/ខ្លាញ់លើដីឬក្នុងទឹក ។* - *អប់រំដល់កម្មករមិនឱ្យចោលកាកសំណល់ចូលទៅក្នុងប្រភពទឹក ហើយផ្តល់មធ្យោបាយគ្រប់គ្រាន់ដើម្បីគ្រប់គ្រងកាកសំណល់ រួមបញ្ចូលទាំងសាងសង់បង្គន់អនាម័យនៅក្នុងទីកន្លែងសាងសង់ និងជុំវិញស្នាក់នៅ ។* - *បាមឃាត់ដាច់ខាតចំពោះកម្មករសំណង់មិនឱ្យធ្វើនេសាទខុសច្បាប់ ហើយក្រុមហ៊ុនធ្វើកិច្ច*

	រសក្នុងទឹក និងធនធានមច្ឆា នៅក្នុងតំរោងផងដែរ ។				*សហការជាមួយខ័ណ្ឌរដ្ឋបាលជលផលខេត្តព្រះសីហនុ ដើម្បីធ្វើអធិការកិច្ច និងទប់ស្កាត់សកម្មភាពនេសាទ ខុសច្បាប់នៅក្នុងតំបន់គំរោង ។*
ទេសភាព	ក្នុងអំឡុងពេលសាងសង់គំរោង នឹងមានហេតុប៉ះពាល់ដល់ទេសភាពនៅក្នុងតំបន់ ដោយសារភាពផ្លាស់ប្តូរបានលេខា ពីការឈូសឆាយដី កាយបើកចំហផ្ទៃដី កាប់សំអាតរុក្ខជាតិ និងការដាក់ឧបករណ៍ សំភារៈ គ្រឿងចក្រស្មេកស្ពៃ ។ ការបុកសសរគ្រឹះ និងសកម្មភាពសាងសង់ដទៃទៀត នឹងបង្កឱ្យមានភាពមិនស្រស់ស្រាយនៅតំបន់កោះពស់ ។	✓			- *ក្រុមហ៊ុននឹងរៀបចំផែនការឱ្យបានល្អសំរាប់ការកាប់សំអាតរុក្ខជាតិសំរាប់ការដ្ឋានសាងសង់ចាំ ជាច់ ឧទាហរណ៍ការដ្ឋានសាងសង់នៅលើកោះពស់នឹងត្រូវធ្វើជាបួកៗ គឺមិនបើកចំហការដ្ឋាន សាងសង់នៅពេលតែមួយរួមគ្នានោះទេ ។* - *ការដាំដុះរុក្ខជាតិឡើងវិញ នៅកន្លែងដែលបានបញ្ចប់ការងារសំណង់ស៊ីវិល ដើម្បីរក្សាតំបន់ទាំងមូល ឱ្យមានភាពបៃតងដូចស្ថានភាពដើម ។* - *គ្រឿងតែងលំអ (ផ្ទាំងរូបភាពស្អាតៗ) នៅបរិវេណការដ្ឋានសាងសង់ផ្នេរហាវ៉ៃ និងការដ្ឋានដទៃទៀត នឹងត្រូវបានផ្តល់ឱ្យក្នុងអំឡុងពេលសាងសង់ ។*
ការបំពុលខ្យល់	ការភាយចេញពី ម៉ាស៊ីនសាងសង់រួមមានធូលី/ភាគល្អិតអណ្តែត ខ្យល់ក្រខ្វក់ (NO_2, SO_2, CO) និងផ្សែងចេញពីការបំផ្ទុះផ្ទៃនៅការដ្ឋាន ម៉ាស៊ីនភ្លើង ម៉ាស៊ីនលាយស៊ីម៉ង់ត៍ សកម្មភាពដឹកជញ្ជូនសំភារៈសំណង់ឱ្យតំរោងនឹងធ្វើឱ្យប៉ះពាល់ដល់គុណ ភាពខ្យល់ក្នុងតំបន់ ។	✓			- *ក្រុមហ៊ុននឹងប្រើប្រាស់ថាមពលអគ្គិសនីពីបណ្តាញអគ្គិសនីកម្ពុជាសាខាក្រុងព្រះសីហនុ ជាប្រភពអគ្គិសនីចំបងសំរាប់គំរោង ហើយម៉ាស៊ីនភ្លើងរបស់គំរោងប្រើសំរាប់តែពេលភ្លើងរដ្ឋដាច់ប៉ុណ្ណោះ ។* - *ក្រុមហ៊ុននឹងប្រើ ម៉ាស៊ីនសាងសង់ និងឡានដឹកបូរថយន្តធំៗរបស់គំរោង ដែលមានគុណភាពល្អ និងមានផ្សែងតិច ។* - *គ្របសំភារៈសាងសង់ (ស៊ីម៉ង់ត៍ ត្រួស ខ្សាច់ ។ល ។) នៅពេលដឹកជញ្ជូនចូលទៅការដ្ឋានសាងសង់ ។* - *ស្រោចទឹក លើតំនរត្រួស ឬខ្សាច់ នៅរដូវប្រាំង ។ ត្រូវដាក់ក្រណាត់សើម សំរាប់ចាប់ធូលីនៅកន្លែងបញ្ជូនធូលី ពីម៉ាស៊ីនលាយស៊ីម៉ង់ត៍ ។*
គុណភាពទឹក	គុណភាពទឹកនៅការដ្ឋានស្ពានកោះពស់ ផ្នេរហាវ៉ៃ និងនៅជុំវិញកោះពស់ នឹងត្រូវថយចុះគុណភាព ដោយសារសកម្មភាពសាងសង់		✓		- *វិធានការ/ការទប់ស្កាត់កកកណ្តាល និងសំណឹកដីត្រឹមត្រូវនឹងត្រូវផ្តល់ (ដាក់ក្រណាត់ព័ទ្ធជុំវិញកន្លែងសាងសង់នៅក្នុងទឹក ឬកែ្សរមាត់ទឹក) ។* - *ក្រុមហ៊ុននឹងអប់រំបុគ្គលិក/កម្មករមិនឱ្យចោះចោលសំរាម/កាកសំណល់ចូលទៅក្នុងប្រភពទឹក*

Draft

	ដូចជាការឈូសឆាយដី ការខួង ការបុកសសរ ការសង់ក្រ៊ីះស្ពាន ការចោលកាកសំណល់ ការកំពប់ឥន្ធនៈ និងប្រេងរំអិលពីម៉ាស៊ីន គ្រឿងចក្រសាងសង់ចូលទៅលើ ឆ្នេរសមុទ្រ/ក្នុងទឹកសមុទ្រ ឬនៅតាមកន្លែងទំនេរកែ្សរនោះ ។ ជួនកាលការបង្ហូរទឹកក្រខ្វក់ដ៏ច្រើនពីសកម្មភាព សាងសង់ និងជំរុំកម្មករចូលទៅក្នុងប្រភពទឹក និងដីទំនេរអាចកើតមានឡើងផងដែរ ។				*លើយផ្តល់សំការៈគ្រប់គ្រងកាកសំណល់រាប់ទាំងសាងសង់បង្គន់អនាម័យឱ្យបានគ្រប់គ្រាន់នៅការដ្ឋានសំណង់ និងនៅជំរុំស្នាក់នៅរបស់បុគ្គលិក/កម្មករ ។* - *គ្រប់គ្រងសំណល់ប្រេងម៉ាស៊ីន និងប្រេងរំអិលឱ្យបានត្រឹមត្រូវដោយប្រមូលទុកដាក់ក្នុងធុង និងប្រើប្រាស់ឡើងវិញ ឬលក់ឱ្យអ្នកយកទៅប្រើក្នុងបំណងផ្សេងៗ ។* - *ថែទាំ និងជួសជុលគ្រឿងចក្រ គំរោងមិនឱ្យលេចកំពប់ប្រេង និងខ្លាញ់លើដី ឬក្នុងទឹក ។*
					- *ការត្រួតពិនិត្យគុណភាពទឹកនៅជុំវិញការដ្ឋានគំរោង នឹងត្រូវអនុវត្តឱ្យបានទៀងទាត់ ដើម្បីធានាថាគុណភាពរបស់ទឹកនៅពេលសាងសង់មិនមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ជីវិតសត្ត និងរុក្ខជាតិក្នុងទឹក និងមនុស្ស ។ ប៉ារ៉ាម៉ែត្រសំខាន់ៗសំរាប់ត្រួតពិនិត្យគុណភាពទឹកគឺ TSS, DO, BOD5, Total N, Total P, Cd, Hg, and Pb ។*
កាកសំណល់	សំណល់រឹងដូចជា កាកសំណល់នៃសំការៈ សំណង់ សំណល់ផ្ទះបាយ និងសំណល់ចេញពីមនុស្សអាចកើតមាននៅការដ្ឋានសាងសង់ និងជំរុំស្នាក់នៅរបស់បុគ្គលិក/កម្មករគំរោង ។ ការគ្រប់គ្រងកាកសំណល់ក្នុងការដ្ឋានសាងសង់ និងក្នុងជំរុំស្នាក់នៅរបស់បុគ្គលិក/កម្មករមិនបានល្អ នឹងបង្ក ឱ្យមានបញ្ហាជាច្រើន ដូចជា ធ្វើឱ្យខូចសោភ័ណ្ឌភាព បំពុលគុណភាពដី គុណភាពខ្យល់ និងគុណភាពទឹក បង្កើតជំរក និងសត្វចង្រៃចំលងរោគ ដូចជា ម្ជូស រ៉ុយ ហើយចុងក្រោយគឺប៉ះពាល់ដល់សុខភាពសត្ត		✓		- *ក្រុមហ៊ុននឹងអប់រំកម្មករមិនឱ្យចោះចោលកាកសំណល់ទៅក្នុងខ្សែទឹក និងផ្តល់ឱ្យនូវសេវាកម្មគ្រប់គ្រងសំរាមរួមទាំងបង្គន់អនាម័យក្នុងទីតាំងការដ្ឋានសាងសង់ និងក្នុងជំរុំបុគ្គលិក/កម្មករ ។ ជាក់ស្តែង ក្រុមហ៊ុនកោះពស់មានកិច្ចសន្យាជាមួយក្រុមហ៊ុន CINTRI សាខាក្រុងព្រះសីហនុ ដើម្បីប្រមូលសំរាមការិយាល័យ និងសំរាមផ្ទះបាយយកទៅចោះចោល ។* - *ក្រុមហ៊ុននឹងសាងសង់ស្រះរងកករ ដែលមានតួនាទីសំអាតបឋមនៃទឹកដែលប្រើប្រាស់ចេញពីការដ្ឋានសាងសង់ និងជំរុំស្នាក់នៅរបស់បុគ្គលិក/កម្មករ ។ សំការៈសំលាប់មេរោគ ដូចជាម្សៅកំបោរស៊ី និងក្ល័រនឹងត្រូវបានប្រើដើម្បីសំអាតទឹកក្នុងស្រះរងកករ ក្នុងករណីបើចាំបាច់ ។* - *គ្រប់គ្រងសំណល់សំការៈសំណង់ឱ្យបានត្រឹមត្រូវ ដូចជា ឈើ ដែក ក្រដាស និងស្បោងប្លាស្ទិក ព្រមទាំងសំណល់ប្រេង និងប្រេងរំអិលចេញពីគ្រឿងចក្រសាងសង់ ដោយប្រមូលទុកក្នុងធុងដើម្បីប្រើប្រាស់ឡើងវិញ ឬលក់ឱ្យអ្នកប្រើប្រាស់ផ្សេងទៀត ។*

Draft

	ក្នុងទឹក សត្វពាហនៈ និងសុខភាពមនុស្ស។				
សំលេង និងរំញ័រ	សំលេង និងរំញ័រដែលកើតចេញពីគ្រឿងចក្រសាងសង់ ជាពិសេស ការបុកសសរគ្រឹះ រថយន្តធំ១/យានយន្ត ប្រើសំរាប់ដឹកជញ្ជូនសំភារៈសំណង់នឹងកើតមានឡើងនៅក្នុង និងនៅជុំវិញការដ្ឋានសាងសង់។ សំលេង និង រំញ័រ នៅ ការដ្ឋានសាងសង់ស្ពានកោះពស់ និងឆ្នេរ ហាវ៉ៃ គឺចាត់ជាប្រភពបំពុលដល់សហគមន៍ នៅទីនេះ។	✓			- *ក្រុមហ៊ុនកោះពស់ នឹងប្រើប្រាស់គ្រឿងចក្រ និងរថយន្តធំ១/យានយន្តគំរោងទាំងអស់ដែលមានគុណភាពល្អ បញ្ចេញសំលេង និងរំញ័រតិច។* - *ក្រុមហ៊ុននឹងផ្តល់ឧបករណ៍ និងសំភារៈ ដូចជា កាស់ពាក់នៅត្រចៀកការពារសំលេងជូនដល់បុគ្គលិក កម្មករគំរោងនៅការដ្ឋានធ្វើការដែលមានសំលេងខ្លាំង។* - *រាល់សកម្មភាពសាងសង់ទាំងអស់របស់គំរោងមរកត នឹងត្រូវអនុវត្តនៅក្នុងរយៈពេលម៉ោងធ្វើការ ពេលថ្ងៃ (៧:៣០-១១:៣០ និង ១៣:៣០-១៧:៣០) និងគោរពតាមកំរិតកំណត់សំលេងក្នុងតំបន់សាធារណៈ ដូចមានចែងក្នុងឧបសម្ព័ន្ធទី៦នៃអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង។*
ដំណាក់កាលប្រតិបត្តិ					
ចរាចរណ៍	ការកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍អាចកើតឡើងនៅលើផ្លូវដែលពាក់ព័ន្ធទៅនឹងកិច្ចដំណើរការ គំរោងមរកត ជាពិសេសផ្លូវពីរធ្ម និងស្ពានកោះពស់ ដោយការកើនឡើងនូវរថយន្ត ឡានធំ ម៉ូតូ និងទោចក្រយានដែលចរាចរណ៍លើផ្លូវក្នុងតំបន់គំរោង។ ជូនកាលគ្រោះថ្នាក់ចរាចរណ៍អាចកើតឡើងនៅលើស្ពានផងដែរ ដោយសារ ការធ្វេសប្រហែសរបស់អ្នកបើកបរ ឬអ្នកប្រើប្រាស់ផ្លូវ/ស្ពាន។	✓			- *ក្រុមហ៊ុននឹងបំពាក់ភ្លើងចរាចរណ៍ ស្លាកសញ្ញាចរាចរណ៍ និងភ្លើងបំភ្លឺនៅតាមបណ្តោយស្ពានទាំងសងខាង ខាងក្រោមស្ពាន ដូចមានចែងក្នុងកិច្ចសន្យាបន្ថែមរវាងក្រុមហ៊ុនកោះពស់ ជាមួយរាជរដ្ឋាភិបាលកម្ពុជា។* - *ក្រុមហ៊ុនកោះពស់នឹងធ្វើសហប្រតិបត្តិការជាមួយមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះសីហនុ ដើម្បីបំពាក់ភ្លើងបំភ្លឺ និងស្លាកសញ្ញាចរាចរណ៍លើផ្លូវពីរធ្ម។* - *ក្រុមហ៊ុនកោះពស់នឹងធ្វើសហប្រតិបត្តិការជាមួយភ្នាក់ងារប៉ូលីសក្នុងក្រុងព្រះសីហនុ ដើម្បីផ្តល់ប៉ូលីសចរាចរណ៍ ដើម្បីប្រចាំការលើច្រកចូលស្ពាន និងកន្លែងប្រសព្វគ្នានៃផ្លូវសំខាន់ៗនៅក្នុងតំបន់គំរោង។*
សិទ្ធិប្រើប្រាស់ទឹក	គំរោងនឹងមានហេតុប៉ះពាល់ដល់ គ្រួសារ			✓	- *ក្រុមហ៊ុននឹងអនុញ្ញាតឲ្យអ្នកនេសាទធ្វើសកម្មភាពនេសាទជុំវិញកោះពស់ក្នុងចំងាយ ១០០ម៉ែត្រ*

និងសិទ្ធិទូទៅ	អ្នកនេសាទមួយចំនួន បើសិនគំរោងនឹងហាមឃាត់សកម្មភាពនេសាទបែបគ្រួសារនៅទីនេះ ។ តំរូវការទឹក យ៉ាងច្រើនសំរាប់កិច្ចប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធនៅលើកោះ និងលើឆ្នេរហាវ៉ៃ នេះអាចប៉ះពាល់ដល់បរិមាណទឹកប្រើរបស់អ្នកក្រុងព្រះសីហនុយ៉ាងខ្លាំង ។ គំរោងនឹងប៉ះពាល់ដល់ការប្រើប្រាស់ឆ្នេររបស់ប្រជាពលរដ្ឋទូទៅ ដែលចង់ទៅលេងកំសាន្ត នៅឆ្នេរហាវ៉ៃ និងឆ្នេរកោះពស់ បើគំរោងហាមឃាត់មិនឱ្យចូលក្រៅពីភ្ញៀវរបស់ខ្លួន ។				*ពីមាត់ទឹក ដើម្បីថែរក្សាភាពស្អាតស្អំ និងសុវត្ថិភាពដល់ប្រជាជាន និងភ្ញៀវដែលរស់នៅលើកោះ ។* - *ក្រុមហ៊ុននឹងផ្តល់អាទិភាពជ្រើសរើសគ្រួសារអ្នកនេសាទដែលនឹងរងផលប៉ះពាល់ឱ្យចូលធ្វើការជាបុគ្គលិក/កម្មករបស់គំរោងទេ អំឡុងពេលប្រតិបត្តិគំរោង ។* - *ក្រុមហ៊ុននឹងអនុញ្ញាតឱ្យប្រជាពលរដ្ឋចូលលេងកំសាន្តលើឆ្នេរហាវ៉ៃតាមធម្មតា និងអនុ-ញ្ញាតឱ្យចូលទៅលេងលើកោះពស់និងឆ្នេរកោះពស់ក្នុងកំរិតកំណត់ដោយដឹកជញ្ជូនតាមឡានប្រើអគ្គិសនីពីតល់ស្ពានខាងជើងកោះដើម្បីធានាបានទាំងសុវត្ថិភាព និងភាពស្អាត ដល់ឆ្នេរ និងបរិស្ថានលើកោះទាំងមូល ។*
សុខភាពសាធារណៈ	ការគ្រប់គ្រងសំណល់រឹងមិនបានត្រឹមត្រូវនៅលើកោះពស់ និងនៅឆ្នេរហាវ៉ៃនឹងបង្កឱ្យមានក្លិនស្អុយ ក្រខ្វក់ដី និងក្រខ្វក់ទឹក ព្រមទាំងបង្កើតជំរកប៉ាក់តេរី និងភ្នាក់ងារចំលងជំងឺ ដែលនាំឱ្យប៉ះពាល់ដល់សុខភាពមនុស្ស ។ ការគ្រប់គ្រងទឹកក្រខ្វក់មិនបានល្អ ឬភាពមិនដំណើរការល្អនៃអាងធ្វើប្រព្រឹត្តកម្មសំអាតទឹកស្អុយ នៅលើកោះពស់ ក៏ដូចជានៅឆ្នេរហាវ៉ៃ នឹងបំពុលគុណភាពទឹកនៅជុំវិញកន្លែងដែលបង្ហូរចេញ បឹងប៉ះពាល់ដល់សុខភាព		✓		- *ក្រុមហ៊ុននឹងផ្តល់ឱ្យគ្រប់គ្រាន់នូវគ្រឿងសំភារៈគ្រប់គ្រងសំណល់រឹងដូចជា ធុងដាក់សំរាម និងកន្លែងដាក់សំរាមតាមការចនាប្លង់ទាន់សម័យទំនើបសំរាប់តំបន់រមណីយដ្ឋាន (ធុងសំរាមមានបីប្រភេទដូចជា (១) ធុងសំរាមក្រដាស់/ប្លាស្ទិក/កំទេចដែក/កែវ (២) ធុងសំរាមសំណល់អាហារនិងបន្លែ និង (៣) ធុងសំរាមគ្រោះថ្នាក់(ថ្មពីល អាគុយ សំណល់ថ្នាំពេទ្យ និងសារធាតុពុលនានា ។ល ។) - *ក្រុមហ៊ុនកោះពស់នឹងធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុនផ្តល់សេវាកម្មប្រមូលសំរាម (ដូចជា CINTRI) ដើម្បីប្រមូលយក ដឹកជញ្ជូន និងយកទៅចោះចោលរាល់សំណល់រឹងទាំងអស់ដែលកើតចេញពីកិច្ចដំណើរ ការគំរោងមរកតទាំងមូល ។* - *ក្រុមហ៊ុនធ្វើការត្រួតពិនិត្យជាប្រចាំ ដើម្បីធានាថាកិច្ចដំណើរការនៃអាងធ្វើប្រព្រឹត្តិកម្មទាំងអស់របស់គំរោងមានដំណើរការល្អ ដែលធានាបានទូវតំលៃនៃកំរិតប៉ារ៉ាម៉ែត្របង្ហូរចេញស្របតាមបទដ្ឋាន បង្ហូរចេញទៅតំបន់ទឹកសាធារណៈ ដែលកំណត់ដោយក្រសួងបរិស្ថាននៃប្រទេសកម្ពុជា ។*

Draft

	ភ្ញៀវឬអ្នកមកលេងទីកក្នុងតំបន់នោះ ។			- ក្រុមហ៊ុនមរកតមានសាងសង់មន្ទីរពេទ្យបាល ឬមណ្ឌលសុខភាពនៅលើកោះពស់ និងមានផ្តល់សេវាកម្មថែទាំសុខភាពចំពោះភ្ញៀវទេសចរណ៍ក៏ដូចជាប្រជាពលរដ្ឋក្នុងខេត្តព្រះសីហនុផងដែរ ។ - ក្រុមហ៊ុនកោះពស់នឹងធ្វើសហប្រតិបត្តិការណ្ណជាមួយភ្នាក់ងារថែទាំសុខភាពថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់ ឬថ្នាក់អន្តរជាតិ ដើម្បីដោះស្រាយរាល់បញ្ហាសុខភាពនៅក្នុងតំបន់គំរោង ។
ហានិយភ័យ	ក្នុងពេលស្ពានដំណើរការ ស្ពាននេះអាចជាកន្លែងគោលដៅសំរាប់មនុស្សមួយចំនួនធ្វើអត្ត ឃាត (អ្នកមោចាំង ឬអ្នកខូចចិត្ត ទៅលោតទីកសម្លាប់ខ្លួន) ដូចធ្លាប់កើតមានឡើងជាធម្មតានៅស្ពានធំ១ក្នុងប្រទេសកម្ពុជា ។ ជួនកាល ការរុញច្រានគ្នាដោយចេតនា ឬដោយអចេតនា និងការប្រជ្រៀតគ្នាហួសហេតុនៅលើស្ពាន ក៏អាចបង្កជាគ្រោះថ្នាក់ដល់ជីវិតបានដែរ ។	✓		**<u>វិធានការការពារហានិយភ័យ</u>** - ក្រុមហ៊ុននឹងមានដាក់ឆ្នាំស្ពាន និងប៉ូលីសឱ្យបានគ្រប់គ្រាន់នៅលើស្ពាន ព្រមទាំងរៀបចំឱ្យមានឆ្នាំស្ពានបីវេន ដើម្បីធានាសុវត្ថិភាព ២៤ ម៉ោង លើ២៤ ម៉ោង ។ - គំរោងនេះមានបំពាក់ភ្លើងបំភ្លឺទាំងផ្នែកខាងលើស្ពាន និងខាងក្រោមស្ពាន បានគ្រប់គ្រាន់ ។ - អនុញ្ញាតឱ្យប្រជាពលរដ្ឋចូល លេងកំសាន្តលើផ្នែរហាវ៉ៃតាមធម្មតា និងអនុញ្ញាតឱ្យចូលទៅលេងលើកោះពស់និងផ្នែរកោះពស់ក្នុងកំរិតកំណត់ ដោយដឹកជញ្ជូនតាមឡានប្រើអគ្គិសនីពីតល់ស្ពានខាងជើងកោះ ដើម្បីធានាបានទាំងសុវត្ថិភាព និងភាពស្អាតដល់ផ្នែរនិងបរិស្ថានលើកោះទាំងមូល ។ - ក្រុមហ៊ុននឹងរៀបចំផែនការសុវត្ថិភាព និងសន្តិសុខទូទៅ ដើម្បីបញ្ជៀស ភាពកកស្ទះនៅតល់ស្ពាន និងលើស្ពាននៅពេលមានប្រារព្ធពិធីពិសេសៗជា សាធារណៈនៅលើកោះពស់ ។ **<u>វិធានការនៅពេលមានហានិយភ័យកើតឡើង</u>** - ក្រុមហ៊ុនកោះពស់នឹងប្រើប្រាស់កំលាំងសមត្ថកិច្ច និងធនធានឧបករណ៍សំភារៈរបស់ក្រុមហ៊ុនឱ្យអស់លទ្ធភាព និងធ្វើកិច្ចសហការជាមួយប៉ូលីស សមត្ថកិច្ច គ្រប់ជាន់ថ្នាក់ក្នុងក្រុងព្រះសីហនុ និងភ្នាក់ងារសង្គ្រោះដទៃទៀតឱ្យបាន ទាន់ពេលវេលា ដើម្បីដោះស្រាយចំពោះបញ្ហាហានិយភ័យដែលអាច កើតឡើងលើកោះពស់ និងស្ពានកោះពស់ ។ - ធានាការដោះស្រាយជាបន្ទាន់ ចំពោះការបាត់បង់ទ្រព្យសម្បត្តិ និងអាយុជីវិតទៅតាមច្បាប់វិនិយោគ ការធានារ៉ាប់រងរបស់ក្រុមហ៊ុន និងកាតព្វកិច្ចច្បាប់ នានារបស់កម្ពុជា ។

Draft

ព្រៃឈើ និងសត្វព្រៃ	គំរោងនឹងប៉ះពាល់ដល់សត្វព្រៃ ជាពិសេស ពពួកបក្សីនៅតំបន់កោះពស់ ដោយសារនៅពេល ដំណើរការគំរោង និងមានមនុស្សច្រើនកុះករ នៅលើកោះ ។ ជាងនេះទៀត ព្រៃឈើចំនួន ៤៦ហ.ត នៅលើកោះ ត្រូវបានបាត់បង់ក្នុងពេល សាងសង់គំរោង ដូចនេះសត្វព្រៃបានបាត់បង់ ជំរករបស់វា និងថយចុះប្រព័ន្ធអេកូឡូស៊ីលើ កោះពស់ និងតំបន់ក្បែរខាង ។		✓		- *ការដាំលើឡើងវិញនៅកន្លែងដីវ៉ាលចាំបាច់មួយចំនួនលើកោះពស់ ដែលអាចរក្សាបានជាជំរកបក្សីព្រៃ និងជំរកសត្វព្រៃដទៃទៀត ។ ធ្វើបានដូចេ្នះអាចអភិរក្សនូវប្រព័ន្ធអេកូឡូស៊ីនៅក្នុងតំបន់នេះបានមួយចំនួន ។*
	គំរោងបានធ្វើឱ្យថយសមត្ថភាពស្រូបជាតិឧស្ម័នកាបូនឌីអុកស៊ីតប្រមាណជា ២៤.១១៩ តោន/ឆ្នាំ ហើយបាត់បង់កំនើនមាឌឈើ ៤០ តោន/ឆ្នាំ ។				- *ក្រុមហ៊ុននឹងចូលរួមវិភាគទានក្នុងកម្មវិធីអភិរក្ស និងការដាំព្រៃឈើឡើងវិញនៅក្នុងខេត្តព្រះសីហនុ ឧទាហរណ៍ក្រុមហ៊ុននឹងចូលរួមវិភាគទានក្នុងទិវាដាំដើមឈើជាដើម ។ល ។*
ភាវរសក្នុងទឹក/ មច្ឆា	ហេតុប៉ះពាល់លើ ភាវរសក្នុងទឹក/មច្ឆា អាចនឹងកើតមានឡើង ដោយសារការបង្ហូរទឹកក្រខ្ជ ដែលគ្មានការសំអាតចូលក្នុងប្រភពទឹក ការចោលសំរាម/សំណល់រឹងនៅលើឆ្នេរ ឬតាមមាត់ទឹក ។ គំរោងនឹងមានហេតុប៉ះពាល់ តិចតួចទៅមធ្យមលើភាវរសត្ว/ភាវរុក្ខជាតិ ជាមួយនឹងការបណ្តុំជាតិពុលជាបន្តបន្ទាប់ហូរចូលទៅក្នុងទឹក ។ ភាពងាយស្រួលក្នុងការចេញចូលបណ្តាល		✓		- *គំរោងមរកតមានផែនការទប់ស្កាត់ និងធ្វើឱ្យប្រសើរឡើងនូវធនធានធម្មជាតិសំរាប់ការអភិវឌ្ឍផ្នែកទេសចរណ៍ ដូចនេះសកម្មភាពនេសាទ និងការប្រមូលភាវរសត្វនឹងត្រូវមានកំណត់ ។* - *ក្រុមហ៊ុននឹងធ្វើសហប្រតិបត្តិការល្អជាមួយខ័ណ្ឌរដ្ឋបាលជលផលខេត្តព្រះសីហនុ និងអនុញ្ញាតឱ្យអ្នកនេសាទធ្វើសកម្មភាពនេសាទនៅតំបន់កោះពស់ក្នុងចំងាយដែនកំណត់ពីមាត់ច្រាំង (យ៉ាងតិច ១០០ ម៉ែត្រ ពីច្រាំងកោះពស់)* - *គ្រប់គ្រងឱ្យបានល្អចំពោះកាកសំណល់ដែលកើតចេញពីការប្រតិបត្តិគំរោង ។ ត្រូតពិនិត្យយ៉ាងខ្ជាប់ខ្ជួនទូវអាងធ្វើប្រព្រឹត្តិកម្មទឹកស្អុយឱ្យមានដំណើរការល្អ លើយតំលៃនៃប៉ារ៉ាម៉ែត្របង្ហូរចេញគោរពតាមបទដ្ឋាននៃការបង្ហូរចូលតំបន់ទឹកធម្មជាតិដែលកំណត់ដោយក្រសួងបរិស្ថាន ។*

Draft

	មកពីកិច្ចដំណើរការស្តានអាចទាក់ទាញដល់អ្នកនេសាទ ឬភ្ញៀវទេសចរណ៍ចូលមក និងធ្វើនេសាទនៅតាមកែ្សរច្រាំងកោះពស់ ។				- ក្រុមហ៊ុននឹងធ្វើសហប្រតិបត្តិការល្អជាមួយខ័ណ្ឌរដ្ឋបាលជលផលខេត្តព្រះសីហនុ ដើម្បីត្រួតពិនិត្យតាមដានវារីសត្ត/ត្រី និងវារីរុក្ខជាតិក្នុងតំបន់កោះពស់ទាំងមូលអំឡុងពេលដំណើរការគំរោង ។ នឹងមានផែនការធ្វើអង្កេតលើត្រី និងផ្តាច់ផ្ទនៅជុំវិញកោះពស់ (១00ម ពីមាត់ច្រាំង) ជាវ្យែងរាលពីរឆ្នាំម្តងពេញរយៈពេលប្រតិបត្តិការគំរោង ដើម្បីពិនិត្យមើលធនធានធម្មជាតិនេះ និងរកដំណោះស្រាយធ្វើយ៉ាងណារក្សានិរន្តភាពវាឱ្យបាន ។
ដីប្រើប្រាស់	ការផ្លាស់ប្តូរនៃដីប្រើប្រាស់លើកោះពស់ គឺការថយចុះនូវព្រៃឈើក្នុងតំបន់ឆ្នេរដោយសារការអភិវឌ្ឍន៍ដី និងសកម្មភាពអភិវឌ្ឍន៍ផ្សេងទៀត នៅលើកោះ ហើយមានការប្រែប្រួលប្រព័ន្ធអេកូ ឡូស៊ីនៅលើកោះ និងអាចបង្កផលអាក្រក់ដល់ផែព្រះសីហនុដោយសារខ្យល់បោកបក់ខ្លាំង និងរកលធំ១ ។	✓			- ក្រុមហ៊ុននឹងរៀបចំផែនការអភិវឌ្ឍឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំ និងបទដ្ឋានក្នុងន័យការអភិវឌ្ឍដែលមានលក្ខណៈសេដ្ឋកិច្ចផង និងការពារបានទូវបរិស្ថានផង ។ - បញ្ជៀសរាល់ការបំផ្លិច បំផ្លាញដល់ធនធានបរិស្ថានធ្ងន់ធ្ងរជាពិសេសប្រព័ន្ធអេកូឡូស៊ីតំបន់កោះពស់ និង បញ្ជៀសរាល់ទំនាស់សង្គមធ្ងន់ធ្ងរក្នុងតំបន់គំរោង ។ - ក្រុមហ៊ុននឹងធ្វើសហប្រតិបត្តិការជាមួយស្ថាប័នជំនាញនានាក្នុងខេត្តព្រះសីហនុ ក៏ដូចក្រសួងពាក់ព័ន្ធដើម្បីដោះស្រាយរាល់ទំនាស់នានាដែលទាក់ទងនឹងការអភិវឌ្ឍគំរោងនេះ ។
ការបំពុលខ្យល់	ការកើនឡើងនូវរថយន្តធុនធ្ងន់ និងរថយន្តដឹកផ្សេងៗ នៅតំបន់កោះពស់ ក៏ដូចជានៅក្នុងក្រុងព្រះសីហនុ នឹងបញ្ចេញផ្សែងក្រខ្ចក់មួយចំនួនចូលទៅក្នុងបរិយាកាសនៅក្នុងតំបន់ ។ ការបំភាយពីរថយន្តតូចធំ និងទោចក្រយានយន្តទាំងនោះ រួមមាន NO_2, SO_2, CO, និង TSP	✓			- ការពារព្រៃឈើឱ្យបានល្អ (ដើមឈើ និងរុក្ខជាតិនានា) នៅលើកោះ និងនៅដីគោកនៅក្នុងតំបន់កោះពស់ទាំងមូល ហើយការដាំដើមឈើនៅកន្លែងទំនេរ ឬនៅតាមបណ្តោយផ្លូវក៏អាចជួយរក្សាឱ្យមានខ្យល់អាកាសបរិសុទ្ធផងដែរ ។
ការបំពុលទឹក	ការបោះចោលសំរាមចូលក្នុងទឹកសមុទ្រ ឬនៅលើឆ្នេរកោះពស់ និងឆ្នេរហាវ៉ៃនឹងបំពុល		✓		- គ្រប់គ្រងឱ្យបានល្អចំពោះកាកសំណល់គំរោង ដែលកើតចេញពី លំនៅដ្ឋាន សណ្ឋាគារ អាគារការិយាល័យ តំបន់ពាណិជ្ជកម្ម និងតំបន់សាធារណៈនៅលើកោះពស់ និងនៅឆ្នេរហាវ៉ៃ ។

	គុណភាពទឹកនៃតំបន់ឆ្នេរសមុទ្រនេះ។ ជួនកាលការបង្ហូរទឹកក្រខ្វក់មិនបានសំអាតចេញពីសហគមន៍ ឬសកម្មភាពដំណើរការគំរោង ចូលក្នុងប្រភពទឹកអាចកើតមានឡើង។ ការមិនដំណើរការល្អនៃអាងធ្វើប្រព្រឹត្តិកម្មសំអាតទឹកក្រខ្វក់នៅ លើកោះពស់ និងនៅឆ្នេរហាវ៉ៃអំឡុងពេលប្រតិបត្តិគំរោងនឹងបំពុលគុណភាពទឹកសមុទ្រក្នុងតំបន់នេះ។				*ជាឧទាហរណ៍សំណល់រឹង គឺមានការគ្រប់គ្រងយ៉ាងល្អដោយមានប្រព័ន្ធប្រមូលយកតាមការទាមទារនៃបរិស្ថានស្អាតសមជាទីស្ថានទេស លើយទឹកក្រខ្វក់គឺមានតភ្ជាប់យ៉ាងល្អត្រឹមត្រូវ និងធ្វើការសំអាតដោយអាងធ្វើប្រព្រឹត្តកម្មមុននឹងបង្ហូរចេញចូលទៅក្នុងសមុទ្រ។* - *ក្រុមហ៊ុននឹងថែទាំ និងត្រួតពិនិត្យយ៉ាងខ្ជាប់ខ្ជួននូវអាងធ្វើប្រព្រឹត្តិកម្មទឹកស្អុយឲ្យមានដំណើរការល្អ លើយតំលៃនៃប៉ារ៉ាម៉ែត្របង្ហូរចេញគោរពតាមបទដ្ឋាននៃការបង្ហូរចូលតំបន់ទឹកធម្មជាតិដែលបានកំណត់ដោយក្រសួងបរិស្ថាន។*
					- *ត្រួតពិនិត្យគុណភាពទឹកនៅជុំវិញទីតាំងគំរោង នឹងត្រូវអនុវត្តឲ្យបានទ្រៀងទាត់ ដើម្បីធានាថាគុណភាពរបស់ទឹកនៅពេលប្រតិបត្តិគំរោងមិនមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ជីវិតសត្ត និងរុក្ខជាតិក្នុងទឹក និងមនុស្ស។ ប៉ារ៉ាម៉ែត្រសំខាន់ៗសំរាប់ត្រួតពិនិត្យគុណភាពទឹកគឺ TSS, DO, BOD_5, Total N, Total P, Cd, Hg, និង Pb.*
កាកសំណល់	ការចោលសំណល់រឹង/សំរាមលើផ្ទៃដីលើឆ្នេរមាត់ទឹក និងក្នុងផ្ទៃទឹក ពីសំណាក់ភ្ញៀវទេសចរណ៍ ឬសហគមន៍ រស់នៅលើកោះពស់ អំឡុងពេលប្រតិបត្តិគំរោងអាចនឹងកើតមានឡើង លើសិនប្រព័ន្ធគ្រប់គ្រងសំណល់រឹងមិនផ្តល់ឲ្យបានគ្រប់គ្រាន់ និងមិនដំណើរការល្អ។	✓			- *កាកសំណល់រឹងដែលកើតចេញពី លំនៅដ្ឋាន សណ្ឋាគារ អាគារ ការិយាល័យ តំបន់ពាណិជ្ជកម្ម និងតំបន់សាធារណៈនៅលើកោះពស់ និងនៅឆ្នេរហាវ៉ៃ នឹងត្រូវបានប្រមូល ទុកដាក់ និងយកទៅបោះចោលតាមការទាមទារនៃបរិស្ថានស្អាតសំរាប់តំបន់រមណីយដ្ឋាន។ ក្រុមហ៊ុននឹងផ្តល់ធុងដាក់សំរាមដោយឡែកៗពីគ្នាតាមប្រភេទសំរាម ដូចជា (១) ធុងសំរាមក្រដាស់/ប្លាស្ទិក/កំទេចដែក/កែវ (២) ធុងសំរាមផ្ទុះបាយ និង (៣) ធុងសំរាមគ្រោះថ្នាក់(ថ្មពិល អាគុយ សំណល់ថ្នាំពេទ្យ និងសាធាតុពុលនានា។ល។)* - *ប្រព័ន្ធប្រមូលសំរាមផ្ទុះបាយមួយដងទៅពីរដងក្នុងមួយថ្ងៃនឹងត្រូវអនុវត្តចំពោះគំរោងមរកត។ ប្រើប្រាស់ឡានដឹកសំរាមដែលមានគុណភាពល្អ ដើម្បីធានាមិនឲ្យមានការលេច ឬកំពុបសំរាមតាមដងផ្លូវឡើយ។* - *ក្រុមហ៊ុនកោះពស់នឹងធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុនប្រមូលសំរាមនៅក្នុងក្រុងព្រះសីហនុ (ក្រុមហ៊ុន CINTRI) ដើម្បីប្រមូល ដឹកជញ្ជូន និងយកទៅបោះចោលនូវសំណល់រឹងទាំងអស់ដែលចេញពីគំរោងមរកត ពេញរយៈពេលប្រតិបត្តិគំរោង។*

Draft

៦.៣ *បណ្តុំនៃហេតុប៉ះពាល់*

បណ្តុំនៃផលប៉ះពាល់នឹងត្រូវបានកើតមានឡើងនៅក្នុងដំណាក់ការសាងសង់ និងក្នុងពេលប្រតិបត្តិការគំរោងនៃបន្ទុំសកម្មភាពអភិវឌ្ឍន៍ដទៃទៀតនៅក្នុងគំរោង ដូចជាមណ្ឌលលំហែកាយ និងមណ្ឌលពាណិជ្ជកម្ម Emario នៅជិតតំបន់កោះពស់ (ដោយក្រុមហ៊ុនជប៉ុន) សកម្មភាពកំពង់ផែក្រុងព្រះសីហនុ និងសកម្មភាពអភិវឌ្ឍន៍ទីក្រុងនៅក្នុងទីកដីសង្កាត់លេខ៣។

ការគ្រប់គ្រងកាកសំណល់មិនបានល្អពីសកម្មភាពទេសចរណ៍ អ្នកនេសាទ/ទូកនេសាទ និងសកម្មភាពលក់ដូរនៅតាមបណ្តោយឆ្នេរក្នុងតំបន់កោះពស់ គឺបានរួមចំណែកក្នុងការបំពុល/បំផ្លាញតំបន់ឆ្នេរ ឬក៏តំបន់ឈូងសមុទ្រទាំងមូល។ ជូនកាល ការលាងសំអាតកប៉ាល់ ឬក៏ការគ្រប់គ្រងកាកសំណល់រឹងមិនបានល្អនៅក្នុងកំពង់ផែព្រះសីហនុអាចចូលរួមចំណែក ធ្វើឱ្យប៉ះពាល់ទៅដល់គុណភាពទឹក ឬក៏អាចបំពុលឆ្នេរសមុទ្រនៅក្នុងតំបន់ផងដែរ។

បណ្តុំនៃផលប៉ះពាល់នៅក្នុងតំបន់គំរោងរួមមាន **ការបាត់បង់ឆ្នេរសាធារណៈ ការប្រើប្រាស់ទឹកស្អាតក្រុងចរាចរណ៍ ការបំពុលខ្យល់ ការបំពុលទឹក និងកាកសំណល់**ពី ការសាងសង់ និងសកម្មភាពប្រតិបត្តិការនៃគំរោងទាំងនោះ។ ជាឧទាហរណ៍ តាមលទ្ធផលនៃការប្រមូលសំរាមនៅលើឆ្នេរកោះពស់ និងឆ្នេរហាវ៉ៃដោយសិក្សាក្រុម KCC ក្នុងឆ្នាំ២០០៨-២០០៩ បានបង្ហាញថា មានសំរាមប្រហែល ៨០គីឡូក្រាម/ថ្ងៃនៅជុំវិញកោះពស់ និងមានចំនួន១០០គីឡូក្រាម/ថ្ងៃនៅលើឆ្នេរហាវ៉ៃ (មានមែកឈើ ស្លឹកឈើ ប្លាស្ទិក និងកែវ) បានអណ្តែត និងនៅលើឆ្នេរនៅក្នុងតំបន់ឆ្នេរជុំវិញកោះពស់ និងនៅលើឆ្នេរហាវ៉ៃ។

➢ *វិធានការបន្ទូរបន្ទាយ នៃបណ្តុំហេតុផលប៉ះពាល់:*

<u>ការបាត់បង់ឆ្នេរសាធារណៈ:</u>

- គ្រប់ក្រុមហ៊ុនដែលទទួលបានការអភិវឌ្ឍលើឆ្នេរសាធារណៈពីមុនមកដូចជា ឆ្នេរសុខា ឆ្នេរឯករាជ្យ និងឆ្នេរហាវ៉ៃជាដើម នឹងជួយគាំទ្រដល់ អាជ្ញាធរខេត្ត និងក្រសួងពាក់ព័ន្ធក្នុងការរៀបចំឱ្យមានឆ្នេរសាធារណៈនៅតំបន់ឆ្នេរនៃខេត្តព្រះសីហនុ ដើម្បីជួយសំរួលដល់ការមកកំសាន្តរបស់ប្រជាពលរដ្ឋ គ្រប់លំដាប់ថ្នាក់។

<u>ការប្រើប្រាស់ទឹកស្អាតក្រុង:</u>

- រាល់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ឬគំរោងដែលមានការប្រើប្រាស់បរិមាណទឹកស្អាតច្រើនត្រូវមានការបង្ហាញជូននូវតំរូវការទឹកសរុប និងពិភាក្សាលើសមត្ថភាពផ្គត់ផ្គង់ទឹកស្អាតរបស់រដ្ឋាភិបាលទឹកស្វ័យតក្រុងព្រះសីហនុ ដើម្បីឱ្យអង្គភាពនេះធ្វើការពង្រីកសមត្ថភាពរោងចក្រ និងបណ្តាញផ្គត់ផ្គង់បានទាន់ពេលវេលា ដែលបញ្ជៀសបានការខ្វះខាតទឹកប្រើប្រាស់ដល់អ្នកក្រុងនៅពេលគំរោងផ្សេងៗ ត្រូវបានអនុវត្ត ឬដំណើរការ។

ចរាចរណ៍:

- គ្រប់ក្រុមហ៊ុនអនុវត្តគំរោងទាំងអស់ត្រូវផ្តល់ស្លាកសញ្ញាចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍ និងអ្នកបញ្ជាចរាចរណ៍ នៅក្នុងការដ្ឋានគំរោងផ្ទាល់ ។
- បណ្តុះបណ្តាលបុគ្គលិកគំរោង និងអ្នកបើកបរឱ្យគោរពច្បាប់ចរាចរណ៍ ។
- ត្រូវប្រើប្រាស់គ្រឿងចក្រ និងយានយន្តដែលមានគុណភាពល្អ ។
- ត្រូវថែទាំផ្លូវចេញចូលដែលបានប្រើប្រាស់ដោយការធ្វើសកម្មភាពគំរោងឱ្យបានទៀងទាត់ ។
- សហប្រតិបត្តិការជាមួយមន្ទីរសាធារណការ និងដឹកជញ្ជូននៅក្នុងខេត្តព្រះសីហនុដើម្បីថែរក្សាស្ថានភាពផ្លូវថ្នល់ ស្លាកសញ្ញាចរាចរណ៍ និងភ្លើងសញ្ញាចរាចរណ៍នៅក្នុងតំបន់គំរោង ។

ការបំពុលខ្យល់:

- ត្រូវប្រើប្រាស់រថយន្តដឹក និងយានយន្តដែលមានគុណភាពល្អ ។
- គ្របដណ្តប់លើស៊ីម៉ង់ត៍ ខ្សាច់ និងកំទេចថ្មទាំងអស់ដែលដឹកជញ្ជូនចេញ និងចូលតំបន់គំរោង ។
- ស្រោចទឹកលើផ្លូវដីដែលប្រើប្រាស់ដោយគំរោង អំឡុងពេលរដូវប្រាំង/ឬពេលស្ងួត ។
- ត្រូវមានដាក់ក្រណាត់សើមនៅជុំវិញម៉ាស៊ីនលាយស៊ីម៉ង់ត៍ ដើម្បីចាប់យកផង់ធូលី

ការបំពុលទឹក:

- ក្រុមហ៊ុនអនុវត្តគំរោងទាំងអស់ ត្រូវមានបំពាក់អាងប្រព្រឹត្តកម្ម ដើម្បីច្រោះសំអាតទឹកក្រខ្ទក់របស់ខ្លួន ហើយក៏រិតជាតិពុលក្នុងទឹកដែលត្រូវបង្ហូរចេញ គឺផ្អែកទៅតាមតំលៃស្តង់ដានៃការបញ្ចេញចោលរបស់ក្រសួងបរិស្ថានសំរាប់តំបន់ទឹកសាធារណៈ ។
- ត្រួតពិនិត្យជាប្រចាំនូវអាងប្រព្រឹត្តកម្មសំអាតទឹកក្រខ្ទក់ឱ្យស្ថិតក្នុងដំណើរការល្អ ។
- ពិនិត្យតាមដានជាប្រចាំនូវគុណភាពទឹកនៅចំណុចបង្ហូរចេញ ។
- ប្រើប្រាស់សារធាតុសំរាប់មេរោគ ដូចជា ម្សៅកំបោររស់ និងក្លរ បើមានការចាំបាច់ ។

កាកសំណល់រឹង:

- ក្រុមហ៊ុនអនុវត្តគំរោងទាំងអស់ត្រូវគ្រប់គ្រងកាកសំណល់របស់គេផ្ទាល់ឱ្យបានត្រឹមត្រូវ ដោយផ្អែកទៅតាមគោលការណ៍គ្រប់គ្រងកាកសំណល់របស់ក្រសួងបរិស្ថាន ។
- សហប្រតិបត្តិការល្អជាមួយគ្នា និងភ្នាក់ងារបរិស្ថាន ដើម្បីគ្រប់គ្រងកាកសំណល់នៅក្នុងតំបន់ឆ្នេរឱ្យបានស្អាត ។
- ចូលរួមផ្តល់វិភាគទានៅក្នុងកម្មវិធីបោសសំអាតកាកសំណល់នៅក្នុងតំបន់ ជាពិសេស ការចូលរួមសំអាតនៅតាមបណ្តោយឆ្នេរ ។

Draft

៦.៤ ផលប៉ះពាល់វិជ្ជមាន

✚ ហេដ្ឋារចនាសម្ព័ន្ធ

ក្រុងព្រះសីហនុ ឬក៏តំបន់ឆ្នេរភាគខាងត្បូងនៃប្រទេសកម្ពុជានឹងបានទទួលស្គានថ្មីមួយដែលមានបណ្តោយ ៩០០ម៉ែត្រ និងផ្លូវចេញចូលរាប់រយម៉ែត្រនៅទាំងសងខាងស្គាន ដែលអាចតភ្ជាប់ពីដីគោកទៅកោះពស់នេះ ។

នៅលើកោះពស់ ក្លាយជាតំបន់អភិវឌ្ឍន៍ទីក្រុងថ្មីជាមួយនឹងសមទ្ធិផលជាច្រើនរួមមាន:-

(១) បង្ការបាយបំរើឱ្យវិស័យទេសចរណ៍ ដូចជា សណ្ឋាគារផ្កាយ៥ ផ្ទះល់ៃបែរកាយនៅលើទឹកចំនួន២៤ ជាមួយនឹងរានហាលជាកញ្ចក់មើលឃើញគ្រប់ទិស ឆ្នេរខ្សាច់ដ៏ស្អាត កាស៊ីណូ ទីលានវាយកូនគោល ក្លឹបរាត្រី/រង្គសាល ភោជនីយដ្ឋាន និងហាងលក់វត្ថុអនុស្សាវរីយ៍ ។

(២) តំបន់ពាណិជ្ជកម្ម មានដូចជា ហាងលក់ដូរ មណ្ឌលបាត់ប្រាណ កន្លែងម៉ាស្សា និងមានផ្សារទំនើប ហើយមានសេវាកម្មសាធារណៈ មានដូចជា សាលារៀន ប៉ូលីក្លីនិច មន្ទីរពេទ្យខ្នាតតូច វត្តអារាម មណ្ឌលកំសាន្តរបស់កុមារ ទីលានបាល់ទាត់ និងទីលានវាយកូនបាល់/តេនីស និងស្ថានីយ៍ប៉ូលីស ។

(៣) តំបន់តាំងទីលំនៅមានដូចជា ផ្ទះល្វែង ភូមិគ្រឹះឯកជន និងផ្ទះល់ៃបែរកាយនៅក្នុងព្រៃ ។

(៤) បណ្តាញផ្លូវថ្នល់លើកោះពស់ទាំងមូល ។

នៅលើឆ្នេរហាវ៉ៃមានសណ្ឋាគារខ្ពស់ៗជាច្រើន លំនៅដ្ឋានខ្ពស់ៗ មណ្ឌលពាណិជ្ជកម្ម ភូមិគ្រឹះឯកជន ក្លឹបកំសាន្តពេលរាត្រី ភោជនីយដ្ឋាន និងការិយាល័យសំរាប់ជួល ។

តំរោងនេះនឹងក្លាយទៅជាបន្ទុំហេដ្ឋារចនាសម្ព័ន្ធចំរុះបន្ថែមទៀតនៅក្នុងក្រុងព្រះសីហនុ ព្រមទាំងនៅក្នុងខេត្តព្រះសីហនុ ដែលបានផ្តល់បន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធផ្នែកដឹកជញ្ជូន ផ្នែកពាណិជ្ជកម្ម និងផ្នែកទេសចរណ៍នៅក្នុងតំបន់ ដើម្បីសំរេចគោលដៅយុទ្ធសាស្ត្រនៃការអភិវឌ្ឍសេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ។

✚ គុណប្រយោជន៍បរិស្ថាន

ផ្នែកទៅលើតំរោង**មរកត**នេះ នឹងមានការការពារទៅលើភាវរសក្នុងទឹក/ធនធានជលផលនៅក្នុងតំបន់កោះពស់ និងអាចថែរក្សាជំរកសំរាប់សត្វរស់នៅក្នុងទឹក/ត្រី ។ ការទប់ស្គាត់នៃការនេសាទខុសច្បាប់ និងការប្រមូលផ្តាច្ច នឹងជាកត្តាមួយចូលរួមចំណែកក្នុងការធ្វើឱ្យប្រសើរឡើងនូវសត្ត និងរុក្ខជាតិរស់នៅក្នុងទឹកក្នុងតំបន់កោះពស់ ។ ជាមួយនឹងភាពស្អាត (ដោយគ្មានការបំពុល) និងជាទីកន្លែងមានសុវត្ថិភាព ដោយសកម្មភាពនេសាទពាណិជ្ជកម្ម និងនេសាទជាលក្ខណៈគ្រួសារ ជាង់នេះទៅទៀត តំបន់នេះនឹងជាជំរកមួយដ៏ល្អសំរាប់ការបង្កាត់ពូជ និងការលូតលាស់សត្វរស់នៅក្នុងទឹក និងពពួកត្រីជំនាន់ក្រោយទៀតផង ។

- **ការងារ**

គំរោងនេះ នឹងផ្តល់ការងារយ៉ាងច្រើនដល់ប្រជាជនមូលដ្ឋាននៅក្នុងខេត្តព្រះសីហនុ បើយោងទៅតាមផែនការមេរបស់គំរោងបានបង្ហាញថា នៅក្នុងដំណាក់ការសាងសង់ គំរោងនេះត្រូវការកម្មករ និងបុគ្គលិកចំនួន ៩៩០នាក់ និងនៅក្នុងដំណាក់ការប្រតិបត្តិការត្រូវការកម្មករ និងបុគ្គលិកចំនួន ១៤៧០នាក់។ នៅក្នុងនោះអ្នកបច្ចេកទេស និងវិស្វករកម្ពុជាមានឱកាសបានចូលធ្វើការសំរាប់គំរោងនេះផងដែរ។

- **ទេសចរណ៍**

គំរោង**មរកត**នេះ នឹងផ្តល់ឱ្យនូវភាពសម្បូណ៌បែបនៃហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់ឆ្នេរដែលអាចបំរើទៅដល់ប៉ូលដែលមានសក្តានុពលសំរាប់ការអភិវឌ្ឍវិស័យទេសចរណ៍នៅក្នុងប្រទេសកម្ពុជា។ ដោយមានការតភ្ជាប់ស្ពានពីដីគោកទៅកោះពស់ និងការអភិវឌ្ឍឆ្នេរហាវ៉ៃអាចពង្រីកតំបន់បន្ថែមទៀតសំរាប់សកម្មភាពទេសចរណ៍ នឹងមានកំណើនអ្នកទេសចរណ៍មកកាន់ក្រុងព្រះសីហនុ ក៏ដូចជាខេត្តព្រះសីហនុទាំងមូល។

- **ប្រាក់ចំណូល**

គំរោងនឹងបង្កើតប្រាក់ចំណូលសំរាប់ប្រជាជនមូលដ្ឋានដោយសារការផ្តល់ការងារក្នុងការសាងសង់ និងដំណាក់ការប្រតិបត្តិគំរោង។ ប្រជាជនមួយចំនួនអាចរកប្រាក់ចំណូលពីការលក់ដូរផ្ទាល់ខ្លួនរបស់ពួកគេ ដែលជាប់ពាក់ព័ន្ធទៅនឹងសកម្មភាពគំរោង ឧទាហរណ៍ពួកគេអាចលក់ដូរចំណីអាហារសំរាប់កម្មករ និងបុគ្គលិកគំរោង។ ប្រជាជនអាចរកប្រាក់បានផងដែរ ដោយសារការលក់ផលិតផលរបស់ពួកគេនៅក្នុងទីផ្សារក្នុងស្រុកនេះ និងផ្តល់សេវាកម្មសំរាប់សកម្មភាពទេសចរណ៍ទៀតផង។

- **សេដ្ឋកិច្ច**

ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗដែលមានស្រាប់នៅក្នុងក្រុងព្រះសីហនុ រាប់ទាំងកំពង់ផែកំពង់សោម ព្រលានយន្តហោះកងកេង និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតនៅក្នុងក្រុង នោះគំរោង**មរកត**មិនគ្រាន់តែបំរើទៅដល់វិស័យទេសចរណ៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបំរើឱ្យវិស័យអភិវឌ្ឍន៍ ផ្សេងៗទៀត ដូចជា វិស័យពាណិជ្ជកម្ម វិស័យទូរគមនាគមន៍ វិស័យឧស្សាហកម្ម វិស័យកសិកម្ម និងវិស័យផ្សេងៗទៀត។ ដូចនេះហើយ ប្រាក់ចំណូលនិងផលប្រយោជន៍ដែលនឹងទទួលបានពីវិស័យខាងលើ នឹងធ្វើឱ្យកើនឡើងនូវជីវភាពរបស់ប្រជាជន និងការរីកចំរើនសេដ្ឋកិច្ចនៅក្នុងខេត្តព្រះសីហនុ ព្រមទាំងសេដ្ឋកិច្ចជាតិទាំងមូល។

ជាងនេះទៅទៀត ជាមួយនឹងតំលៃវិនិយោគគំរោងសរុបប្រមាណជា ៤៤០លានដុល្លាសហរដ្ឋអាមេរិក ដែលជាថវិការវិនិយោគពីបរទេស និងមានប្រាក់ចំណូលពីការបង់ពន្ធប្រចាំឆ្នាំក្នុងការប្រតិបត្តិគំរោងនឹងជាកត្តាមួយដើម្បីគាំទ្រចំពោះការរីកចំរើននៃសេដ្ឋកិច្ចជាតិ។